គណៈកម្មការទន្លេមេគង្គ

# វារីវប្បកម្មទឹកសាប នៅតំបន់អាងទន្លេមេគង្គក្រោម

អត្ថបទបច្ចេកទេសនៃគណៈកម្មការទន្លេមេគង្គ

លេខ ៧

ខែ មេសា ឆ្នាំ ២០០២



បំពេញតម្រូវការ និង រក្សាតុល្យភាព

MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

គណៈកម្មការទន្លេមេគង្គ

# វារីវប្បកម្មទឹកសាប
# នៅតំបន់អាងទន្លេមេគង្គក្រោម

អត្ថបទបច្ចេកទេសនៃគណៈកម្មការទន្លេមេគង្គ

លេខ ៧

ម.ព.ឯ.ក AIDOC
Code: 140-006
Date:
Donated by:

ខែ តុលា ឆ្នាំ ២០០២

បោះពុម្ពផ្សាយនៅរាជធានីភ្នំពេញ ខែ តុលា ឆ្នាំ ២០០២
ដោយគណៈកម្មការទន្លេមេគង្គ

សូមដាក់នៅក្នុងឯកសារយោងរបស់លោកអ្នកដូចខាងក្រោម :

Phillips, M.J. 2002. Freshwater Aquaculture in the Lower Mekong Basin. MRC Technical Paper No. 7, Mekong River Commission, Phnom Penh, 62pp. ISSN:1683-1489.

អត្ថបទបច្ចេកទេសនេះត្រូវបានរៀបចំចងក្រងដោយ ហ្វីលីព (M. J. Phillips)
រួមជាមួយបណ្តាអ្នកដែលមានឈ្មោះនៅក្នុងសេចក្តីថ្លែងអំណរគុណ ។ រាល់មតិ ឬ ការបកស្រាយដែលមាននៅក្នុងអត្ថបទនេះ
គឺជាទស្សនៈរបស់អ្នកនិពន្ធផ្ទាល់ និង ពុំឆ្លុះបញ្ចាំងទស្សនៈរបស់គណៈកម្មការទន្លេមេគង្គឡើយ ។

កែសំរួលដោយ : អាន់ ប៊ីហ្សប់
រៀបចំរចនាជាភាសាខ្មែរដោយ : ម៉ងឃី ខាថូន
បកប្រែជាភាសាខ្មែរដោយ : ជិន ដា   នាយកដ្ឋានជលផល
ពិនិត្យ និងកែសំរួលដោយ : ឯកឧត្តម ណៅ ធូក និង លោក លាង   សុផា  នាយកដ្ឋានជលផល
សម្របសម្រួលបោះពុម្ពជាភាសាខ្មែរដោយ : លាង  សុផា

©គណៈកម្មការទន្លេមេគង្គ
ប្រអប់សំបុត្រលេខ ១១១២ អាគារលេខ : ៣៦៤  មហាវិថីព្រះមុនីវង្ស
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ : (៨៥៥-២៣)៧២០ ៩៧៩ ទូរសារ : (៨៥៥-២៣) ៧២០ ៩៧២
អ៊ីម៉ែល : mrcs@mrcmekong.org
គេហទំព័រ : www.mrcmekong.org

# សេចក្តីថ្លែងអំណរគុណ

ព័ត៌មានដែលមាននៅក្នុងអត្ថបទនេះ គឺបានប្រមូលចងក្រងសម្រាប់ពិនិត្យឡើងវិញអំពីវិស័យជលផលដោយគណៈកម្មការទន្លេមេគង្គហើយបានកែសម្រួលជាបន្តបន្ទាប់ឱ្យទៅជាអត្ថបទបច្ចេកទេស ។ អត្ថបទនេះត្រូវបានរៀបចំឡើងដោយមានការចូលរួមចំណែកពីវារីវប្បកម្ម និង អ្នកជំនាញការអភិវឌ្ឍន៍ជនបទដែលបំរើការងារនៅអាងទន្លេមេគង្គ។ ការជួបពិភាក្សាជាមួយអ្នកជំនាញការទាំងនេះ ដោយមានការរៀបចំសម្របសម្រួលដោយមជ្ឈមណ្ឌលបណ្តាញវារីវប្បកម្មសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក (NACA) នៅទីក្រុងបាងកក នាខែ ឧសភា ឆ្នាំ ២០០១ រៀបចំសេចក្តីព្រៀងលើកទី១ ដោយមានការជួបពិគ្រោះយោបល់បន្ថែមជាមួយមជ្ឈមណ្ឌលបណ្តាញវារីវប្បកម្មសម្រាប់តំបន់អាស៊ីបាស៊ីហ្វិក (NACA) ។

## ពាក្យសរសេរកាត់

| | |
|---|---|
| ACIAR | មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ស្រាវជ្រាវកសិកម្មអន្តរជាតិ |
| AIMS | វារីវប្បកម្មនៃប្រភេទត្រីទន្លេមេគង្គ |
| AIT | វិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី |
| DFID | នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ (នៃប្រទេសអង់គ្លេស) |
| DoF | នាយកដ្ឋានជលផល |
| FAO | អង្គការស្បៀង និង កសិកម្មនៃអង្គការសហប្រជាជាតិ |
| IPM | គ្រប់គ្រងសត្វល្អិតចម្រុះ |
| Lao PDR | សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ |
| LARReC | មជ្ឈមណ្ឌលស្រាវជ្រាវធនធានវារីជាតិ |
| MRC | គណៈកម្មការទន្លេមេគង្គ |
| NACA | មជ្ឈមណ្ឌលបណ្តាញវារីវប្បកម្មសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| READ | គម្រោងផ្សព្វផ្សាយអភិវឌ្ឍវារីវប្បកម្មជនបទ |
| STREAM | អង្គការជំនួយការគាំទ្រការគ្រប់គ្រងធនធានវារីជាតថ្នាក់តំបន់ |
| VAC | ភាសាវៀតណាម "វ៉ូន" (សួន ឬ សួនផ្កា) "អាវ" (ស្រះត្រី) និង ជួង" (ទ្រុងជ្រូក ឬ ទ្រុងមាន់ទា) |

# មាតិកា

សេចក្តីសង្ខេប

**១. ស្ថានភាពវារីវប្បកម្មទឹកសាបនៅក្នុងតំបន់អាងទន្លេមេគង្គក្រោម**

១.១. ប្រវត្តិសង្ខេប......៥

១.២. ផលិតកម្មវារីវប្បកម្មនៅតំបន់អាងទន្លេមេគង្គក្រោម......៥

១.៣. ផលិតករ និង តួនាទីរបស់វារីវប្បកម្មនៅក្នុងសន្តិសុខស្បៀង និង ជីវភាពរស់នៅ......៦

១.៤. ប្រព័ន្ធវារីវប្បកម្ម និង ប្រភេទត្រីដាក់ចិញ្ចឹម......៨

១.៥. អតិថិជន និង ទីផ្សារ......១៤

១.៦. ស្ថាប័នទ្រទ្រង់វារីវប្បកម្ម......១៥

១.៧. វារីវប្បកម្ម និង បរិស្ថាន......១៧

**២. ការវិភាគអនុវិស័យវារីវប្បកម្ម**

២.១. ការអភិវឌ្ឍ ឱកាស និង ការគំរាមកំហែង......២១

២.២. តើមានសេវាកម្មគាំទ្រអ្វីខ្លះ ដែលគេត្រូវការជាចាំបាច់ ?......២៧

២.៣. តម្រូវការព័ត៌មាន និង កង្វះខាតព័ត៌មានដែលត្រូវបំពេញសម្រាប់វារីវប្បកម្ម......២៩

២.៤. តម្រូវការក្នុងការធ្វើផែនការចម្រុះ និង បទបញ្ញត្ត......៣០

២.៥. ឧបសគ្គក្នុងវារីវប្បកម្ម និង ដំណោះស្រាយសមស្រប......៣១

**៣. អនុសាសន៍សម្រាប់វារីវប្បកម្ម និង ការអភិវឌ្ឍនៅតំបន់អាងទន្លេមេគង្គក្រោម**

៣.១យុទ្ធសាស្ត្រនៃការកសាងផែនការនិង ការអនុវត្ត......៣២

៣.២.ការជួយទ្រទ្រង់វារីវប្បកម្មគ្រួសារ......៣៣

**៤. ឯកសារយោង និង ការអានបន្ថែម**......៣៧

# ខ្លឹមសារសង្ខេប

## ១. ប្រវត្តិសង្ខេប

វារីវប្បកម្ម ការចិញ្ចឹមសត្វ វារីសត្វ និង វារីរុក្ខជាតិ ជាសកម្មភាពសំខាន់ មានកំណើនឡើងយ៉ាងខ្លាំងក្លានៅតាមជនបទ វាជាប្រភពអាហារ និង ប្រាក់ចំណូលសម្រាប់ប្រជាជនដែលរស់នៅក្នុងអាងទន្លេមេគង្គក្រោម ។ អត្ថបទនេះពិនិត្យឡើងវិញនូវស្ថានភាពវារីវប្បកម្មទឹកសាបនៅបណ្តាប្រទេសក្នុងអាងទន្លេមេគង្គក្រោម ដូចជា កម្ពុជា ឡាវ ថៃ និង វៀតណាម ។ អត្ថបទនេះបង្ហាញកត្តាជាគន្លឹះ កំណត់ការអភិវឌ្ឍវារីវប្បកម្ម និង ផ្តល់អនុសាសន៍ដើម្បីបង្កើតឡើងនូវសារៈសំខាន់របស់វាក្នុងពេលអនាគតនៃផលិតកម្មស្បៀងអាហារ និង ការអភិវឌ្ឍជនបទនៅក្នុងអាងទន្លេមេគង្គក្រោម ។ ព័ត៌មានដែលមាននៅក្នុងអត្ថបទនេះបានមកពីភាគទានជាសំណេរ និង ការពិគ្រោះយោបល់ជាមួយអ្នកជំនាញការផ្នែកវារីវប្បកម្មនៅអាងទន្លេមេគង្គ និងអភិវឌ្ឍន៍ជនបទ ។ សេចក្តីព្រាងដំបូងត្រូវបានរៀបចំឡើង នៅឆ្នាំ ២០០១ សំរាប់ធ្វើការពិនិត្យមើលឡើងវិញលើវិស័យជលផលរបស់គណៈកម្មការទន្លេមេគង្គ (MRC) ហើយបានពិនិត្យកែសំរួលជាបន្តបន្ទាប់ដាក់ចូលទៅក្នុងអត្ថបទបច្ចេកទេសជាចំដោយឡែករបស់គណៈកម្មការទន្លេមេគង្គ (MRC) ស្តីពីវារីវប្បកម្ម ។ អត្ថបទនេះបានផ្តល់ឱ្យទាន់ពេលវេលាអំពីការពិនិត្យមើលឡើងវិញអំពីវារីវប្បកម្មដែលជាមធ្យោបាយមួយយ៉ាងសំខាន់សម្រាប់ផលិតកម្មស្បៀងអាហារ និង ជួយលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជននៅតាមជនបទក្នុងអាងទន្លេមេគង្គក្រោម ។

## ២. ស្ថានភាពវារីវប្បកម្ម

វារីវប្បកម្មក្នុងអាងទន្លេមេគង្គក្រោមមានសកម្មភាពផ្សេងៗចំរុះជាច្រើន ។ សកម្មភាពទាំងនោះរួមមានការបង្កាត់ពូជ ការភ្ញាស់កូនត្រី ការលក់កូនត្រីម្សៅ និង កូនត្រីពូជ ក៏ដូចជាការចិញ្ចឹមបំប៉នកូនត្រីម្សៅ និង កូនត្រីពូជដែលញាស់ក្នុងធម្មជាតិ ឬញាស់បែបសិប្បនិម្មិត ក្នុងប្រព័ន្ធទឹកបិទជិត ឬ ពាក់កណ្តាលបិទជិត ដូចជានៅតាមប្រព័ន្ធស្រះ វាលស្រែ និង បែត្រី ។ ផលិតផលវារីវប្បកម្មត្រូវបានលក់នៅទីផ្សារនិងតែងតែប្រើប្រាស់សម្រាប់ផ្គត់ផ្គង់ការបរិភោគក្នុងគ្រួសារផងដែរ ។ ការផ្តល់ដើមទុនសម្រាប់ធ្វើវារីវប្បកម្ម ដូចជាត្រីពូជ ចំណី ការថែទាំ ការកែច្នៃ ការលក់ដូរ និង ការប្រើប្រាស់ផលិតផលវារីវប្បកម្ម គឺជា សមាសភាពដ៏សំខាន់សម្រាប់ជីវភាពរស់នៅរបស់បុរសស្ត្រី និង កុមារក្នុងក្រុមគ្រួសារជាច្រើននៅតាមជនបទក្នុងតំបន់អាងទន្លេមេគង្គក្រោម ។

ជាង ១០ ឆ្នាំកន្លងទៅនេះ មានការអភិវឌ្ឍវារីវប្បកម្មទឹកសាបជាលំដាប់នៅតាមបណ្តាប្រទេសក្នុងតំបន់អាងទន្លេមេគង្គក្រោម ចាប់ពីប្រមាណពី ៦០.០០០ តោន នៅក្នុងឆ្នាំ ១៩៩០ ទៅ ២៦០.០០០ តោន នៅឆ្នាំ ១៩៩៩-២០០០ ។ តួលេខនេះស្មើនឹង ១២ ទៅ ១៣% នៃផលិតផលវារីសត្វទឹកសាបសរុបនៅក្នុងអាងទន្លេមេគង្គក្រោម (ចំនួនប៉ាន់ប្រមាណ ២.០៣៦.០០០ តោន) ។ តួលេខនេះមិនទាន់រួមបញ្ចូលទាំងផលិតផលត្រី និង បង្គាទឹកភ្ជាវនៃតំបន់ដីសណ្តទន្លេមេគង្គឡើយ ។ ការអភិវឌ្ឍវារីវប្បកម្មភាគច្រើនដែលកើតមាននៅតំបន់ដីសណ្តទន្លេមេគង្គ មានលក្ខណៈមិនដូចគ្នាទេ ។ សកម្មភាពវារីវប្បកម្មភាគច្រើនត្រូវបានអនុវត្តនៅតំបន់ដីសណ្តទន្លេមេគង្គក្នុងប្រទេសវៀតណាម និង នៅតំបន់ខ្ពង់រាបកូរ៉ាត់ផ្នែកភាគឦសានប្រទេសថៃ ហើយផលិតកម្មវារីវប្បកម្មតិចតួចមាននៅប្រទេសកម្ពុជា និង ប្រទេសឡាវ ។ ទោះជាយ៉ាងនេះក្តី ការពិនិត្យឡើងវិញបានបង្ហាញថា ស្ថិតិជាផ្លូវការរបស់រដ្ឋាភិបាលប្រហែលធ្វើការប៉ាន់ប្រមាណអំពីសារៈសំខាន់នៃវារីវប្បកម្មទ្រង់ទ្រាយតូច

នៅទាបនៅឡើយ ហើយកំពុងមានសកម្មភាពរីកចំរើនយ៉ាងខ្លាំង មានតួនាទីយ៉ាងសំខាន់ ជាប្រភពចំណូល និង ជាស្បៀងអាហារសម្រាប់ប្រជាជននៅតាមជនបទ។

គោលនយោបាយរបស់រដ្ឋាភិបាលបានរួមចំណែកយ៉ាងសំខាន់ដល់ការរីកចំរើនថ្មីៗនៃវារីវប្បកម្ម។ ក្នុងរយៈពេលជាង ១០ ឆ្នាំកន្លងមកនេះ រដ្ឋាភិបាលនៅបណ្តាប្រទេសនៅតាមដងទន្លេមេគង្គបានជំរុញការវិនិយោគលើផ្នែកស្រាវជ្រាវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ និង ការងារផ្សព្វផ្សាយ ។ រដ្ឋាភិបាលប្រទេសថៃ និង ប្រទេសវៀតណាមបានធ្វើការវិនិយោគយ៉ាងច្រើនក្នុងការងារអភិវឌ្ឍន៍វារីវប្បកម្ម ហើយប្រទេសវៀតណាមមានមហិច្ឆិតាក្នុងការធ្វើផែនការបណ្តុះបណ្តាលសមត្ថភាព និង ការងារផ្សព្វផ្សាយ។ ជាទូទៅ ការគាំទ្រការងារស្រាវជ្រាវបានផ្តោតតែទៅលើបញ្ហាបច្ចេកទេស និង ការបង្កើត និង អនុវត្តន៍ការរៀបចំរបៀបវារៈ ស្រាវជ្រាវឱ្យបានល្អិតល្អន់ជាមួយកសិករ ប៉ុន្តែនៅពេលថ្មីៗនេះ មានភស្តុតាងបង្ហាញពីការប្រែប្រួលសំដៅដល់ការអភិវឌ្ឍវារីវប្បកម្ម តាមរបៀបសម្របសម្រួលទៅរកតំរូវការជាក់ស្តែងរបស់កសិករ ។

និរន្តរភាពនៃវារីវប្បកម្មផ្សាភ្ជាប់គ្នាយ៉ាងជិតស្និទ្ធជាមួយនឹងមូលដ្ឋានធនធានធម្មជាតិនៅក្នុងអាងទន្លេមេគង្គ។ វារីវប្បកម្មទ្រង់ទ្រាយតូចអាចរួមចំណែកដល់ការកែលំអបរិស្ថាន ដូចជាតាមរយៈការស្តុកទឹកសម្រាប់រដូវប្រាំង និង ការប្រើប្រាស់ឡើងវិញនូវកាកសំណល់កសិកម្ម តាមរយៈស្រះធ្វើវារីវប្បកម្មជាដើម។ ការកង្វល់អំពីបញ្ហាបរិស្ថានទាក់ទងនឹងការបំពុលទឹកដែលបណ្តាលមកពីវិស័យផ្សេងទៀត ដូចជាកសិកម្ម ការស្តុកទឹក ការរីករាលដាលនៃជំងឺរបស់វារិសត្វ (សត្វរស់នៅក្នុងទឹក) ផលប៉ះពាល់នៃការចិញ្ចឹមត្រីក្នុងបែជាលក្ខណៈប្រពលវប្បកម្ម ការឆ្លងព្រូន និង ការបាត់បង់នៃនានាភាពនៃសេនេទិច (ពូជសុទ្ធ) តាមរយៈការបង្កាត់ពូជអន់ថយ និង ចរាចរឆ្លងដែននៃផលស្តុកដែលមានជំងឺឆ្លង។ បញ្ហាទាំងអស់នេះអាចកាត់បន្ថយតាមរយៈការអនុវត្តការគ្រប់គ្រងកសិដ្ឋានឱ្យបានល្អប្រសើរ និង មានប្រព័ន្ធកសិដ្ឋាន រួមទាំងយុទ្ធសាស្ត្រអភិវឌ្ឍន៍វារីវប្បកម្មចម្រុះក្នុងកសិដ្ឋាន និង ប្រព័ន្ធអេកូធម្មជាតិនៃអាងទន្លេមេគង្គទាំងមូល។ គោលបំណងដើម្បីកាត់បន្ថយភាពក្រីក្រ ការយល់ដឹងអំពីជីវភាពរស់នៅរបស់ប្រជាជនក្រីក្រអាចជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ដ៏មានតម្លៃមួយ។

**៣. អនាគតនៃវារីវប្បកម្ម :**

វារីវប្បកម្មកំពុងបន្តរីកចំរើនឥតឈប់ឈរនៅក្នុងអាងទន្លេមេគង្គ។ ក្នុងរយៈពេល ១០ ឆ្នាំខាងមុខ ក្នុងកិរិតម៉ាក្រូ និង និន្នាការប្រជាជននៅអាងទន្លេមេគង្គទាំងមូលនឹងត្រូវការផលិតផលវារីសត្វបន្ថែម ចំនួន ៤០០.០០០ តោន ទៀតដើម្បីរក្សាស្ថេរភាពប្រើប្រាស់នៅពេលបច្ចុប្បន្ន។ ការអភិវឌ្ឍវារីវប្បកម្មដែលនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញតម្រូវការនេះ ។

នៅតាមជនបទនៃតំបន់អាងទន្លេមេគង្គ បទពិសោធន៍បានបង្ហាញថា វារីវប្បកម្មទ្រង់ទ្រាយតូចបានផលិតបានផលម្នាក់ៗតិច ប៉ុន្តែបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងផលិតកម្មវារីវប្បកម្ម។ សក្តានុពលភាពក្នុងការធ្វើឱ្យមានការជះឥទ្ធិពលនៃវារីវប្បកម្មលើការអភិវឌ្ឍជនបទមានសារៈសំខាន់ណាស់។ នៅតំបន់ខ្លះដែលការផ្គត់ផ្គង់ត្រីនៅមានកំរិត នៅទីនោះមានបញ្ហាអសុវត្ថិភាពស្បៀង និង ភាពក្រីក្រ ដូចជានៅតំបន់ខ្ពង់រាបនៃប្រទេសឡាវ និង ប្រទេសវៀតណាម និង តំបន់នៅឆ្ងាយពីទន្លេមេគង្គ បឹងទន្លេសាបនៃប្រទេសកម្ពុជា វារីវប្បកម្មគួរត្រូវប្រើប្រាស់សម្រាប់ធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពស្បៀង។ ដើម្បីបង្កើន ការជះឥទ្ធិពលជាវិជ្ជមាននៃវារីវប្បកម្មនៅអាងទន្លេមេគង្គ ការគាំទ្រត្រូវផ្តោតចំពោះវារីវប្បកម្ម និង ដោះស្រាយបញ្ហាដែលប្រជាជនក្រីក្រជួបប្រទះដូចជា បញ្ហាឥណទាន និង ការផ្សព្វផ្សាយការយល់ដឹង ។

បច្ចេកវិទ្យាវារីវប្បកម្មទាំងនេះ ត្រូវបានអនុវត្តអស់រយៈកាលជាង ១០ ឆ្នាំមកហើយ និង ដែលជាសមិទ្ធិផលដ៏មានសារៈសំខាន់។ បច្ចេកវិទ្យាវារីវប្បកម្មដែលបំរើផលប្រយោជន៍ឱ្យប្រជាជនក្រីក្រអាចកំណត់លក្ខណៈរួមមួយដែលត្រូវការទុនវិនិយោគទាបដែលនាំឱ្យមានការប្រថុយគ្រោះថ្នាក់តិច និង ផ្តល់ផលក្នុងរយៈពេលខ្លី។ វាត្រូវមានលក្ខណៈសាមញ្ញងាយរៀនសូត្រអនុវត្ត តាមវិធីងាយផ្សព្វផ្សាយ ងាយបង្រៀនដល់គ្រូបណ្តុះបណ្តាល ហើយវាជួយផ្គត់ផ្គង់បែត្រីដល់ប្រជាជន នៅមូលដ្ឋានជនបទ។ បច្ចេកវិទ្យាវារីវប្បកម្មនេះអាចមានស្រះសម្រាប់ថែបំប៉នត្រីនៅក្នុងហាប៉ានៅ កន្លែងចិញ្ចឹមចម្មតា ចិញ្ចឹមត្រីនៅតាមវាលស្រែ និង បច្ចេកវិទ្យាចិញ្ចឹមត្រីតាមបែបែបសាមញ្ញ។

វារីវប្បកម្មត្រូវការធនធានជាច្រើនយ៉ាងដើម្បីជំរុញការរីកចំរើនលូតលាស់ ដូចជា ត្រូវមានពូជត្រីគ្រប់គ្រាន់ ចំណីត្រី (ជី និង ចំណី) ព្រមទាំងផ្ទៃដី និង ទឹក។ សេវាកម្មដែលជួយទ្រទ្រង់វារីវប្បកម្មមានសារៈសំខាន់ណាស់ ជាពិសេសនៅថ្នាក់មូលដ្ឋាន ។នៅតាមជនបទដែលមានសក្តានុពលភាពវារីវប្បកម្មសេវាកម្មត្រូវបង្កើនការយល់ដឹង និង ត្រូវជំរុញការគាំទ្រពីស្ថាប័ន ។ការចូលរួមដោយប្រជាជនក្រីក្រទាមទារឱ្យមានការផ្លាស់ប្តូរពីការផ្សព្វផ្សាយបច្ចេកវិទ្យាទៅជាការប្រើប្រាស់វិធីសាស្ត្រដែលមានភាពបត់បែនរស់រវើកទៅតាមសេចក្តីត្រូវការរបស់ប្រជាជនជាសំខាន់ និង តាមវិធីសាស្ត្រនៃការចូលរួម (participatory approach) តាមរយៈយន្តការទំនាក់ទំនងថ្មីៗ។ ការគាំទ្រដោយមានការយកចិត្តទុកដាក់របស់រដ្ឋាភិបាលចំពោះវារីវប្បកម្មទ្រង់ទ្រាយតូចការយល់ដឹង និង ការធ្វើការងារជាមួយប្រជាជនក្រីក្រនៅតាមជនបទនឹងផ្តល់តុល្យភាពជាចាំបាច់សំដៅឆ្ពោះទៅការអភិវឌ្ឍវារីវប្បកម្មតាមបែបពាណិជ្ជកម្ម។

បញ្ហានានានៅក្នុងតំបន់អាងទន្លេមេគង្គនឹងអាចមានផលប៉ះពាល់ដល់វារីវប្បកម្មនៅពេលអនាគត។ ទាំងនេះរួមទាំងការផ្លាស់ប្តូរបទពិសោធន៍ និង ចំណេះដឹងអំពីការអភិវឌ្ឍវារីវប្បកម្ម ជាពិសេសវារីវប្បកម្មទ្រង់ទ្រាយតូច និង ការឆ្ពោះទៅរកគោលនយោបាយរួមស្តីពីបញ្ហានៅក្នុងតំបន់អាងទន្លេមេគង្គទាំងមូល។ បញ្ហាពីរដែលគួរយកចិត្តទុកដាក់ជាចំបង គឺការគ្រប់គ្រងជំងឺឆ្លងនៃវារីសត្វ និង ការកាត់បន្ថយភាពប្រថុយនឹងគ្រោះថ្នាក់ចំពោះផលស្តុកធម្មជាតិដែលបណ្តាលមកពីការដាក់ចិញ្ចឹមប្រភេទវារីសត្វនាំចូលពីបរទេស ឬ តាមរយៈចរាចរឆ្លងដែន និង ការបង្កាត់ត្បានៃប្រភេទត្រីក្នុងស្រុកដែលមានសេនេទិចផ្សេងៗគ្នា។

រហូតមកដល់បច្ចុប្បន្ននេះ ការអភិវឌ្ឍវារីវប្បកម្មមានការរីកចំរើនតាមផ្នែក។ ក្នុងពេលអនាគតរដ្ឋាភិបាល និង បណ្តាភ្នាក់ងារផ្តល់ជំនួយដ៏ទៃទៀតនឹងផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតដើម្បីជំរុញវារីវប្បកម្មនៅក្នុងក្របខ័ណ្ឌអភិវឌ្ឍជនបទ។ ការយកចិត្តទុកដាក់របស់គណៈកម្មការទន្លេមេគង្គ (MRC) អំពីការអភិវឌ្ឍបរិស្ថានប្រកបដោយចីរភាពនៅក្នុងអនុតំបន់នៃអាងទន្លេមេគង្គដែលមានប្រទេសជាច្រើនផ្តល់ឱកាសធ្វើការសាកល្បងយុទ្ធសាស្ត្រជាលក្ខណៈប្រព័ន្ធក្នុងការធ្វើវារីវប្បកម្ម និង ដើម្បីជាមធ្យោបាយកាត់បន្ថយភាពក្រីក្រ។

## ៤. អនុសាសន៍ :

### ៤.១ វារីវប្បកម្មក្នុងក្របខ័ណ្ឌការងារនៃផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ

ការបែងចែកអាងទន្លេមេគង្គជាតំបន់អាងរងទឹកភ្លៀង ឬ ជាសំណុំនៃតំបន់រងទឹកភ្លៀង ដូចដែលបានស្នើសុំដោយគណៈកម្មការទន្លេមេគង្គ (MRC) ផ្តល់នូវឱកាសសំរាប់រៀបចំជាប្រព័ន្ធដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍវារីវប្បកម្មដែលមានគោលដៅជួយសំរួលដល់ប្រជាជនក្រីក្រ និង បញ្ហាអសន្តិសុខស្បៀង។ យុទ្ធសាស្ត្រគ្រប់គ្រងតំបន់រងទឹកភ្លៀង គឺជាបញ្ហាថ្មីនៅឡើយ

ដូច្នេះយុទ្ធសាស្ត្រជាជំហានៗគប្បីប្រើប្រាស់នូវរាល់បទពិសោធន៍ ដែលទទួលបានពីគ្រប់គំរោងពិសោធន៍នានា ដើម្បីពង្រីកនូវចំណេះដឹងជាបណ្តើរៗទៅរកតំបន់រងទឹកភ្លៀងដទៃទៀត។

## ៤.២ ការគាំទ្រវារីវប្បកម្មខ្នាតតូច និង សេវាកម្មអភិវឌ្ឍន៍វារីវប្បកម្ម

ការគាំទ្រដល់ការអភិវឌ្ឍន៍ពេលអនាគត គប្បីកសាងសេវាកម្មដ៏មានប្រសិទ្ធភាពដែលទ្រទ្រង់ដល់គោលបំណងវារីវប្បកម្មជាលក្ខណៈគ្រួសារ និង គ្រួសារក្រីក្រ។ យុទ្ធសាស្ត្រតម្រូវឱ្យមានការពង្រឹងសមត្ថភាពបន្ថែមទៀតក្នុងចំណោមស្ថាប័នថ្នាក់ជាតិ ខេត្ត និង មូលដ្ឋានដើម្បីលើកទឹកចិត្តដល់ការងារ ការប្រើប្រាស់រាល់យុទ្ធសាស្ត្រនៃការចូលរួមដើម្បីធ្វើការកសាងផែនការ និង ការងារផ្សព្វផ្សាយបង្កើនការយល់ដឹង និង អភិវឌ្ឍរាល់ដំណើរការនៃការកសាងផែនការជាតិ និង គោលនយោបាយដែលផ្តោតទៅលើសេចក្តីត្រូវការរបស់ប្រជាជននៅតាមជនបទ។

## ៤.៣. វិភាគយុទ្ធសាស្ត្រសេចក្តីត្រូវការក្នុងការអភិវឌ្ឍវារីវប្បកម្ម

សក្តានុពលភាពនៃវារីវប្បកម្ម គឺមានតំលៃធំធេងណាស់នៅតាមតំបន់ដាច់ស្រយាលនៃអាងទន្លេមេគង្គដែលពុំមានស្ថេរភាពនៃសុវត្ថិភាពស្បៀងអាហារ។ តំបន់ទាំងនោះរួមទាំងតំបន់ខ្ពង់រាប និង តំបន់ដទៃទៀតដែលនៅឆ្ងាយពីទន្លេមេគង្គ និង ដែននេសាទធំៗ ដូចជា បឹងទន្លេសាបកម្ពុជា។ ដើម្បីគាំទ្រការងារនេះ ការវិភាគជាយុទ្ធសាស្ត្រនៃរាល់សក្តានុពលភាពវារីវប្បកម្មក្នុងអាងទន្លេមេគង្គគប្បីត្រូវអនុវត្ត។

## ៤.៤. សហប្រតិបត្តិការស្រាវជ្រាវ

កិច្ចសហប្រតិបត្តិការស្រាវជ្រាវក្នុងតំបន់គប្បីត្រូវលើកទឹកចិត្តឱ្យមានប្រសិទ្ធភាពសេដ្ឋកិច្ចដើម្បីដោះស្រាយនូវរាល់ផលវិបាកនៃការអភិវឌ្ឍវារីវប្បកម្មដូចដែលបានបង្ហាញនៅក្នុងអត្ថបទនេះ។ កិច្ចសហប្រតិបត្តិការស្រាវជ្រាវគប្បីរួមបញ្ចូលជាចាំបាច់នូវរាល់អ្នកជំនាញវារីវប្បកម្មតាមជនបទដែលមកពីក្រុមគ្រួសារ និង មានឥទ្ធិពលនៅតាមជនបទដាច់ស្រយាល។

## ៤.៥. ការអភិវឌ្ឍគោលនយោបាយរួមនៅក្នុងអាងទន្លេមេគង្គ

បញ្ហាទាក់ទងនឹងវារីវប្បកម្មដែលកើតមានហួសពីព្រំដែននៃប្រទេសនៅក្នុងអាងទន្លេមេគង្គ មានដូចជាចរាចរឆ្លងដែននៃពពួកវារិសត្វក្នុងស្រុកមានជីវិត និង ប្រភេទវារិសត្វថ្មីមកពីបរទេស។ ពីដំបូងមានការខ្វល់ខ្វាយជាច្រើនអំពីការបាត់បង់សេនេទិច (ភាពសុទ្ធ) និង ការឆ្លងជម្ងឺរវាងប្រភេទវារិសត្វ។ កិច្ចសហប្រតិបត្តិការរវាងបណ្តាប្រទេសក្នុងតំបន់មានសារៈសំខាន់ណាស់ដើម្បីបង្កើតគោលនយោបាយ និង យុទ្ធសាស្ត្រគ្រប់គ្រងរួមដោះស្រាយរាល់បញ្ហាទាំងអស់ ដូចជាការរីកសាយកូននៃប្រភេទវារីសត្វមកពីបរទេស។ បញ្ហានេះត្រូវបានសង្ឃឹមថា គណៈកម្មការទន្លេមេគង្គនឹងបន្តគាំទ្រការងារដ៏មានតំលៃរបស់ក្រុមប្រឹក្សាបច្ចេកទេសស្តីពីការគ្រប់គ្រងជលផលនៅអាងទន្លេមេគង្គក្រោមដែលធ្វើឱ្យកាន់តែប្រសើរឡើងនូវទំនាក់ទំនង និង ដំណោះស្រាយនូវរាល់បញ្ហាការអភិវឌ្ឍរួម។

## ៤.៦. ទំនាក់ទំនង និង ភាពជាដៃគូរ

មានឱកាសជាច្រើនដើម្បីបង្កើតឡើងនូវភាពជាដៃគូរឱ្យកាន់តែមានប្រសើរឡើងថែមទៀត ក្នុងចំណោមភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗដែលកំពុងធ្វើការងារអភិវឌ្ឍន៍វារីវប្បកម្មជនបទក្នុងអាងទន្លេមេគង្គ។ កិច្ចសហប្រតិបត្តិការ និង ការរួមបទពិសោធន៍ទាំងឡាយរវាងអង្គភាពពាក់ព័ន្ធនានាតាមរយៈទំនាក់ទំនងគ្នាជាកន្សោមអាទិភាព គឺមានសារៈសំខាន់ណាស់ ប្រសិនបើមានរាល់ធនធានដើមទុន និង ធនធានបញ្ញាអាចមាន និង ប្រើប្រាស់ជាប្រយោជន៍ដ៏ល្អបំផុត។

# ស្ថានភាពវារីវប្បកម្ម នៅតំបន់អាងទន្លេមេគង្គក្រោម ១

## ១.១. ប្រវត្តិសង្ខេប

វារីវប្បកម្មគឺជាផ្នែកមួយយ៉ាងសំខាន់ដែលកំពុងមានសកម្មភាពយ៉ាងផុសផុលនៅតាមតំបន់ជនបទ ហើយសកម្មភាពទាំងនោះមានរូបភាពផ្សេងៗពីគ្នានៅតាមតំបន់អាងទន្លេមេគង្គក្រោម។ សកម្មភាពទាំងនោះរួមមានការបង្កាត់ពូជ ការភ្ញាស់ ការលក់កូនត្រីម្យ៉ៅ និង កូនត្រីពូជ រួមទាំងការចិញ្ចឹម និង ការថែបំប៉នកូនត្រីពូជដែលញាស់នៅក្នុងធម្មជាតិ ឬ ញាស់តាមលក្ខណៈសិប្បនិម្មិតនៅក្នុងប្រព័ន្ធទឹកបិទជិត ឬ ក្នុងប្រព័ន្ធទឹកបិទ បើក ដូចជាតាមស្រះ វាលស្រែ និង បែត្រី។ ជាទូទៅ ផលិតផលដែលបានមកពីការធ្វើវារីវប្បកម្មត្រូវបានគេទុកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ និង លក់ទៅទីផ្សារ។ ការចំណាយទុនសម្រាប់ចិញ្ចឹមរួមមាន កូនត្រីពូជ ចំណីការថែទាំ ការកែច្នៃ ការលក់ដូរ និងការប្រើប្រាស់ផលិតផលដែលទទួលបានពីវារីវប្បកម្មនេះ គឺជាកត្តាដ៏សំខាន់ក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតរបស់គ្រួសារនៅតាមជនបទដែលរស់នៅតាមទីកន្លែងដាច់ស្រយាលក្នុងតំបន់អាងទន្លេមេគង្គក្រោម។

វារីវប្បកម្ម និង ផលនេសាទដែលបានពីធម្មជាតិត្រូវបានគេធ្វើការបែងចែងទៅតាមសកម្មភាពដាច់ដោយឡែកពីគ្នា ប៉ុន្តែអ្វីដែលជាការពិតនោះគឺធនធានទាំងនេះមានទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធតាមរូបភាពជាច្រើន។ ឯកសារនេះបានកំណត់អត្តសញ្ញាណអំពីទំនាក់ទំនង និង ការធ្វើវិភាគអំពីតួនាទី និង សារៈសំខាន់នៃវារីវប្បកម្មនៅក្នុងបរិបទទូលំទូលាយក្នុងវិស័យជលផល និង ការអភិវឌ្ឍនៅតាមជនបទក្នុងអាងទន្លេមេគង្គក្រោម។ ព័ត៌មានស្តីពីស្ថានភាពនេសាទទឹកសាប និង នេសាទនៅតាមអាងស្តុកជលផលព្រមទាំងការធ្វើសំយោគអំពីវារីវប្បកម្មត្រូវបានបរិយាយនៅក្នុងឯកសារផ្សេងៗទៀត (Sverdrup-Jensen, 2002)។

## ១.២ ផលិតផលវារីវប្បកម្មនៅក្នុងតំបន់អាងទន្លេមេគង្គក្រោម

ជាងមួយទសវត្សរ៍កន្លងទៅនេះ មានការកើនឡើងជាលំដាប់នូវផលិតផលវារីវប្បកម្មទឹកសាបនៅតាមបណ្តាប្រទេសនៃអាងទន្លេមេគង្គក្រោមដែលមានកំណើនប្រមាណពី ៦០.០០០ តោន នៅក្នុងឆ្នាំ ១៩៩០ (គណៈកម្មាធិការបណ្តោះអាសន្នសម្រាប់ធ្វើការសម្របសម្រួល និង ឃ្លាំមើលអាងទន្លេមេគង្គក្រោម ១៩៩២) ទៅ ២៦០.០០០ តោន នៅក្នុងឆ្នាំ ១៩៩៩-២០០០។ ចំនួនទាំងនេះគឺផ្អែកលើស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល និង ការសិក្សាអំពីការប្រើប្រាស់ត្រីតាមគ្រួសារ ហើយទិន្នន័យនេះមានបង្ហាញនៅក្នុងតារាងទី ១។ បើគិតជាតម្លៃនៅកន្លែងចិញ្ចឹម ផលិតផលវារីវប្បកម្មនៅក្នុងឆ្នាំ ១៩៩៩/២០០០ មានតំលៃ ២៦៣ លានដុល្លារអាមេរិក។[១] ផលិតកម្មវារីវប្បកម្មបានចូលរួមចំណែកប្រមាណ ១២-១៣% នៃផលិតផលជលផលសរុបប្រហែល ២.០៣៦.០០០ តោន នៅក្នុងតំបន់អាងទន្លេមេគង្គក្រោមទាំងមូល។

ចំពោះនៅតំបន់ទឹកភ្លាវនៃតំបន់ដីសណ្តទន្លេមេគង្គ វារីវប្បកម្មបានរួមចំណែកប្រហែល ១៣៥.១៧៩ តោន នៃបរិមាណផលិតផលជលផលសរុបរួមទាំងបង្គាដែលមានតម្លៃខ្ពស់ប្រហែល ៧១.៥៣៦ តោន (Tran & Tran 2000)។ ទោះបីវារីវប្បកម្មទឹកភ្លាវមានសារៈសំខាន់យ៉ាងខ្លាំងចំពោះប្រជាជនវៀតណាម និង ប្រជាជនរស់នៅតាមតំបន់ដីសណ្តទន្លេមេគង្គ ដែលជាប្រភពចំណូល និង ប្រាក់កំរៃរកបានពីការនាំចេញ ប៉ុន្តែប្រព័ន្ធវារីវប្បកម្មទឹកភ្លាវ និង វារីវប្បកម្មមិនត្រូវបានអភិវឌ្ឍឱ្យបានជាប់លាប់នៅក្នុងតំបន់អាងទន្លេមេគង្គទេ។ ភាគច្រើននៃសកម្មភាពអភិវឌ្ឍន៍ប្រភេទត្រីទឹកភ្លាវមិនត្រូវបានគិតគូរពិចារណាបន្ថែមទៀតនៅក្នុងរបាយការណ៍ទាំងនេះទេ។

វារីវប្បកម្មមិនត្រូវបានអភិវឌ្ឍឱ្យបានជាប់លាប់នៅក្នុងតំបន់អាងទន្លេមេគង្គទេ ។ ភាគច្រើននៃសកម្មភាពអភិវឌ្ឍន៍វារីវប្បកម្មទាំងនេះ មានច្រើនតែនៅតាមតំបន់ដីសណ្តប្រទេសវៀតណាម និង តំបន់ខ្ពង់រាបកូរ៉ាត់ឬខ្ពង់រាបកូរ៉ាតនៅភាគឦសានប្រទេសថៃ។ ទោះបីយ៉ាងនេះក៏ដោយ ក៏មានសកម្មភាពវារីវប្បកម្មខ្លះបាននឹងកំពុងរីកផុសផុលនៅក្នុងប្រទេសកម្ពុជា និងនៅតំបន់ទំនាបកណ្តាល និង តំបន់ខ្ពង់រាបនៃប្រទេសឡាវ។ ប៉ុន្តែផលិតផលដែលទទួលបានមានបរិមាណតិច និង មានតម្លៃទាប។ ស្ថិតិវារីវប្បកម្មជាលក្ខណៈគ្រួសារប្រហែលជាត្រូវបានគេរាយការណ៍នៅទាបក្នុងរបាយការណ៍ជាផ្លូវការរបស់រាជរដ្ឋាភិបាល ដែលតាមជាក់ស្តែងមានសកម្មភាពចិញ្ចឹមច្រើននៅតាមជនបទ។

---

១ រួមបញ្ចូលទាំងការប៉ាន់ប្រមាណបន្ថែមអំពីតម្លៃនៃវារីវប្បកម្មជាលក្ខណៈគ្រួសារពីភាគឦសានប្រទេសថៃ

តារាងទី១- **ផលិតផលវារីវប្បកម្មទឹកសាបនៅក្នុងតំបន់ទន្លេមេគង្គក្រោមផ្អែកលើទិន្នន័យឆ្នាំ ១៩៩៨-២០០០)**

| ប្រទេស | ចំនួនប៉ាន់ប្រមាណសរុបនៃគ្រួសារនៅជនបទ | ភាគរយនៃគ្រួសារនៅជនបទដែលធ្វើវារីវប្បកម្ម | បរិមាណផលិតផលវារីវប្បកម្មទឹកសាបប្រចាំឆ្នាំប៉ាន់ប្រមាណ តោន) | តំលៃប៉ាន់ប្រមាណ (US$)[១] |
|---|---|---|---|---|
| ប្រទេសថៃ | ២.៦ លាន | ប្រហែល ៧ | ៣៨.១១៥[២]+ ៣០.០០០[៣] | ២០.៤០០.០០០[៤] |
| ប្រទេសឡាវ | ៦៦៧.៩០០ | ៨.៣[៥] | ៥.៣៧៨[៦] | ៧.០០០.០០០ |
| ប្រទេសកម្ពុជា | គ្មាន | គ្មាន | ១៤.១០០[៧] | ១៧.២០០.០០០ |
| ប្រទេសវៀតណាម | ២.៦៧៥.៩០០[៨] | គ្មាន | ១៧១.៥៧០[៩] | ២០០.០០០.០០០ |
| **សរុបៈ** | | | **២៥៩.១៦៣** | **២៤៤.៦០០.០០០** |

**កំណត់សំគាល់ :**

១ គឺតម្លៃគិតជាប្រាក់តាមទ្រឹស្តីនៃតំលៃផលិតផល និង មិនគិតអំពីចំណូល ឬ ចំណាយជាក់ស្តែងទៅលើធនធានវារីជាតទេ។

២ ស្ថិតិផលិតផលជលផលជាផ្លូវការនៃនាយកដ្ឋានជលផល ១៩៩៨ នៅភាគឦសានប្រទេសថៃ (DoF 2001)

៣ របាយការណ៍ក្រៅផ្លូវការដែលបានប៉ាន់ប្រមាណផលវារីវប្បកម្មជាលក្ខណៈគ្រួសារ

៤ ការប៉ាន់ប្រមាណពីទិន្នន័យនៅឆ្នាំ ១៩៩៧ របស់នាយកដ្ឋានជលផលថៃ ស្តីពីតម្លៃត្រីទឹកសាបគិតជាមធ្យម គឺ ២៧ បាតក្នុង ១ គីឡូក្រាម និង តួលេខផលិតផលប្រចាំឆ្នាំ ១៩៩៧ និង អត្រាប្តូរប្រាក់ ១ ដុល្លារ = ៤៥ បាត

៥ ជំរឿនផលិតផលកសិកម្មរបស់ប្រទេសឡាវ ,១៩៩៨/៩៩។ គណៈកម្មាធិការដឹកនាំធ្វើជំរឿនកសិកម្មនៅទីក្រុងវៀងច័ន្ទ ខែកុម្ភៈ ឆ្នាំ ២០០០

៦ ការប៉ាន់ប្រមាណពីផលិតផលតាមស្រះតាមរយៈទំហំផ្ទៃស្រះដែលប៉ាន់ប្រមាណ x បរិមាណផលមធ្យម ៨០០ គ.ក/ហិកតាផ្ទៃក្រឡាចិញ្ចឹមត្រីតាមស្រែ x បរិមាណ ១២០ គ.ក/ហិកតា

៧ តួលេខផ្លូវការរបស់នាយកដ្ឋានជលផល ឆ្នាំ ១៩៩៨ (មានបញ្ចូលទាំងតម្លៃ)

៨ តួលេខឆ្នាំ ១៩៩៩ របស់អង្គការ READ ដោយផ្អែកទៅលើស្ថិតិប្រជាជននៅ ១២ ខេត្ត នៃតំបន់ដីសណ្តរប្រទេសវៀតណាម ដែលមានប្រមាណ ១៣.៣៨ លាន ក្នុងឆ្នាំ ១៩៩៩ ហើយមានសមាជិកជាមធ្យម ៥ នាក់/គ្រួសារ

៩ តួលេខផលិតផលជលផលមិនរាប់បញ្ចូលបរិមាណផលបង្គា។ យោងតាមទិន្នន័យរបស់ក្រសួងជលផលវៀតណាម គឺប្រមាណ ៧១.៥៣៦ តោន នៅឆ្នាំ ២០០១

## ១.៣ អ្នកផលិត និង តួនាទីរបស់វារីវប្បកម្មនៅក្នុងសន្តិសុខស្បៀង និង ជីវភាពរស់នៅរបស់ប្រជាជន

កសិដ្ឋានវារីវប្បកម្មទ្រង់ទ្រាយធំមួយចំនួននៅក្នុងតំបន់អាងទន្លេមេគង្គ ដូចជា ការចិញ្ចឹមត្រីតាមបែដែលភាគច្រើនចិញ្ចឹមពពួកត្រីប្រានៅតាមដងទន្លេបាសាក់ និង ដីសណ្តទន្លេមេគង្គ។ កសិដ្ឋានចិញ្ចឹមត្រីចំរុះដ៏ធំមួយនៅក្បែរភាគឦសាន ប្រទេសថៃ។ ទោះបីជាយ៉ាងនេះក៏ដោយក៏ភាគច្រើននៃផលវារីវប្បកម្មបានមកពីវារីវប្បកម្មជាលក្ខណៈគ្រួសារនៅតាមជនបទ។ ជាក់ស្តែងក៏រិតគ្រួសាររបស់ប្រជាជននៅតាមជនបទ ជាពិសេស នៅតំបន់ក្រីក្រ និង តំបន់ដែលខ្សត់ត្រី ហើយនៅឆ្ងាយពីដែនទេសាទ វារីវប្បកម្មមានសារៈសំខាន់ជាងអ្នករស់នៅក្នុងតំបន់អាងទន្លេមេគង្គ។ ប៉ុន្តែបរិមាណជាក់លាក់មិនអាចរកបានពីស្ថិតិជាផ្លូវការឡើយ។ ឧទាហរណ៍ នៅភាគឦសានប្រទេសថៃ គ្រួសារប្រមាណពី ១៧០.០០០ ទៅ ២០០.០០០ ឬ ស្មើ ៦,៥-៧,៦ % នៃចំនួនប្រជាជនតាមជនបទសរុប ២.៦ លានគ្រួសារ បានចូលរួមក្នុងសកម្មភាពវារីវប្បកម្មជាលក្ខណៈគ្រួសារ។ រីឯនៅប្រទេសឡាវវិញ ទោះបីផលិតផលវារីវប្បកម្មប្រចាំឆ្នាំមានប្រហែល ៥.០០០ តោន ដែលបរិមាណនេះជាបរិមាណមួយទាបជាងចំនួនគ្រួសារនៅតាមជនបទ

ដែលមានចំនួន ៩៥.២០០ គ្រួសារ ស្មើនឹង ៨.៣ ភាគរយនៃចំនួនគ្រួសារនៅតាមជនបទសរុប ប្រកបរបរវារីវប្បកម្មតាមគ្រប់ទ្រង់ទ្រាយ ។ នេះបញ្ជាក់ឱ្យឃើញថា វារីវប្បកម្មនៅប្រទេសឡាវពិតជាមានតួនាទីសំខាន់ក្នុងការជួយបំបាត់ភាពក្រីក្រ ។

នៅរដូវខ្សត់ត្រី វារីវប្បកម្មជាលក្ខណៈគ្រួសារបានជួយផ្គត់ផ្គង់ជាចំណីអាហារដល់អ្នករស់នៅក្នុងតំបន់អាងទន្លេមេគង្គដែលមានឱកាសចាប់ត្រីបានតិចតួច ។ ក្រៅពីនេះវារីវប្បកម្មបានផ្តល់ឱ្យកសិករដែលប្រកបរបរកសិកម្មមានឱកាសរកប្រាក់ចំណូលបន្ថែមទៀត។ វារីវប្បកម្មបានផ្តល់ស្បៀង និង ឱកាសរកចំណូលហើយមានភាពប្រថុយនឹងការបង់ខាតទាប។ ត្រីចិញ្ចឹម និង ប្រភេទវារិសត្វចិញ្ចឹមផ្សេងៗទៀត មិនត្រឹមតែលក់ទាំងរស់នៅតាមភូមិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានារក្សាភាពស្រស់ និង មានរស់ជាតិឆ្ងាញ់ទៀតផង។ នៅតាមតំបន់ជនបទដែលគ្មានភ្លើងអគ្គិសនី និង ទឹកកក មានលទ្ធភាពលក់ត្រីទាំងរស់ ហើយទទួលបានប្រយោជន៍ពីទីផ្សារយ៉ាងច្រើនពីត្រីដែលគេចាប់បានពីធម្មជាតិបន្ទាប់ពីចាប់បានពីក្នុងទឹករួចយកមកប្រោះទុក១រយៈពេលនោះ។

វារីវប្បកម្មក៏បានរួមចំណែកក្នុងការជួយផ្តល់បន្ថែមនូវសារធាតុចិញ្ចឹម ។ អាហាររបស់ប្រជាជននៅតាមជនបទនៃតំបន់អាងទន្លេមេគង្គភាគច្រើនសំបូរដោយសារធាតុកាបូនអ៊ីដ្រាត និង សារធាតុប្រូតេអ៊ីនដ៏សំខាន់។ ទោះជាយ៉ាងនេះក្តី អាហារកាបូនអ៊ីដ្រាតទាំងនេះ ពុំមានសំបូរគ្រប់គ្រាន់នូវពពួកអាមីណូអាស៊ីត និង លីស៊ីនទេ។ ប៉ុន្តែត្រីជាប្រភពដែលមានសំបូរទៅដោយលីស៊ីន។

វារីវប្បកម្មគឺជាប្រភពផ្តល់នូវប្រាក់ចំណូល និង ស្បៀងអាហារចំពោះគ្រួសារនៅតាមជនបទ។ ការចំណាយដើមទុនជាប្រាក់កាក់ប្រហែលជាត្រូវការខ្លះសម្រាប់ចំណាយលើការទិញកូនត្រីពូជមកចិញ្ចឹម។ ដូចនេះប្រាក់ចំណូលដែលរកបានពីប្រភពផ្សេង គឺជាប្រការដ៏សំខាន់ ដូចជា ប្រាក់ដែលបានមកពីការលក់ត្រីដែលចិញ្ចឹមបាន ឬ ការលក់កសិផល។ គ្រួសារក្រីក្រ គ្រួសារដែលធ្វើវារីវប្បកម្មតែងតែបរិភោគត្រី ហើយអាចមិនសម្លាប់សត្វផ្សេងៗទៀតសម្រាប់បង្កើនប្រាក់ចំណូលគ្រួសារ (ដូចជា មាន់ និង ជ្រូកជាដើម)។ នៅប្រទេសឡាវ យោងតាមបទពិសោធន៍របស់អង្គការស្បៀងអាហារពិភពលោកបានបង្ហាញថា ភាគច្រើននៃកសិករធ្វើការចិញ្ចឹមត្រីដើម្បីបំពេញតម្រូវការត្រីសាច់នៅក្នុងគ្រួសារ និង បង្កើនប្រាក់ចំណូលក្នុងគ្រួសារនៅពេលដែលត្រីចិញ្ចឹមមានលើសពីតម្រូវការនៅក្នុងគ្រួសារ (Funge-Smith 1999a)។ ជាទូទៅ អ្នកដែលមានស្រះស្រាប់សំរាប់ចិញ្ចឹមត្រីផ្គត់ផ្គង់សន្តិសុខស្បៀង ចំណាយកំលាំងពលកម្មតិចតួចប៉ុណ្ណោះ។ ដូចនេះ សកម្មភាពនេះមិនត្រឹមតែធ្វើឱ្យវារីវប្បកម្មក្លាយជាសកម្មភាពដ៏សំខាន់សម្រាប់តំបន់អាងទន្លេមេគង្គប៉ុណ្ណោះទេ ប៉ុន្តែមានចំនួនគ្រួសារជាច្រើនចូលរួមក្នុងផលិតកម្មវារីវប្បកម្មទៀតផង។

ប្រជាជនដែលចូលរួមក្នុងសកម្មភាពវារីវប្បកម្មមានវិសាលភាពធំធេង ដោយភាគច្រើនជាអ្នកដែលមានចំណូលទាប និងក្រីក្រ ប៉ុន្តែក៏មានអ្នកដែលមានទ្រព្យច្រើនធ្វើការវិនិយោគវារីវប្បកម្មនេះផងដែរ។ ចំពោះអ្នកដែលមានទ្រព្យធនច្រើនវារីវប្បកម្មអាចផ្តល់ប្រាក់ចំណេញជាច្រើន ឧទាហរណ៍ ដូចជាការចិញ្ចឹមត្រីតាមបែនៅប្រទេសវៀតណាម។ ប្រជាជននៅក្នុងតំបន់អាងទន្លេមេគង្គក៏បានចូលរួមក្នុងសកម្មភាពវារីវប្បកម្មដែរ ដូចជាការផ្គត់ផ្គង់ពូជ ចំណី និងសកម្មភាពប្រមូលផល។ ឧទាហរណ៍រោងចក្រនៅតំបន់ដីសណ្តទន្លេមេគង្គធ្វើការកែច្នៃសាច់ត្រីសម្រាប់នាំចេញ ហើយបានផ្តល់ការងារយ៉ាងច្រើនដល់ស្ត្រី។

ទោះជាយ៉ាងនេះក្តី ទ្រព្យធនខ្លះទាមទារឱ្យមានការវិនិយោគនៅក្នុងផលិតកម្មវារីវប្បកម្ម អ្នកក្រដែលគ្មានដីពួកគេអាចចូលរួម និងទាញយកចំណូលបានតាមរយៈការប្រើប្រាស់កម្លាំងពលកម្ម។ ឧទាហរណ៍ ដូចជានៅប្រទេសឡាវ អ្នកក្រីក្រដែលគ្មានដីសម្រាប់ជីកស្រះចិញ្ចឹមត្រី ពួកគេចូលរួមក្នុងបណ្តាញថែបំប៉នត្រីដោយទទួលបានជោគជ័យប្រកបដោយចីរភាព (Lithdamlong etal.2002)។

មកដល់បច្ចុប្បន្ននេះ យុទ្ធវិធីក្នុងការអភិវឌ្ឍវារីវប្បកម្មបានបង្កើនផលិតភាពវារីវប្បកម្ម ប៉ុន្តែផលិតកម្ម និងបច្ចេកវិទ្យានេះមិនទាន់បានផ្តោតការយកចិត្តទុកដាក់ចំពោះប្រជាជនក្រីក្រនៅឡើយទេ។ ក្នុងករណីខ្លះ យុទ្ធសាស្ត្រខ្លះអាចធ្វើឱ្យមានផលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាជនក្រីក្រទៀតផង (Haylor2001)។ គម្រោងនៅក្នុងប្រទេសឡាវ និងប្រទេសកម្ពុជា កាលពីប៉ុន្មានឆ្នាំមុនបានបង្ហាញថា ការផ្តោតការយកចិត្តទុកដាក់ចំពោះក្រុមអ្នកក្រីក្រអាចជួយជាវិភាគទានដ៏សំខាន់ដល់ការលើកកំពស់ជីវភាពរស់នៅរបស់គ្រួសារក្រីក្រនៅតាមជនបទ។ ជាធម្មតា អ្នកនៅតាមជនបទត្រៀមជាស្រេចក្នុងការចូលរួមចិញ្ចឹមត្រី ទោះបីមានផលវិបាកក្នុងការផ្គត់ផ្គង់កូនត្រីពូជសម្រាប់ចិញ្ចឹមក៏ដោយ ។

ស្ត្រី បុរស និងក្មេងៗភាគច្រើនតែងតែបានពាក់ព័ន្ធនៅក្នុងសកម្មភាពវារីវប្បកម្មជាលក្ខណៈគ្រួសារ ហើយពួកគេមានតួនាទីផ្សេងៗពីគ្នា។ នៅតំបន់អាងទន្លេមេគង្គមានផលវិបាកបញ្ហាវប្បធម៌ខ្លះៗដោយបានបង្កការលំបាកចំពោះស្ត្រីដើម្បីរួមចំណែកក្នុងសកម្មភាពវារីវប្បកម្ម។ ឧទាហរណ៍ នៅប្រទេសវៀតណាម ស្ត្រីបានចូលរួមយ៉ាងសកម្មក្នុងការផ្តល់ចំណី ការដាក់ជី ជាពិសេសស្ត្រីបានចូលរួមក្នុងការងារប្រមូលផល និងលក់ដូរត្រីនៅទីផ្សារផងដែរ។ ចំណែកនៅប្រទេសឡាវវិញ ស្ត្រីភាគច្រើនជាអ្នកលក់ដូរ (Funge-

Smith 1999a)។ លើសពីនេះ បទពិសោធន៍នៃគម្រោងផ្សព្វផ្សាយវារីវប្បកម្ម (READ) នៅតាមតំបន់ជនបទរបស់គណៈកម្មការទន្លេមេគង្គ (MRC) បានឱ្យដឹងថា ស្ត្រីមានតួនាទីធំធេងបន្ថែមទៀតនៅក្នុងគ្រួសារក្រីក្រ ដែលបុរសតែងតែចេញឆ្ងាយពីផ្ទះដើម្បីទៅស្វែងរកការងារធ្វើតាមរដូវកាល ឬប្រចាំថ្ងៃ។ នៅតំបន់ខ្លះ កន្លែងវារីវប្បកម្មនៅឆ្ងាយពីផ្ទះធ្វើឱ្យមានផលវិបាកខ្លះៗ ហើយការបំពេញការងារផ្ទះអាចបណ្ដាលឱ្យមានជម្លោះក្នុងការផ្ដល់ចំណី និងការគ្រប់គ្រងត្រី។ ប៉ុន្តែជាទូទៅ ស្ត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងវារីវប្បកម្មជាលក្ខណៈគ្រួសារនៅតំបន់អាងទន្លេមេគង្គ។

## ១.៤ ប្រព័ន្ធវារីវប្បកម្ម និង ប្រភេទត្រីដាក់ចិញ្ចឹម

ការចិញ្ចឹមត្រីនៅក្នុងតំបន់អាងទន្លេមេគង្គបានអនុវត្តនៅតាមស្រះ និងតាមវាលស្រែ (តារាងទី ២)ជាទូទៅ វាជាផ្នែកមួយនៃប្រព័ន្ធកសិដ្ឋានកសិកម្មតាមវាលស្រែ។ ប៉ុន្តែមានភាពខុសគ្នាដាច់ដោយឡែករវាងការចិញ្ចឹមត្រីនៅទូទាំងតំបន់អាងទន្លេមេគង្គរវាងតំបន់នៅជុំវិញទីក្រុង និងតំបន់ជនបទ។ តំបន់នៅជុំវិញទីក្រុងងាយស្រួលរកផលិតផលកសិកម្មធ្វើជាចំណី ជាពិសេសសំបូរផលិតកម្មវិបុលវប្បកម្មចិញ្ចឹមសត្វក្នុងស្រុក (ជាពិសេសការចិញ្ចឹមជ្រូក និងមាន់) ផលិតកម្មទាំងនេះ ជាប្រភពផ្ដល់កាកសំណល់ដែលអាចប្រើប្រាស់សម្រាប់ចំណីត្រី។ ព័ត៌មានពីបច្ចេកទេស និងពូជត្រីអាចរកបានយ៉ាងងាយ និងមានស្រាប់ដោយសារមានស្ថានីយ៍ជលផលរដ្ឋនៅជិត និងមានលទ្ធភាពផ្ដល់កូនត្រីពូជបាន។ នៅប្រទេសថៃ និងតំបន់ដីសណ្ដទន្លេមេគង្គនៃ ប្រទេសវៀតណាមមានប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធល្អ បានជួយសម្រួលឱ្យអ្នកចិញ្ចឹមងាយស្រួលទទួលការផ្គត់ផ្គង់ ងាយរកទីផ្សារ និងព័ត៌មានផ្សេងៗជាងវារីវប្បករនៅតាមតំបន់ជនបទដាច់ស្រយាលនៃប្រទេសកម្ពុជា និងប្រទេសឡាវ។

មានចំនួនកសិដ្ឋានចិញ្ចឹមត្រី និងដីធ្លីជាច្រើនដែលបានប្រើសម្រាប់សកម្មភាពវារីវប្បកម្មបានរីកចំរើនលូតលាស់តាំងពីជាង ១០ ឆ្នាំមុនមកម្ល៉េះ។ នៅភាគឦសានប្រទេសថៃមានប្រើឧបករណ៍សម្រាប់ជីកស្រះតាំងពីឆ្នាំ ១៩៩៧ នេះក៏ជាកត្តាមួយមានឥទ្ធិពលលើវិបត្តិសេដ្ឋកិច្ចរបស់ប្រទេសថៃផងដែរ ហើយតាមរយៈនេះ រាល់គម្រោង និងគោលការណ៍រក្សាសន្តិសុខស្បៀង និងប្រសិទ្ធភាពស្វ័យភាពដែលត្រូវបានជំរុញដោយព្រះមហាក្សត្រថៃ។ នៅក្នុងប្រទេសកម្ពុជា ស្រះរបស់កសិករជាច្រើនត្រូវបានអង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារផ្ដល់ជំនួយមួយចំនួនជួយជាង១០ឆ្នាំមកហើយ។ ទោះជាយ៉ាងនេះក៏ដោយ មានស្រះមួយចំនួនប៉ុណ្ណោះដែលបានបម្រើឱ្យសកម្មភាពវារីវប្បកម្ម ហើយនៅមានផលិតភាពទាបនៅឡើយ។ ស្ថិតិដែលមានស្ដីពីចំនួនកសិដ្ឋាន និងដីធ្លីមានសង្ខេបបង្ហាញនៅក្នុងតារាងទី ២ ហើយការប៉ាន់ប្រមាណនៅមានកំរិតទាបដោយសកម្មភាពវារីវប្បកម្មគ្រួសារមានរបាយនៅគ្រប់ទីកន្លែងនៃតំបន់ជនបទនៅក្នុងអាងទន្លេមេគង្គ។

**តារាងទី ២ តំបន់ផលិតកម្មវារីវប្បកម្ម និងផលិតកម្មកូនត្រីពូជនៅក្នុងតំបន់ទន្លេមេគង្គក្រោម ផ្អែកលើស្ថិតិឆ្នាំ ១៩៩៨-២០០០**

| ប្រទេស | ស្រះ (ហ.ត) | បែរ/សិង (ហ.ត) | ចិញ្ចឹមតាមស្រែ (ហ.ត) | ចំនួនកូនត្រីពូជប៉ាន់ប្រមាណ (ក្បាល) |
|---|---|---|---|---|
| ថៃ[1] | ២៥.៨៦២ | ៨.៥៦ | ៦.៥១៩ | ១៥០.៦ លាន[2] |
| ឡាវ | ៥.១៥០[3] | គ្មាន | ១.៨៥៦[4] | <១៥លាន[5] |
| កម្ពុជា | ៣១៥ | ១៤.២៥ (៣.៥៦១ បែរ. ៩.៨៧០ តោន) | គ្មាន | ៧.១ លាន ក្នុងឆ្នាំ ១៩៩៩ ការប៉ាន់ប្រមាណ >១០ លាន ក្នុងឆ្នាំ ២០០០[6] |
| វៀតណាម[7] | ៥១.២៦៤ | ៣៩ | ៧៩.៧៥០ | ៥៥៥ លាន |

**កំណត់សំគាល់ :**

១ ភាគល្បីសានប្រទេសថៃ។ ស្ថិតិផ្លូវការនាយកដ្ឋានជលផលឆ្នាំ ១៩៩៨ មិនរួមបញ្ចូលផ្ទៃ ៣០ ហិកតានៃការចិញ្ចឹមតាមប្រឡាយ។

២ ទំនាក់ទំនងផ្ទាល់ពីបណ្ឌិត ខាំចៃឡូវំងយ៉ាវុង ដោយផ្អែកលើការប៉ាន់ប្រមាណរបស់នាយកដ្ឋានជលផលអំពីផលិតកម្ម ៣៨.១១៤.៧៥០ គ.ក្រ ត្រី និង ១ គ.ក្រ ត្រីត្រូវការកូនត្រីពូជ ៥ ក្បាល (ក្នុងឆ្នាំ ១៩៩៨) (នាយកដ្ឋានជលផល ២០០១)។

៣ ការប៉ាន់ប្រមាណ ៥១.៥០០ គ្រួសារ X ទំហំស្រះជាមធ្យម ០.១ ហ.ត

៤ ការប៉ាន់ប្រមាណ ៦.៣២០ គ្រួសារ X ទំហំស្រះជាមធ្យម ០.៣ ហ.ត

៥ ការប៉ាន់ប្រមាណរបស់រដ្ឋាភិបាលឆ្នាំ ១៩៩៧ ប៉ុន្តែប្រហែលជាតិចជាង

៦ So Nam & Nao Thuok (1999)

៧ Tran Thanh Xuan et al. 2000

> **ប្រអប់១ : កត្តាដែលជះឥទ្ធិពលលើការអភិវឌ្ឍវារីវប្បកម្មជាលក្ខណៈគ្រួសារ**
>
> - ការផ្គត់ផ្គង់ត្រីធម្មជាតិ រួមទាំងបម្រែបម្រួលតាមរដូវកាល និងឆ្នាំ
> - មានប្រភពធនធាន ដូចជាប្រភពទឹក កូនត្រីពូជ ចំណី ប្រភពជីបង្កើតចំណីធម្មជាតិ និងទីតាំងសមស្រប
> - តម្រូវការពីទីផ្សារនៅតាមមូលដ្ឋាន ជាពិសេសតំបន់នៅតាមជនបទដាច់ស្រយាល
> - មានការជួយគាំពារជាសេវាកម្មផលទានព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធ

វារីវប្បកម្មនៅតំបន់អាងទន្លេមេគង្គបានឆ្លើយតបនូវរាល់តម្រូវការនៃផលិតផលវារីជាតនៅតាមគ្រួសារទាំងនៅតាមមូលដ្ឋាន និងទីក្រុង ជាពិសេសតម្រូវការសម្រាប់ការនាំចេញនូវប្រភេទខ្លះ ដូចជាប្រភេទត្រីប្រា និងបង្កងទឹកសាបជាដើម។ នៅតំបន់ដីសណ្តទន្លេមេគង្គ ការចិញ្ចឹមត្រីប្រាតាមបែបនាវីកចំរើនយ៉ាងរហ័សនៅប៉ុន្មានឆ្នាំថ្មីៗនេះដោយសារការកើនឡើងនៃការនាំចេញទៅទីផ្សារអន្តរជាតិ វារីវប្បកម្មមានសក្តានុពលភាពខ្ពស់នៅទីកន្លែងណាដែលមានប្រភពទឹក និងខ្វះខាតសន្តិសុខស្បៀង និងនៅតំបន់ណាដែលត្រីធម្មជាតិមិនអាចឆ្លើយតបតាមតម្រូវការប្រើប្រាស់តាមរដូវកាល និងពេញមួយឆ្នាំ។ កត្តាសំខាន់ដែលកំពុងជះឥទ្ធិពលលើការអភិវឌ្ឍវារីវប្បកម្មរួមទាំងហេដ្ឋារចនាសម្ព័ន្ធនានា ដូចជាភាពងាយស្រួលទៅកាន់ទីផ្សារ ការផ្គត់ផ្គង់ធនធាន ជាពិសេសប្រភពត្រីពូជ សេវាផ្សព្វផ្សាយ និងសេវាទ្រទ្រង់ផ្សេងៗទៀត។ ឧទាហរណ៍ នៅប្រទេសឡាវ កត្តាសេដ្ឋកិច្ចមួយចំនួន ដូចជាសេដ្ឋកិច្ចទីផ្សារអភិវឌ្ឍនៅកំរិតទាបនៅតាមតំបន់ក្រៅក្រុង ស្ថានភាពផ្លូវមិនល្អ សេដ្ឋកិច្ចជនបទមួយភាគធំគ្រាន់តែបំពេញតម្រូវការជីវភាពរស់នៅ និងការទទួលសេវាផលទានរយៈពេលវែងមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវារីវប្បកម្ម។

មានត្រី និងបង្កងជាង ៣០ ប្រភេទដែលបានចិញ្ចឹមនៅក្នុងអាងទន្លេមេគង្គក្រោម នៃប្រទេសវៀតណាម ហើយពូជដែលដាក់ចិញ្ចឹមទាំងនេះ គឺមានពូជក្រៅស្រុកផង និងពូជក្នុងស្រុកផងដែលត្រូវបានគេប្រមូលយកមកពីធម្មជាតិ។ ជារួមប្រព័ន្ធទន្លេ មេគង្គ និងប្រភេទវារីជាតពិពណ៌នានៅខាងក្រោមដោយធ្វើការបែងចែកទៅតាមតំបន់ទាំងនេះ គឺដើម្បីបង្ហាញឱ្យឃើញពីប្រភេទផ្សេងៗគ្នាដែលមាននៅក្នុងតំបន់ទំនាបដីសណ្តនៃប្រទេសវៀតណាម និងកម្ពុជានៅតំបន់ទំនាបកណ្តាលប៉ែកអាគ្នេយ៍នៃប្រទេសថៃ និងប្រទេសឡាវ និងតំបន់ខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាម។ ឯកសារយោងបន្ថែមដែលពាក់ព័ន្ធជាមួយបញ្ហានេះនឹងត្រូវបានផ្តល់ជូនដល់មិត្តអ្នកអានដែលស្វែងរកព័ត៌មានបន្ថែម។

## ១.៤.១. តំបន់ដីសណ្តមេគង្គប្រទេសវៀតណាម

តំបន់ដីសណ្តមេគង្គនៅវៀតណាមមានតំបន់វារីវប្បកម្មធំជាងគេដោយគ្របដណ្តប់លើផ្ទៃដី ៣២៩.២២៥ ហិកតានៅក្នុងអាងទឹករបស់ខ្លួន។ ផលិតផលសរុបដែលទទួលបាន (ផលិតផលទឹកសាបទឹកភ្លាវ និងផលិតផលសមុទ្រ) នៅឆ្នាំ១៩៩៩គឺ ២៩១.៤៩៧ តោន គិតទឹកប្រាក់ប្រមាណ ៣០៥ លានដុល្លារអាមេរិក (Tran and Tran 2000) ។ក្នុងចំណោមផលិតផលទាំងនេះផលិតផលដែលទទួលបានដោយវារីវប្បកម្មគឺមានប្រមាណ១៧១.៥៧០តោន ដែលក្នុងនោះបានមកពីការចិញ្ចឹមតាមស្រះចំនួន ៨០.៥៨០ តោន តាមបែចំនួន ៥៨.៤១០ តោន ការចិញ្ចឹមត្រីចំរុះ ២៩.៨៤០ តោន និង បង្កង ២.៣៤០ តោន។ នៅឆ្នាំ១៩៩៩ តំបន់ដីសណ្តមេគង្គប្រទេសវៀតណាមអាចចិញ្ចឹមក្នុងស្រះមានប្រមាណ ៥១.២៤៦ ហិកតា ប៉ុន្តែក្នុងនោះ ផ្ទៃដីត្រឹម ១៦.៨៧៧ ហិកតា ស្មើនឹង ៣៣ ភាគរយប៉ុណ្ណោះដែលគេចិញ្ចឹម។

ផលិតផលក្នុងមួយឯកត្តានៃផ្ទៃទឹកទទួលបានផលខ្ពស់ ដែលជាទូទៅអាចបានផលជាមធ្យមប្រមាណ ៤.៨ តោន/ហិកតា។ ក្រឡាផ្ទៃស្រះជាទូទៅមានទំហំពី ១០០-៥០០ ម$^{២}$ នេះជាទំហំមួយបានមកពីការជីកដី ដើម្បីលើកដីឱ្យខ្ពស់ ឬ សង់ផ្ទះ។ នៅឆ្នាំ ១៩៩៩ ផ្ទៃដីត្រឹម ១១១ ហិកតា នៃតំបន់ដីសណ្តប្រទេសវៀតណាមអាចផលិតបានកូនត្រីម៉េ្យាប្រហែល ១.៦១៥ លាន និងកូនត្រីពូជប្រមាណ ៥៩៥ លានក្បាល។ កូនត្រីពូជទាំងនោះមានត្រីឆ្ពិន ត្រីកាប កាបឥណ្ឌា ទីឡាព្យ៉ា និងប្រភេទត្រីអណ្តែង និងត្រីប្រា ដែលជាប្រភេទត្រីពូជផលិតបានច្រើនជាងគេ។ ដោយមានការគាំទ្រពីគម្រោងផ្សព្វផ្សាយអភិវឌ្ឍន៍វារីវប្បកម្មរបស់គណៈ កម្មការទន្លេមេគង្គ (READ/MRC) ដែលគម្រោងនេះបង្កើននូវចំនួនអាងភ្ញាស់ពូជត្រីសម្រាប់ប្រភេទត្រីមួយចំនួន ដូចជា ត្រីកន្ធរ kissing, giant gouram និងត្រីក្រាញ់។ ការចិញ្ចឹមតាមបែត្រូវបានគេជួបប្រទះនៅតាមដងទន្លេដែលភាគច្រើន មាននៅតំបន់ចៅដុក ខេត្តអាងយ៉ាង និងមានចំនួនតិចតួចនៅតំបន់ឡុងសៀន ។

ប្រភេទត្រីដែលគេនិយមចិញ្ចឹមតាមស្រះនៅក្នុងតំបន់ដីសណ្តមេគង្គគឺមានប្រភេទត្រីប្រា ត្រីឆ្ពិន ត្រីកាបសាមញ្ញ ត្រីទីឡាព្យ៉ា (*ភាគច្រើនប្រភេទO. niloticus និង O. mossambicus*) ត្រីដីរ ត្រីអណ្តែងកូនកាត់ (*Clarias macrocephalus.*) ត្រីកាបស ត្រីកាបឥណ្ឌា និងត្រីរស់។ ការចិញ្ចឹមតាមបែបចំរុះ គឺអាស្រ័យលើបទដ្ឋាននៃការចិញ្ចឹម និងបរិមាណចំនួនស្តុក វាតែងតែខុសគ្នាទៅតាមលទ្ធភាពដែលមាន ដូចជាផ្គត់ផ្គង់ចំណី គុណភាពទឹកល្អ និងតម្លៃលើទីផ្សារ។ការចិញ្ចឹមត្រីតាមស្រះនៅក្នុងតំបន់ដីសណ្តមេគង្គជាទូទៅបានចិញ្ចឹមតាមលក្ខណៈចំរុះទៅតាមប្រព័ន្ធ VAC ដែលជាពាក្យកាត់របស់វៀតណាម គឺទាក់ទងដល់ការងារ " ចិញ្ចឹមសត្វ និងដំណាំបន្លែ " ។ ការប្រើប្រាស់ដ៏ទូលំទូលាយលើអនុផលកសិកម្ម និងជលផល ដោយសារគេមានការយល់ដឹងខ្ពស់ ហើយក៏មានមនុស្សមួយចំនួនបានបំផ្លាញចោលនូវកាកសំណល់ដែលមានក្នុងបង្គន់ ហើយម៉្យាងវិញទៀត ដោយសារកំលាំងពលកម្មថោកផង នោះបានធ្វើឱ្យតម្លៃត្រីមួយចំនួនចុះថោក។ គម្រោង READ/MRCបានធ្វើការប៉ាន់ប្រមាណថា ២៤០.០០០ តោន នៃចំណីដែលបង្កើតឡើងដោយកសិដ្ឋានត្រូវបានគេប្រើប្រាស់ជាប្រចាំឆ្នាំនៅក្នុងតំបន់ដីសណ្តទន្លេមេគង្គ ហើយតាំងពីមុនមកក៏មានការប្រើប្រាស់តិចតួចផងដែរនូវប្រភេទចំណីគ្រាប់។ មូលហេតុនេះហើយដែលបានធ្វើឱ្យប្រទេសវៀតណាមមានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងការផលិតចំណីសម្រាប់ត្រីនៅតាមកសិដ្ឋាន។

ក្នុងតំបន់ដីសណ្តមេគង្គត្រូវបានគេប៉ាន់ស្មានថាមានផ្ទៃដីប្រមាណ ២០៩.៦៧០ ហិកតា ដែលក្នុងនោះមានផ្ទៃដីប្រហែល ៧៩.៧៥០ ហិកតា ជាតំបន់មានសក្តានុពល។ បច្ចុប្បន្ននេះត្រូវបានគេធ្វើការចិញ្ចឹមត្រីលាយជាមួយដំណាំស្រូវ។ ជាទូទៅការអនុវត្តបែបនេះគេតែងតែជីកប្រឡាយ ឬបៀព័ទ្ធជុំវិញស្រែទទឹង ១,៥-២ម និងជម្រៅ ០,៨-១មហើយត្រូវជីក ត្រឹមតែ ១០ ទៅ ១៥ ភាគរយ នៃទំហំផ្ទៃស្រែទាំងមូលតែប៉ុណ្ណោះ។ ត្រីឆ្ពិន ត្រីកាបសាមញ្ញ ត្រីកាបស ត្រីទីឡាព្យ៉ា ត្រីកាបឥណ្ឌា ត្រីក្រាញ់ និងត្រីកន្ធរត្រូវបានគេដាក់ចិញ្ចឹមជាប្រចាំនៅក្នុងប្រព័ន្ធចំរុះនេះ។ ផលិតផលប្រចាំឆ្នាំជាមធ្យមដែលទទួលបានពីប្រព័ន្ធចិញ្ចឹមត្រីក្នុងស្រែនៅតំបន់ដីសណ្តទន្លេមេគង្គបានផ្តល់ផលប្រមាណ ០,៣៧ តោន/ហិកតា ដោយអាចឱ្យត្រីនៅបន្តក្នុងវាលស្រែបានសម្រាប់រយៈពេលដាំដុះបន្តពី ២-៣ ដងទៀត។

[២] ក្រសួងជលផលធ្វើការប៉ាន់ស្មានសម្រាប់ឆ្នាំ ២០០១ មាន ៣៧២.៩៧៨ តោន. ដោយមាន ១៣៧.០៤៣ តោនបានមកពីការចិញ្ចឹមតាមស្រះ ៦៤.៥០៨ តោនបានពីការចិញ្ចឹមតាមបែ និង ៦៣.៦៤៣តោន ឡូង និងក្រែងឃោមបានពីការចិញ្ចឹមបង្គា/បង្កង ៧១.៥៣៦ តោន និងបានពីការចិញ្ចឹមវារីសត្វផ្សេងៗទៀតចំនួន ៣៥.៤៤៨ តោន។

[៣] គម្រោងផ្សព្វផ្សាយអភិវឌ្ឍន៍វារីវប្បកម្មតាមជនបទ (READ) កម្មវិធីជលផលគណៈកម្មការទន្លេមេគង្គ

នៅឆ្នាំ ១៩៩៩ មានបែចិញ្ចឹមត្រីចំនួន ៤.៦៣៩ នៅក្នុងខេត្តទាំង ៤ នៃតំបន់ដីសណ្តទន្លេមេគង្គ ហើយបែរនីមួយៗមានទំហំចន្លោះពី ៥០-៤០០ ម³ ដែលផ្នែកខាងលើនៃបែអណ្តែតលើផ្ទៃទឹក និងផ្នែកនៅសល់លិចក្នុងទឹក។ ត្រីប្រា ត្រីឆ្តោ ត្រីកាហែ ត្រីកាបស និងត្រីកាបសាមញ្ញត្រូវបានគេចិញ្ចឹមនៅក្នុងបែដោយដាក់ចិញ្ចឹមតែត្រីមួយប្រភេទប៉ុណ្ណោះ និងមានចំនួនច្រើន ពេលខ្លះមានត្រីកាបសាមញ្ញមួយចំនួន ដើម្បីឱ្យវាស៊ីកាកសំណល់ដែលនៅសេសសល់។ ត្រីប្រា និងត្រីឆ្តោ ត្រូវបានបំប៉នក្នុងករិត ដង់ស៊ីតេពី ២០០-៣០០ និងដាក់ចិញ្ចឹមយកសាច់ក្នុងករិតដង់ស៊ីតេពី ៨០-១៥០ ក្បាលក្នុងមួយម៉ែត្រគូប ក្នុងទំហំត្រីពី ៥-៦ ក្រាម។ ប្រភេទត្រីផ្សេងៗទៀត ដាក់ចិញ្ចឹមក្នុងដង់ស៊ីតេ ៨០-១០០ ក្បាលក្នុងមួយម៉ែត្រគូប។ ត្រីត្រូវបានគេផ្តល់ចំណីពូតដុំមានកន្ទក់លាយ ជាមួយចុងអង្ករ និងកាកសំណល់ត្រីដែលមានតម្លៃពី ០.១០-០.១៤ ដុល្លារក្នុង ១គីឡូក្រាម។ បន្លែកាលពីមុនត្រូវបានប្រើប្រាស់ជាចំណីត្រីប្រា ប៉ុន្តែបច្ចុប្បន្នត្រូវបានគេឈប់ប្រើប្រាស់លាយជាចំណីទៀតហើយ ដោយសារវាមានសារធាតុការ៉ូទែនដែលបណ្តាលឱ្យសាច់ត្រីប្រាមានពណ៌លឿង និងរោងចក្រកែច្នៃមិន ទទួលយក។ ត្រីត្រូវបានចិញ្ចឹមក្នុងរយៈពេលពី ១០-១៤ ខែ និងទទួលបានទិន្នផល ពី៨០-១២០ គីឡូក្រាមក្នុងមួយម៉ែត្រគូប។ ការចិញ្ចឹមត្រីតាមបែទាមទារការវិនិយោគទុនច្រើនលើសពីលទ្ធភាពរបស់ប្រជាជនក្រីក្រ និងកសិករធម្មតា។ ការចិញ្ចឹមត្រីតាមបែនៅប្រទេសវៀតណាម និងកម្ពុជាពឹងផ្អែកទាំងស្រុងលើការផ្គត់ផ្គង់ចំណី ដូចជា កាកសំណល់ត្រីសល់ពីការនេសាទ ។ ការប្រើប្រាស់កាកសំណល់ត្រី គឺជាការប្តូរពីផលិតផលដែលមានតម្លៃទាបទៅជាផលិតផលមានតម្លៃខ្ពស់។ កាកសំណល់ត្រីដែលបានពីធម្មជាតិគ្រាន់តែបំពេញតម្រូវការជាចំណីតែប៉ុណ្ណោះ។ គ្មានតួលេខអំពីកាកសំណល់ត្រីសំរាប់ធ្វើការពិនិត្យឡើងវិញឡើយ ប៉ុន្តែមានការព្រួយបារម្ភអំពីផលប៉ះពាល់កំណើននៃតម្រូវការលើបរិស្ថាន និងតម្រូវការត្រីរបស់ប្រជាជនក្រីក្រ ។

រដ្ឋាភិបាលវៀតណាមថ្មីៗនេះ បានចាប់ផ្តើមជំរុញការចិញ្ចឹមបង្កងទឹកសាបនៅតាមតំបន់ដីសណ្តទន្លេមេគង្គ។ នៅឆ្នាំ ១៩៩៩ មានស្រះចិញ្ចឹមបង្កងទឹកសាបចំនួន ២.៩៤០ ស្រះ។ ស្រះទាំងនេះមានទំហំពី ៥០-២០០ ម៉ែត្រការ៉េ និងអាចដាក់ចិញ្ចឹមកូនទើបញាស់បានពី ១-៥ ក្បាល ក្នុង ១ ម៉ែត្រការ៉េ។ ការចិញ្ចឹមបង្កងនេះពឹងផ្អែកទាំងស្រុងលើពូជពីធម្មជាតិ ទោះបីស្ថានីយ៍ភ្ញាស់កំពុងអភិវឌ្ឍក៏ដោយ។ ស្រែបង្កងតាមវាលស្រែ ៦,៧៣០ ហិកតា ដែលមានដាក់ចិញ្ចឹមកូនទើបញាស់ ១-២ ក្បាលក្នុង ១ ម៉ែត្រការ៉េ។ នៅក្នុងស្រះបង្កងត្រូវបានផ្តល់ចំណីកន្ទក់លាយជាមួយចុងអង្ករចំណីត្រី និងកាកសំណល់ត្រីនៅពេលដែលពុំមានចំណីនៅតាមវាលស្រែបង្កង។ ទិន្នផលគិតជាមធ្យមប្រចាំឆ្នាំ ១៩៩៩ គឺ ០,៣៣ តោន ក្នុង ១ ហិកតា។

នៅផ្នែកនៃតំបន់ខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាមដែលបង្ហូរទឹកទៅទន្លេមេគង្គមានវារីវប្បកម្មទ្រង់ទ្រាយតូច តាមស្រះ និងបែមួយចំនួន។ ការចិញ្ចឹមត្រីកាបស៊ីស្មៅតាមបែ បានចាប់ផ្តើមនៅក្នុងខេត្តដាឡាក់នៅក្នុងឆ្នាំ ១៩៩៣ នៅអាងទឹកអៀស៊ូប។ ចំនួនបែដែលចិញ្ចឹមនៅអាងស្តុកទឹកជលផលនោះបានកើនឡើងយ៉ាងឆាប់រហ័ស ប៉ុន្តែបានថយចុះទៅវិញនៅឆ្នាំ ១៩៩៦ ដោយសារមានជំងឺឆ្លងពីត្រីកាបស៊ីស្មៅ (Phillip 1998)។ បញ្ហាសំខាន់ដែលធ្វើឱ្យប៉ះពាល់ដល់ការចិញ្ចឹមត្រីតាមបែនៅក្នុងតំបន់នោះ គឺការបំពុលដល់បរិស្ថានទឹក ជំងឺឆ្លង និងផលវិបាកទីផ្សារ[៤] ។

## ១.៤.២ ប្រព័ន្ធដីសណ្តទន្លេមេគង្គ និង ទន្លេសាបនៅកម្ពុជា

នៅប្រទេសកម្ពុជា ជាង ៨០ ភាគរយ នៃផលិតកម្មវារីវប្បកម្មបានមកពីការចិញ្ចឹមតាមបែ និងស៊ងនៅតាមប្រព័ន្ធបឹងទន្លេសាបទន្លេមេគង្គ និងទន្លេបាសាក់។ ការចិញ្ចឹមតាមបែ និងស៊ងមានដើមកំណើតចេញពីដីសណ្តទន្លេមេគង្គ និងប្រព័ន្ធទន្លេសាបដែលមានប្រវត្តិតាំងពីយូរលង់ណាស់មកហើយ។ ប្រភេទត្រីភាគច្រើនដែលចិញ្ចឹមក្នុងបែរួមមាន ត្រីប្រា និងត្រីឆ្តោ។ ប្រភេទត្រីដែលចិញ្ចឹមតិចតួច មានប្រភេទត្រីកាហែ ត្រីអណ្តែង ត្រីដំរី ត្រីគ្រុំ និងត្រីច្រឡឹង ឬ ត្រីព្រលូង។ ការចិញ្ចឹមត្រីតាមបែនៅ ប្រទេសកម្ពុជាស្ថិតក្នុងដំណាក់កាលអន្តរកាលរវាងការចិញ្ចឹម និងការនេសាទពីធម្មជាតិ។ កសិករខ្លះប្រើប្រាស់បែសម្រាប់ការដឹកជញ្ជូន។ កសិករខ្លះ ប្រស់ត្រី ឬ បំប៉នត្រីក្នុងបែរយៈពេល ២ ទៅ ៣ ខែ សម្រាប់លក់នៅពេលខ្សត់ត្រី។ បែខ្លះទៀតអាចប្រើប្រាស់សម្រាប់បំប៉នត្រីឱ្យលូតលាស់រហូតមានទំហំតាមតម្រូវការទីផ្សារ។ ពូជកូនត្រីប្រា និងត្រីឆ្តោ ជារឿយៗត្រូវពឹងអាស្រ័យលើការចាប់ពីធម្មជាតិ។

ការចិញ្ចឹមត្រីក្នុងស្រះ និងតាមវាលស្រែបានអភិវឌ្ឍតិចតួចក្នុងប្រទេសកម្ពុជាទោះបីជានាពេលថ្មីៗនេះ មានការកើនឡើងនូវសារៈសំខាន់របស់វា ដោយមានការជួយទ្រទ្រង់ពីបណ្តាអង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារអន្តរជាតិនានាក៏ដោយ។ ការចូល

[៤] ឧទាហរណ៍ បញ្ហាជម្ងឺដែលកើតមាននៅតាមការចិញ្ចឹមតាមបែរនៅក្នុងអាងស្តុកជលផល អៀស៊ូប នៅឆ្នាំ ១៩៩៧ បានបណ្តាលឱ្យ កសិករជាច្រើនលក់ត្រីកាបស៊ីស្មៅ ជាច្រើនក្នុងតម្លៃទាបដោយសារតម្រូវការត្រីនៅទីផ្សារតិច។ ជាងនេះទៅទៀតករណីនេះក៏បានធ្វើ ឱ្យប៉ះពាល់ យ៉ាងធ្ងន់ធ្ងរដល់ តំលៃត្រីពីធម្មជាតិ ដោយអ្នកនេសាទ បញ្ចុះតម្លៃត្រី ដែលចាប់ពីបានពីធម្មជាតិឱ្យទាប។

រួមចំណែកពីការចិញ្ចឹមត្រីក្នុងស្រះ និងតាមវាលស្រែមានប្រមាណពី ១៥-២០ ភាគរយនៃផលិតកម្មវារីវប្បកម្មសរុប។ ប្រភេទចិញ្ចឹមទី ១ ការចិញ្ចឹមត្រីប្រាតាមបែបវិបុលវប្បកម្មមានច្រើននៅជុំវិញទីក្រុងភ្នំពេញ និងនៅខេត្តកណ្ដាល និងនៅជិតទីផ្សារនៃទីក្រុងភ្នំពេញ។ កូនត្រីពូជប្រមូលពីធម្មជាតិដាក់ចិញ្ចឹមក្នុងស្រះតូច និងផ្ដល់កន្ទក់ជាចំណី ឬកាកសំណល់ត្រីនៅពេលត្រីមានសំបូរច្រើន។ ប្រភេទចិញ្ចឹមត្រីទីពីរត្រូវការធនធានចិញ្ចឹមក្នុងស្រះតិច ចិញ្ចឹមត្រីតាមវាលស្រែ និងការចិញ្ចឹមចំរុះរវាងត្រី និងសត្វ រុក្ខជាតិដែលបានមកពីក្នុងស្រុក និងនាំចូលពីបរទេស។ ដូច្នេះ ទោះបីទិន្នផលត្រីបានពីស្រះចិញ្ចឹមត្រី និងវាលស្រែនៅមានកំរិតទាបបើប្រៀបទៅនឹងទិន្នផលត្រីថ្នាក់ជាតិក៏ដោយ ប៉ុន្តែវាមានសារៈសំខាន់ណាស់ចំពោះគ្រួសារនៅតំបន់ខ្សត់ត្រីនៅឆ្ងាយពីបឹងទន្លេសាប និងទន្លេសំខាន់ៗ។

## ១.៤.៣. ប្រទេសឡាវ

នៅប្រទេសឡាវការចិញ្ចឹមត្រីក្នុងស្រះ និងតាមវាលស្រែត្រូវបានអនុវត្តជាច្រើនកន្លែង និងតាមប្រព័ន្ធផ្សេងៗគ្នាដោយអាស្រ័យលើកអាកាសធាតុនៃតំបន់ទាំងនោះ។ តំបន់សំខាន់គឺនៅតាមតំបន់ទំនាបលិចទឹកនៃទន្លេមេគង្គ ជ្រលងភ្នំក្នុងតំបន់ខ្ពង់រាប (ដែលគ្របដណ្ដប់ ៨៥ ភាគរយ នៃប្រទេសឡាវ)។ វារីវប្បកម្មមានការយកចិត្តទុកដាក់ផងដែរក្នុងតំបន់ដែលអាចអនុវត្តការចិញ្ចឹមត្រីតាមរដូវ ដូចជាការចិញ្ចឹមតាមស្រះ និងតាមវាលស្រែ។ កសិករនៅតាមតំបន់ជនបទកំពុងត្រូវបានបំផុសឱ្យចូលរួមអនុវត្តវារីវប្បកម្ម ដោយសារមិនអាចនេសាទត្រីបានពីធម្មជាតិ ឬទាមទារឱ្យមានកិច្ចខិតខំអនុវត្តវារីវប្បកម្មបន្ថែម ដោយសារការនេសាទទទួលបាន ផលក្នុងកំរិតទាប។ ការចិញ្ចឹមត្រីតាមបែក្នុងអាងស្តុកទឹកមានចំនួនតិចតួច ហើយមានការកើនឡើងនូវការវិនិយោគទុនលើការចិញ្ចឹម ត្រីតាមបែក្នុងតំបន់អាងទន្លេមេគង្គ និងបណ្ដាដៃរបស់វា ប៉ុន្តែប្រព័ន្ធចិញ្ចឹមនេះបានផ្ដល់នូវទិន្នផលត្រីបន្តិចបន្តួចប៉ុណ្ណោះក្នុងផលិតកម្មវារីវប្បកម្ម។ ស្រះភាគច្រើននៅប្រទេសឡាវទទួលទឹកពីទឹកភ្លៀង និងស្រះមានទឹករាក់ដែលមានជំរៅរាក់ជាង ៥០ សម។ ជាទូទៅ ស្រះចិញ្ចឹមត្រីដែលជីកដោយដៃមានទំហំតូច។ ការអភិវឌ្ឍស្រះចិញ្ចឹមត្រី គឺជារឿយៗជាស្រះដែលបានមកពីការកសាងផ្លូវ ឬប្រឡាយ ប៉ុន្តែការចិញ្ចឹមតាមរបៀបនេះជួបបញ្ហាផលវិបាកដោយសារកង្វះកូនត្រីពូជ។

ទិន្នផលវារីវប្បកម្មតាមស្រះនៅតាមជនបទ នៅមានកំរិតទាប ហើយនេះឆ្លុះបញ្ចាំងពីការប្រើប្រាស់ធនធាន (ចំណី និងជីបន្ថែម) ដាក់នៅក្នុងស្រះចិញ្ចឹមត្រីមិនគ្រប់គ្រាន់ ហើយខ្វះកូនត្រីសម្រាប់ដាក់ចិញ្ចឹម។ នៅតំបន់ត្រជាក់ខ្លាំងការលូតលាស់របស់ត្រីថយចុះ ហើយទិន្នផលដែលទទួលបានក៏មានកំរិតផងដែរ។ ប្រភេទត្រីផ្សេងៗជាច្រើនត្រូវបានចិញ្ចឹមក្នុងប្រទេសឡាវ រួមមាន ប្រភេទត្រីឡាព្យ៉ា ប្រភេទត្រីកាបបរទេស (ត្រីកាបឥណ្ឌា ត្រីកាបស និងត្រីកាបសាមញ្ញ) ហើយនិងប្រភេទត្រីក្នុងស្រុក ដូចជាត្រីឆ្ពិន ជាដើម។ ប្រភេទត្រីផ្សេងៗពីធម្មជាតិ (រួមមាន ត្រីឆ្តោ ត្រីក្រាញ់ ត្រីអណ្ដែង អន្ទង់ ត្រីមាស *(Carassius auratus)* ត្រីកាបសាមញ្ញ (Cyprinus Carpio)[5] និងប្រភេទត្រីតូចៗផ្សេងៗទៀត ដូចជា ត្រីចង្វា កំពីស កង្កែប និងខ្យង ដែលជួនកាលមាននៅក្នុងស្រះតែម្ដង) ដែលផ្ដល់ជាប្រភពជីវជាតិបន្ថែមយ៉ាងសំខាន់សម្រាប់គ្រួសារនៅតាមជនបទ។ ប្រភេទត្រីតូចៗដែលមានតម្លៃទាបនៅទីផ្សារ ជាទូទៅ ត្រូវបានទុកសំរាប់បរិភោគនៅក្នុងគ្រួសារប្រចាំថ្ងៃតែប៉ុណ្ណោះ។

នៅតាមតំបន់ជនបទនៃប្រទេសឡាវ ពួកគេពឹងអាស្រ័យលើប្រព័ន្ធកសិកម្មដែលជារបរចិញ្ចឹមជីវិត និងបានផលលើសពីតំរូវការក្នុងគ្រួសារតិចបំផុត និងជាធម្មតាការចិញ្ចឹមសត្វសម្រាប់តែបរិភោគក្នុងគ្រួសារតែប៉ុណ្ណោះ។ ជាលទ្ធផល កសិករខ្វះដីប្រើសម្រាប់បង្កើនចំណីត្រី។ ម្យ៉ាងទៀតពួកគេតែងតែខ្វះកូនត្រីពូជ ខ្វះចំណីបន្ថែម ខ្វះព័ត៌មានបច្ចេកទេស ឬខ្វះការយល់ដឹងអំពីសក្ដានុពលភាពវារីវប្បកម្ម។ នេះដោយសារអត្រាប្រជាជនរស់នៅទាបហើយទំនាក់ទំនងពីភូមិមួយទៅភូមិមួយនៅខ្សោយសេវាកម្មផ្សព្វផ្សាយវារីវប្បកម្មដែលអាចជួយជំរុញវារីវប្បកម្ម និងព័ត៌មានបច្ចេកទេសនៅមានកំរិត។

វាលស្រែនៅប្រទេសឡាវ គឺជាប្រភពយ៉ាងសំខាន់នៃធនធានវារីជាតិទាំងការនេសាទ និងការចិញ្ចឹម។ ទោះជាយ៉ាងណាក៏ដោយ ការចិញ្ចឹមត្រីក្នុងស្រែគឺមានការពិបាកនៅក្នុងតំបន់ខ្ពង់រាប។ វាលស្រែពឹងលើទឹកភ្លៀង និងប្រព័ន្ធបង្ហូរទឹកក្នុងស្រែ គឺជាធម្មតាតម្រូវឱ្យមានភាពរាបស្មើ ដោយសារទំហំវាលស្រែនីមួយៗមានកំណត់កសិករ គឺមិនអើពើក្នុងការបង្ហូរទឹកពីប្រឡាយ ឬទំនប់ទឹកធ្វើជាជំរកត្រី (តាមការណែនាំពីអ្នកជំនាញការចិញ្ចឹមត្រីក្នុងស្រែ) តម្រូវការជំរៅទឹកជ្រៅ និងជម្រកត្រី គឺមានសារៈសំខាន់តិចតួចក្នុងតំបន់ខ្ពង់រាប ពីព្រោះមានសីតុណ្ហភាពត្រជាក់។

កន្លែងដែលមានប្រព័ន្ធបង្ហូរទឹកអាចដាក់ចិញ្ចឹមត្រីក្នុងស្រែ ហើយទទួលបានជោគជ័យ និងបរិមាណកូនត្រីពូជកើនឡើង។ ក្នុងតំបន់ខ្ពង់រាបប្រទេសឡាវ ប្រភេទត្រីកាប (Cyprinus carpio) និងត្រីមាស (Carassius auratus) ពងតាមលក្ខណៈធម្មជាតិនៅក្នុងស្រែ និងស្រះដែលជិតៗគ្នា។ ក្នុងតំបន់ខ្លះកសិករអាចផលិតកូនត្រីពូជបានដោយខ្លួនឯងដែលជាការនិយមចូលចិត្តរបស់កសិករ និងមិនចាំបាច់ចំណាយប្រាក់សម្រាប់ទិញកូនត្រីពូជ។ កម្មវិធីរបស់អង្គការស្បៀងអាហារពិភពលោកបានរកឃើញថា ការចិញ្ចឹមត្រីក្នុងស្រែត្រូវបានពង្រីកយ៉ាងឆាប់រហ័ស ដោយកសិករដែលបានឆ្លងកាត់វគ្គបណ្តុះបណ្តាលស្តីពី ការផលិតកូនត្រីពូជ។ នៅដំណាក់កាលដំបូងបញ្ហាកង្វះខាតកូនត្រីពូជគឺជាបញ្ហាចំបង។ គំរោងស្រាវជ្រាវរបស់អង្គការ DFID នៅខេត្តសាវ៉ាន់បានរកឃើញថា ការចិញ្ចឹមវារីជាតនៅតាមវាលស្រែកំពុងត្រូវបានអនុវត្តដោយកសិករក្រីក្រ។

ការផលិតកូនត្រីពូជ គឺជាការពេញនិយមរបស់គ្រួសារកសិករនៅតាមជនបទ ដោយសារការផលិតកូនត្រីពូជត្រូវការដើមទុនតិច ហើយកម្រៃដែលទទួលបានច្រើន។ ការកែប្រែដីស្រែពីរបីកន្លែងឱ្យក្លាយទៅជាស្រះត្រី គឺត្រូវបានជំរុញឱ្យពួកគាត់ធ្វើជាជាងការចិញ្ចឹមត្រីនៅតាមផ្ទុក ឬត្រពាំង។ កាលបើកូនត្រីពូជត្រូវបានផលិត កូនត្រីពូជទាំងនោះត្រូវបានផ្ទេរទៅស្រះជាប់នោះ ដើម្បីធ្វើការចិញ្ចឹមបំប៉ន។ ប្រសិនកសិដ្ឋានផលិតកូនត្រីពូជនៅជិតផ្សារដែលមានទីតាំងជិតទីរួមខេត្ត ឬផ្សារជិតទីរួមស្រុកនោះចំណូលពីការលក់កូនត្រីអាចបានដោយងាយ។ ត្រីដែលបានដាក់ចិញ្ចឹមក្នុងស្រែ (ជាធម្មតារយៈពេលពី ៩០ ថ្ងៃ ទៅ ១០០ ថ្ងៃ) ត្រូវបានប្រមូលផលទន្ទឹមគ្នាជាមួយនឹងការប្រមូលផលស្រូវ ហើយជារឿយៗផលដែលបានក្រោយពីការសងថ្លៃពលកម្ម ដើម្បីជួយជំរុញការប្រមូលផលស្រូវ។ នៅពេលមានត្រីនៅក្នុងស្រែរបស់ពួកគាត់ គឺជាការល្អប្រសើរ ព្រោះកសិករមិនសូវមានពេលវេលាច្រើនសម្រាប់ទៅរកត្រីក្នុងរដូវច្រូតកាត់ទេ។

ត្រីដែលប្រមូលបានមានទំហំផ្សេងៗគ្នាដោយយោងទៅតាមពេលវេលាដែលដាក់ចិញ្ចឹម។ កសិករចូលចិត្តចិញ្ចឹមត្រីធំ ទម្ងន់ពី ៥-១០ ក្រាម ចំពោះដែលត្រីនៅតូចក៏អាចដាក់ចិញ្ចឹមជាមួយគ្នាបានដែរដោយសារវាមានតម្លៃថោក។ ការដាក់ត្រីចិញ្ចឹមគឺជាទូទៅក្នុងអត្រាទាប ដោយសារកូនត្រីពូជមានតម្លៃថ្លៃ និងការខ្វះខាតថវិការបស់កសិករ។ ជាក់ស្តែងចាប់តាំងពីកសិករមិនប្រើប្រាស់ថវិកាសម្រាប់ទិញកូនត្រី ការលក់ដូរកូនត្រីពូជក៏មិនអាចមានសកម្មភាពដែរ។

ការចិញ្ចឹមត្រីក្នុងស្រែត្រូវបានអនុវត្តនៅតាមតំបន់ខ្ពង់រាបដែលជាចំបងចិញ្ចឹមសម្រាប់ការហូបចុកប្រចាំថ្ងៃតែប៉ុណ្ណោះ។ ប្រភេទត្រីដាក់ចិញ្ចឹមរួមមានប្រភេទត្រីកាប *(Cyprinus carpio)* ប្រភេទត្រីមាស *(Carassius auratus)* និងត្រីទីឡាព្យ៉ា ។ ភាពគ្រោះថ្នាក់ចំពោះវាលស្រែចិញ្ចឹមត្រីដែលគ្មានប្រព័ន្ធបង្ហូរទឹកគឺបានជួបប្រទះជាចំបងនូវទឹកជំនន់ ភាពរាំងស្ងួត និងចោរលួច។ ដូច្នេះត្រូវបង្កើនឱ្យមានប្រព័ន្ធផ្គត់ផ្គង់ទឹកឱ្យបានគ្រប់គ្រាន់។ ការបរាជ័យក្នុងការចិញ្ចឹមត្រីក្នុងស្រែគឺបណ្តាលមកពីកត្តាខាងលើ។ យោងតាមការធ្វើបទបង្ហាញបានបញ្ជាក់ថា មិនមែនវាលស្រែទាំងអស់សុទ្ធតែអាចចិញ្ចឹមត្រីបាននោះទេ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏ស្រែទាំងនោះអាចផ្តល់នូវធនធានវារីជាតផងដែរ។

## ១.៤.៤. ខ្ពង់រាបកូរ៉ាតក្នុងតំបន់ភាគឦសានថៃ

ក្នុងតំបន់ភាគឦសានប្រទេសថៃ វារីវប្បកម្មត្រូវបានពង្រីកយ៉ាងទូលាយតាំងពី ១០ ឆ្នាំមុនម្ល៉េះ ហើយតំបន់ខ្ពង់រាបកូរ៉ាត គឺជាតំបន់ទី២ នៃផលិតកម្មវារីវប្បកម្ម បន្ទាប់ពីដីសណ្តទន្លេមេគង្គ។ យោងតាមស្ថិតិជាផ្លូវការរបស់នាយកដ្ឋានជលផលថៃសម្រាប់ឆ្នាំ ១៩៩៨ (DoF, 2001) ទិន្នផលត្រីចិញ្ចឹមក្នុងស្រះ វាលស្រែ ប្រព័ន្ធប្រឡាយ និងទិន្នផលត្រីចិញ្ចឹមតាមបែ គឺមានប្រមាណ ៣៨.០០០ តោន។ ស្ថិតិទាំងនេះគឺពិតជាមិនបានគិតបញ្ចូលនូវបរិមាណត្រីដែលចិញ្ចឹមជាលក្ខណៈគ្រួសារទេ ដោយសារកសិករចិញ្ចឹមត្រីជាលក្ខណៈគ្រួសារមានចំនួនច្រើន។ កសិដ្ឋានចិញ្ចឹមមានប្រមាណ ២.៦ លានគ្រួសារ ក្នុងតំបន់ភាគឥសាន្តនេះ។ រយៈពេល ០៥ ឆ្នាំកន្លងទៅប្រមាណ ៦០.០០០ ស្រះចិញ្ចឹមត្រីត្រូវបានជីកក្នុងតំបន់នោះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ស្រះទាំងនោះមិនអាចដំណើរការបានទាំងអស់នោះទេ។ ឥឡូវនេះតាមការប៉ាន់ប្រមាណមានជាង ២០០.០០០ គ្រួសារ ដែលមានសកម្មភាពចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ហើយទិន្នផលត្រី ដែលទទួលបានពីការចិញ្ចឹមជាលក្ខណៈគ្រួសារនេះមានប្រមាណ ៣០.០០០ តោន ឬក៏ច្រើនជាងនេះ។ ដូច្នេះទិន្នផលត្រីសរុបមានប្រមាណ ៦៨.០០០ តោន ក្នុងមួយឆ្នាំ ហើយប្រសិនបើគិតបញ្ចូល ៣០.០០០ តោន ពីទិន្នផលត្រីជាលក្ខណៈគ្រួសារ និង ៣៨.០០០ តោន ដែលជាទិន្នផលត្រីជាផ្លូវការរបស់នាយកដ្ឋានជលផលក្នុង ឆ្នាំ ១៩៩៨។

ស្រះចិញ្ចឹមត្រីមានចំនួនយ៉ាងច្រើននៅខ្ពង់រាបកូរ៉ាត។ ប្រភេទត្រីចិញ្ចឹមរួមមានប្រភេទត្រីទីឡាព្យ៉ាគ្រប់ប្រភេទ ប្រភេទត្រីកាបពីបរទេស និងត្រីកាបក្នុងស្រុក រួមមានត្រីឆ្ពិន ត្រីកាបសាមញ្ញ ត្រីកាបឥណ្ឌា ត្រីកាបចិន ត្រីរ៉ស់ និងត្រីអណ្តែង។ ស្រះ

ចិញ្ចឹមត្រី គឺពឹងផ្អែកទៅលើផលិតផលកាកសំណល់កសិកម្ម ជីលាមកសត្វ បន្លែ និងការកើនឡើងនៃចំណីគ្រាប់ពាណិជ្ជកម្ម (ចំណីសិប្បនិម្មិត)។ ឯការចិញ្ចឹមចំរុះបានជួបប្រទះនៅតាមតំបន់ជាយក្រុងដែលមានជីលាមកសត្វជ្រូក និងសត្វមាន់គ្រប់គ្រាន់។

ចំពោះការចិញ្ចឹមត្រីក្នុងស្រែគឺបានជួបប្រទះផងដែរនៅភាគឦសានប្រទេសថៃ។ ទោះបីជាការចិញ្ចឹមមិនមានលក្ខណៈទូលំទូលាយយ៉ាងណាក៏ដោយ ក៏នាពេលថ្មីៗនេះការចិញ្ចឹមត្រីទីឡាព្យ៉ាតាមបែផ្ទ្រវបានជួយគាំទ្រដោយកសិ-ឧស្សាហកម្មមានការរីកដុះដាលយ៉ាងខ្លាំងក្នុងរយៈពេល ០៣ ឆ្នាំកន្លងទៅក្នុងតំបន់ទឹកនៅតាមដៃព្រែក បឹងបួរសំខាន់ៗនៃអាងទឹកទន្លេមេគង្គ ដោយចាប់កូនត្រីពីធម្មជាតិយកមកចិញ្ចឹម។ ការចិញ្ចឹមត្រីមានសភាពកាន់តែរីកដុះដាល ប្រសិនបើបច្ចេកទេសនៃការបង្កាត់ភ្ញាស់កូនត្រីប្រាខៅកាន់តែមានភាពងាយស្រួល។ នៅភាគឦសាននេះ គឺជាកន្លែងយ៉ាងសំខាន់ផងដែរក្នុងការផ្គត់ផ្គង់កូនត្រីពូជ និងផ្គត់ផ្គង់ចំណីទៅឱ្យតំបន់នានាក្នុងប្រទេសឡាវ ដែលនៅជាប់នឹងព្រំដែនទន្លេមេគង្គ។

## ១.៥. អតិថិជន និង ទីផ្សារ

ផលិតផលវារីវប្បកម្មគឺកាន់តែមានសារៈសំខាន់ឡើងក្នុងទីផ្សារចិញ្ចឹមត្រីដោយឡែកក្នុងប្រទេសវៀតណាម និងប្រទេសថៃ។ ភាពសំបូរបែបនៃទីផ្សារផលិតផលវារីវប្បកម្មមានឥទ្ធិពលទៅលើកត្តាជោគជ័យសម្រាប់វារីវប្បកម្មហើយនឹងភាពសំបូរបែបនៃផលិតផលជលផលគឺមានឥទ្ធិពលយ៉ាងខ្លាំងទៅលើទីផ្សារផងដែរ។ ជាឧទាហរណ៍ ភាពសំបូរបែបនៃផលចាប់ពីធម្មជាតិក្នុងបឹងទន្លេសាបនៃប្រទេសកម្ពុជា ក្នុងអំឡុងដើមឆ្នាំ ២០០១ បានធ្វើឱ្យទីផ្សារត្រីចិញ្ចឹមក្នុងតំបន់ឦសានប្រទេសថៃធ្លាក់ចុះ ដូចជា ត្រីរស់ ត្រីអណ្តែង និងត្រីទីឡាព្យ៉ា។ ផលវិបាកនេះ ដោយសារភាពសំបូរហូរហៀរនៃផលចាប់ពីធម្មជាតិក្នុងឆ្នាំ ២០០១ និងការពង្រីករចនាសម្ព័ន្ធទីផ្សារកម្ពុជា និងប្រទេសថៃ។

វារីវប្បកម្មមានសារៈប្រយោជន៍យ៉ាងច្រើន បើប្រៀបធៀបជាមួយត្រីធម្មជាតិ ត្រីចិញ្ចឹមអាចលក់រស់បានផ្តល់ផលិតផលស្រស់ៗ ហើយត្រីចិញ្ចឹមមានតម្លៃលើទីផ្សារ នៅពេលដែលត្រីពីធម្មជាតិមិនមានគ្រប់គ្រាន់តាមតម្រូវការ ហើយមានតម្លៃថ្លៃគួរជាទីចាប់អារម្មណ៍។ ជាឧទាហរណ៍ ក្នុងខេត្តស្វាយរៀងនៃប្រទេសកម្ពុជា ត្រីមានតម្លៃថោកនៅដើមឆ្នាំពេលដែលត្រីចាប់ពីធម្មជាតិមានចំនួនច្រើន។ ចំពោះកសិករចិញ្ចឹមត្រីដែលមានទឹកគ្រប់គ្រាន់នៅក្នុងស្រះ ពួកគេអាចរក្សាត្រីទុកក្នុងស្រះរហូតដល់ចុងនៃរដូវប្រាំងចូលរដូវវស្សា ហើយជាពេលដែលគេអាចលក់ត្រីបានតម្លៃថ្លៃ។

ហេដ្ឋារចនាសម្ព័ន្ធ និងភាពសំបូរនៃត្រីធម្មជាតិមានឥទ្ធិពលលើទីផ្សារផលិតផលវារីវប្បកម្ម។ វារីវប្បកម្មអាចផ្តល់នូវភាពរស់រវើកនៃទីផ្សារផ្តល់អត្ថប្រយោជន៍នៅរដូវប្រាំងពេលដែលខ្វះខាតត្រី និងកំឡុងពេលប្រារព្ធពិធីបុណ្យអុំទូក។ តម្លៃត្រីចិញ្ចឹមមានតម្លៃថ្លៃបំផុតក្នុងកំឡុងពេលប្រារព្ធពិធីចូលឆ្នាំឡាវ និងពិធីចូលឆ្នាំខ្មែរដែលប្រារព្ធធ្វើឡើងក្នុងរដូវប្រាំង និងចំពេលដែលត្រីក្នុងធម្មជាតិមានការខ្វះខាត។ ដូចដែលបានបញ្ជាក់ហើយថា ត្រីចិញ្ចឹមអាចលក់រស់នៅតាមទីផ្សារក្នុងភូមិដោយធានាបាននូវត្រីស្រស់ និងមានរសជាតិឆ្ងាញ់។ តំបន់ជនបទគ្មានប្រព័ន្ធអគ្គីសនី ហើយជារឿយៗមិនមានទឹកកក ដូច្នេះបំណងនៃការលក់ត្រីរស់ដែលចាប់ពីធម្មជាតិគឺពិតជាទទួលបានអត្ថប្រយោជន៍យ៉ាងច្រើន ព្រោះថាជួនកាលត្រីអាចថយរសជាតិពេលដែលយើងរក្សាទុកយូរតាំងពីចាប់បានមក។

សមាមាត្រត្រីចិញ្ចឹមអាចប្រើសម្រាប់ការហូបចុកនៅផ្ទះ ឬក៏មិនសម្រាប់បំរើទីផ្សារទេ។ ជាឧទាហរណ៍ ត្រីចិញ្ចឹមជាធម្មតាប្រើប្រាស់សម្រាប់តែគ្រួសារប៉ុណ្ណោះ នៅប្រទេសឡាវ ទិញត្រីពីអ្នកជិតខាង គឺដើម្បីបំពេញតម្រូវការក្នុងពិធីបុណ្យផ្សេងៗប៉ុណ្ណោះ ដោយយោងតាមទិន្នន័យពីកម្មវិធីFAOនៅប្រទេសឡាវ (FAO/LAO/97/007-Fung-Smith 1999a) មាន៧០ភាគរយនៃកសិករចិញ្ចឹមត្រីបានលក់ត្រីចិញ្ចឹមពីកសិដ្ឋាន។ ផលិតផលភាគច្រើនបានពីវារីវប្បកម្មត្រូវបានប្រើប្រាស់នៅក្នុងតំបន់នោះផ្ទាល់ ឬនៅផ្សារជិតនោះ។ ការនាំចេញប្រភេទត្រីចិញ្ចឹមដែលជាប្រភេទត្រីគួរឱ្យកត់សំគាល់ដូចជាត្រីប្រា ហើយបច្ចុប្បន្ននេះត្រីប្រា *(Pangasianodon hypophthalmus)* កូនពូជភាគច្រើនដ៏លើសលុបបាននាំចូលពីប្រទេសវៀតណាម។ ប្រភេទត្រីប្រាទន្លេគឺមានតម្លៃនៅទីផ្សារ សហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប ដូចជាសាច់បន្ទះ (Fillet)។ សាច់បន្ទះត្រីទីឡាព្យ៉ាខ្លះបាននាំចេញពីប្រទេសវៀតណាម ហើយផលិតផលសាច់បន្ទះត្រីទីឡាព្យ៉ានេះកំពុងមានការចាប់អារម្មណ៍ពីអ្នកប្រើប្រាស់ និងមានតម្លៃខ្ពស់នៅលើទីផ្សារ។

ដូច្នេះផលិតផលត្រីទាំងនោះគឺអាចឱ្យការចិញ្ចឹមត្រីកាន់តែមានតម្លៃ។ ត្រីធម្មជាតិអាចច្នៃធ្វើជាត្រីងៀត ត្រីឆ្អើរ ហើយនឹងត្រីហើម ប៉ុន្តែផ្ទុយមកវិញវារីវប្បកម្មគឺបានផ្តោតជាសំខាន់ទៅលើគុណភាពផលិតផល និងការលក់ត្រីស្រស់តាមការចាំបាច់។

នៅក្នុងករណីនៃការចិញ្ចឹមត្រីតាមបែនៅចៅដុក (Chau Doc) ខេត្តអានយ៉ាង (An Giang) ការផ្លាស់ប្តូរនៃតួនាទីរបស់អ្នកជំនួញគឺជាការចំណាប់អារម្មណ៍ពិសេសមួយ។ បណ្តាញជំនួញដ៏ផ្សេងៗគ្នាក្នុងការផ្គត់ផ្គង់ដល់ការចិញ្ចឹមត្រីតាមបែបាន

លេចឡើងស្របគ្នា។ ការផ្គត់ផ្គង់ត្រីស្រកាទឹកសាបតូចៗដែលនេសាទដោយឧបករណ៍លបបានកើនដល់ប្រហែល ១.០០០ តោនក្នុងមួយថ្ងៃនៅរដូវវស្សា។ ការជួញដូរនេះត្រូវបានដឹកឆ្លងកាត់ទីក្រុងចៅដុក (Chau Doc) ជាប្រចាំថ្ងៃ សម្រាប់ធ្វើជាចំណីត្រីប្រា និងត្រីរ៉ស់ដែលត្រូវបានចិញ្ចឹមនៅជុំវិញតំបន់នោះ។ កូនត្រីប្រា *(Pangasius bocourti)* និងកូនត្រីរ៉ស់/ឆ្តោ (Channa spp.) ត្រូវបានចាប់ដោយប្រើឧបករណ៍ងាយត្រីក្នុងប្រទេសកម្ពុជា ហើយត្រូវបានលក់ទៅប្រទេសវៀតណាមសម្រាប់ចិញ្ចឹមតាមបៃ។ បណ្តាញជួញដូរក្នុងការផ្គត់ផ្គង់ចំណីត្រីសម្រាប់វារីវប្បកម្មឃើញថា មានការរីកលូតលាស់ក្រៅបណ្តាញជួញដូរត្រី [៦] ។

## ១.៦ ស្ថាប័នទ្រទ្រង់វារីវប្បកម្ម

### ១.៦.១. គោលនយោបាយ និង ច្បាប់

គោលនយោបាយរបស់រដ្ឋាភិបាលក្នុងប្រទេសនៃតំបន់ទន្លេមេគង្គទាំងអស់បានគាំទ្រដល់វារីវប្បកម្ម និងរដ្ឋាភិបាលខ្លះទៀតក៏មានគោលដៅនៃការផលិត និងការរកកម្រៃសម្រាប់អភិវឌ្ឍន៍នាពេលអនាគតផងដែរ។ គោលការណ៍ដែលគាំទ្រវារីវប្បកម្មទាំងនេះបានគាំពារឱ្យការវិនិយោគជាច្រើនដូចជាការស្រាវជ្រាវ ហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ និងការផ្សព្វផ្សាយដែលបានចូលរួមយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវារីវប្បកម្មក្នុងរយៈពេល ១០ ឆ្នាំកន្លងមកនេះ។ ជាលទ្ធផល ការគាំទ្រនេះមិនសូវមានការយកចិត្តទុកដាក់ទៅលើវារីវប្បកម្មទឹកសាបទេ។ ប្រទេសថៃ និងប្រទេសវៀតណាមបានដាក់ទុនវិនិយោគយ៉ាងច្រើននៅក្នុងវិស័យវារីវប្បកម្មតែចំពោះប្រទេសឡាវ និងប្រទេសកម្ពុជាវិញឃើញថា ការវិនិយោគទុនចំពោះវារីវប្បកម្មហាក់ដូចជាមានតិចតួចណាស់។ នៅប្រទេសកម្ពុជាស្ថាប័នជាច្រើនបានគាំទ្រដោយផ្ទាល់ទៅលើការនេសាទពីធម្មជាតិ ហើយនៅចុងឆ្នាំ ១៩៩០ វារីវប្បកម្មត្រូវបានទទួលស្គាល់ជាគោលការណ៍ ព្រមទាំងការិយាល័យវារីវប្បកម្មក៏បានបង្កើតឡើងនៅក្នុងនាយកដ្ឋានជលផលផងដែរ។

រដ្ឋាភិបាលក៏បានទទួលស្គាល់វារីវប្បកម្មនៅក្នុងបរិបទនៃគោលការណ៍អភិវឌ្ឍន៍ជនបទ និងកាត់បន្ថយភាពក្រីក្រផងដែរ។ ឧទាហរណ៍ ថ្មីៗនេះខុទ្ទកាល័យនាយករដ្ឋមន្ត្រីនៃប្រទេសវៀតណាមបានបង្កើតគោលនយោបាយទាក់ទងនឹងវារីវប្បកម្ម នឹងជួយកាត់បន្ថយភាពក្រីក្រ។ នេះគឺជាផ្នែកមួយក្នុងកម្មវិធីលុបបំបាត់នូវភាពស្រេកឃ្លាន និងការកាត់បន្ថយភាពក្រីក្ររបស់ជាតិ។ នៅក្នុងប្រទេសថៃវិញ រដ្ឋធម្មនុញ្ញថ្មីដែលបានប្រកាសឱ្យប្រើនៅឆ្នាំ១៩៩៧ បញ្ជាក់ពីការផ្តល់អំណាចគ្រប់គ្រង បែបវិមជ្ឈការទៅដល់ថ្នាក់មូលដ្ឋាន ដើម្បីគាំទ្រដល់ការអភិវឌ្ឍមូលដ្ឋាន។ នៅប្រទេសឡាវគោលនយោបាយថ្មីរបស់រដ្ឋាភិបាលទៅលើវិស័យកសិកម្មបានទទួលស្គាល់នូវតួនាទីរបស់វារីវប្បកម្មក្នុងការអភិវឌ្ឍតំបន់ជនបទ និងបង្កើតនូវប្រាក់ចំណូល ។

គោលការណ៍បរិស្ថាន ក្រៅពីវិស័យជលផលវារីវប្បកម្មមានឥទ្ធិពលយ៉ាងខ្លាំងក្លាដល់ការអភិវឌ្ឍ។ ឧទាហរណ៍ ដើម្បីកាត់បន្ថយភាពក្រីក្រ ដីស្រែត្រូវបានជំរុញឱ្យជីកជាស្រះសម្រាប់ចិញ្ចឹមត្រីវិញនៅប្រទេសវៀតណាម និងប្រទេសឡាវ តាមរយៈគោលការណ៍ផ្លាស់ប្តូរដីធ្លីប្រើប្រាស់។ បញ្ហាដីកម្មសិទ្ធ និងការប្រើប្រាស់ដីធ្លីគឺជាបញ្ហាសំខាន់ក្នុងការគ្រប់គ្រងភូមិឬសហគមន៍ ស្រះចិញ្ចឹមត្រីនៅភាគខាងជើងឆៀងខាងកើតនៃប្រទេសថៃ និង ប្រទេសឡាវ។

គោលនយោបាយរបស់រដ្ឋាភិបាលគឺដើម្បីជម្រុញឱ្យមានពាណិជ្ជកម្មអន្តរជាតិតាមតំបន់និងការអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធក៏បានជះឥទ្ធិពលលើការអភិវឌ្ឍវារីវប្បកម្ម

**ប្រអប់២ : បទពិសោធន៍ជាមួយក្រុមកសិករ និងការផ្សព្វផ្សាយវារីវប្បកម្មនៅក្នុងប្រទេសឡាវ**

វារីវប្បកម្មនៅតាមតំបន់ជនបទ គឺជាសកម្មភាពមួយដែលអាចចិញ្ចឹមជីវភាពគ្រួសារដោយពឹងផ្អែកទៅលើធនធានផ្សេងៗដែលទទួលជោគជ័យលើការអភិវឌ្ឍបែបបុរាណ និងបានផ្តោតសំខាន់ទៅលើតែបច្ចេកទេសបន្តិចបន្តួចដែលគ្រួសារជាច្រើនមិនបានចូលរួម។ គម្រោងរបស់អង្គការ FAO (FAO/LAO/97/007) បានបង្កើតក្រុមកសិករដែលមានស្ថានភាពគ្រួសារផ្សេងៗគ្នា។ ការផ្គត់ផ្គង់កសិករដោយជួយត្រីពូជ បច្ចេកទេសបន្ថែមលើការចិញ្ចឹមត្រី និងការកែប្រែប្រព័ន្ធចិញ្ចឹមដោយយោងទៅតាមគំរិតមហន្តរាយដែលពួកគាត់បានទទួលស្គាល់។ គ្រួសារដែលមានប្រភពទឹកល្អ ឬក៏អ្នកមានចំណូលចិត្តក្នុងការចិញ្ចឹមត្រីត្រូវបានបណ្តុះបណ្តាលឱ្យចេះផលិតកូនត្រីពូជ។ ការផលិតកូនត្រីពូជតាមបែបវិមជ្ឈការគឺជាកត្តាសំខាន់មួយដើម្បីឱ្យមាននិរន្តរភាពក្នុងការផ្គត់ផ្គង់កូនត្រីពូជដល់តំបន់ដាច់ស្រយាលដែលស្ថានីយ៍ភ្ញាស់កូនត្រីខេត្តមិនអាចផ្គត់ផ្គង់ទៅដល់បាន។

6.ទំនាក់ទំនងផ្ទាល់ជាមួយ សៃមិន ប៊ូស (Siman Bush) ដោយផ្អែកលើរបាយការណ៍មិនទាន់បោះពុម្ពផ្សាយ របស់គណៈកម្មការទន្លេមេគង្គ

ផងដែរ ដោយនាំមកនូវសកម្មភាពនៃការផលិតកូនត្រីពូជយ៉ាងច្រើន និងជាប្រភពចំណីត្រីគ្រប់ប្រភេទ ជាពិសេសការប្រើប្រាស់ជីព្រមទាំងមានត្រីយ៉ាងច្រើននៅលើទីផ្សារទៀតផង ។

ច្បាប់ និងបទបញ្ជាផ្ទៃក្នុងជាច្រើន ត្រូវបានកែប្រែនៅគ្រប់លំដាប់ថ្នាក់ ប៉ុន្តែមិនមានច្បាប់ដោយឡែកស្តីពីវារីវប្បកម្មក្នុងបណ្តាប្រទេសតំបន់ទន្លេមេគង្គឡើយ។ វារីវប្បកម្មត្រូវបានចាត់ទុកជាផ្នែកមួយនៃច្បាប់ជលផលជាតិ។ ថ្មីៗនេះច្បាប់ជលផលបានត្រូវកែសម្រួលឡើងវិញ ឬកំពុងតែកែសម្រួលនៅក្នុងប្រទេសកម្ពុជា ប្រទេសថៃ និងប្រទេសវៀតណាម ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរតាមកាលៈទេសៈ។ នៅក្នុងប្រទេសកម្ពុជាច្បាប់ថ្មីមួយដែលកំពុងត្រូវបានបង្កើតឡើងដែលនឹងសង្កត់ធ្ងន់ទៅលើការគ្រប់គ្រងវារីវប្បកម្ម ក៏ដូចជាការគ្រប់គ្រងនៃប្រភពធនធានជលផល។ នៅក្នុងប្រទេសថៃ ច្បាប់ថ្មីកំពុងត្រូវបានបង្កើតឡើងដែលនឹងត្រូវផ្តោតច្រើនទៅលើការគ្រប់គ្រងសហគមន៍ជាមូលដ្ឋានស្របជាមួយនឹងរដ្ឋធម្មនុញ្ញថ្មី។ នៅក្នុងប្រទេសវៀតណាមច្បាប់ជលផលត្រូវបានព្រៀងដោយផ្តោតជាសំខាន់ទៅលើវារីវប្បកម្មដែលជាផ្នែកបន្ទាប់នៅក្នុងវិស័យជលផល។ ការបង្កើតនូវបទបញ្ជាផ្ទៃក្នុងដ៏ជាក់លាក់មួយស្តីអំពីវារីវប្បកម្មនឹងត្រូវបានរៀបចំឡើង ដោយគោរពទៅតាមច្បាប់ជលផលចាស់។

បច្ចុប្បន្ននេះ ស្ថាប័នពាក់ព័ន្ធជាមួយនឹងវារីវប្បកម្មកំពុងស្ថិតនៅក្នុងស្ថានភាពអន្តរកាល ដោយបានជំរុញឱ្យវារីវប្បកម្មកើតឡើង។ ទោះបីជាយ៉ាងណាក៏ដោយ យន្តការថ្មីរបស់ស្ថាប័នក្នុងការអភិវឌ្ឍ និងយុទ្ធសាស្ត្រគ្រប់គ្រងគឺតម្រូវឱ្យមានការផ្លាស់ប្តូរទៅជាការអភិវឌ្ឍ និងការគ្រប់គ្រងនៅថ្នាក់មូលដ្ឋានវិញ។

នៅក្នុងកម្រិតតំបនវិញ កិច្ចព្រមព្រៀងនៅឆ្នាំ ១៩៩៥ ដែលបានបង្កើតគណៈកម្មការទន្លេមេគង្គបានផ្តល់នូវក្របខ័ណ្ឌការងារសម្រាប់សហប្រតិបត្តិការជាមួយប្រទេសក្នុងតំបន់ទន្លេមេគង្គ ហើយមិនតែប៉ុណ្ណោះក៏មានការកើនឡើងនូវកិច្ចសហប្រតិបត្តិការលើការងារស្រាវជ្រាវការអភិវឌ្ឍ និងការអប់រំក្នុងកំឡុងពេល ១០ ឆ្នាំកន្លងមកដែលបានចូលរួមក្នុងការអភិវឌ្ឍវារីវប្បកម្មក្នុងតំបន់ទន្លេមេគង្គ។ ទោះជាយ៉ាងណាក៏ដោយ ក៏បញ្ហាគោលនយោបាយចំពោះបញ្ហាឆ្លងដែនដែលទាក់ទងនឹងវារីវប្បកម្មមិនទាន់បានចារជាលាយលក្ខណ៍អក្សរនៅឡើយទេ។ ក្នុងនោះមានបញ្ហាទាក់ទងនឹងពូជត្រីនាំចូលពីបរទេស ការសហការគ្នាក្នុងការទប់ស្កាត់ការរាតត្បាតនៃជម្ងឺត្រី និងបញ្ហាតំណពូជដែលពាក់ព័ន្ធដល់ចលនានៃការចិញ្ចឹមត្រីនៅក្នុងស្រុក។ នាពេលអនាគត កិច្ចសហប្រតិបត្តិការគ្នានេះអាចមានសារៈសំខាន់សម្រាប់គ្រប់គ្រងពូជត្រី និងសុខភាពសត្វពាហនៈក្នុងអាងទឹកទន្លេមេគង្គ ។

## ១.៦.២. ស្ថាប័នទ្រទ្រង់

ស្ថាប័នរដ្ឋាភិបាលដែលទ្រទ្រង់ដល់ការផ្សព្វផ្សាយ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាល គឺមាននៅគ្រប់ប្រទេសក្នុងតំបន់អាងទន្លេមេគង្គ។ ប្រទេសថៃ និងប្រទេសវៀតណាម បានវិនិយោគគួរឱ្យកត់សម្គាល់នូវធនធានជាច្រើនទៅលើវារីវប្បកម្ម ហើយ ប្រទេសវៀតណាមមានគម្រោងផែនការដ៏ធំដើម្បីពង្រឹងសមត្ថភាពការងារ និងការផ្សព្វផ្សាយវារីវប្បកម្ម។ ប្រទេសថៃបានដាក់ទុនវិនិយោគស្ថានីយ៍ភ្ញាស់ត្រី។ ជាធម្មតា ជំនួយដល់ការស្រាវជ្រាវច្រើនតែផ្តោតទៅលើបញ្ហាបច្ចេកទេស ហើយមានតិចតួចដែលផ្តោតទៅលើការចងក្រងជាទ្រឹស្តី និងជំរុញឱ្យកសិករអនុវត្តតាមរបៀបវារៈនៃការស្រាវជ្រាវ។ ដូចគ្នានេះ ការផ្សព្វផ្សាយបានផ្តល់នូវសេចក្តី សង្ឃឹមដល់កសិករជាជាងការផ្តល់តាមតម្រូវការរបស់កសិករ។ វារីវប្បកម្មនៅពេលបច្ចុប្បន្នត្រូវបានសម្របសម្រួលតាមតំរូវការរបស់កសិករ (ប្រអប់ទី២)។ ការយល់ដឹងពីតម្រូវការសម្រាប់ភាពជោគជ័យនៃវិស័យនេះកំពុងតែកើនឡើង។ ឧទាហរណ៍ នៅតំបន់ដីសណ្តទន្លេមេគង្គ រដ្ឋាភិបាលនៃប្រទេសវៀតណាមទើបតែបញ្ចប់រួចរាល់នូវឯកសារជាគោលការណ៍មួយដែលផ្តោតទៅលើការបង្កើតនូវបរិស្ថានដែលអាចយកជ័យជំនះលើបញ្ហាបច្ចេកវិទ្យា។ ប៉ុន្តែ ជាសត្យានុម័តការផ្ទេរ និងផ្តល់បច្ចេកទេសទៅដល់កសិករ និងគ្រួសារនៅជនបទត្រូវការពេលវេលាយូរ។

រដ្ឋាភិបាល និងស្ថាប័នក្រៅរដ្ឋាភិបាលដែលបានចូលរួមក្នុងការផ្សព្វផ្សាយ គឺជាការងារសំខាន់សម្រាប់ជោគជ័យនៃវារីវប្បកម្ម។ បើមិនមានការផ្សព្វផ្សាយសមស្រប និងការជួយឧបត្ថម្ភទេ នោះវារីវប្បកម្មនឹងអាចបរាជ័យ។ ឧទាហរណ៍ ចំនួនស្រះយ៉ាងច្រើនត្រូវបានជីកដោយអង្គការក្រៅរដ្ឋាភិបាល (NGOs) និងស្ថាប័នអន្តរជាតិនៅក្នុងប្រទេសកម្ពុជា ក្នុងកំឡុងចុងឆ្នាំ១៩៨០ និងឆ្នាំ១៩៩០ តែបានធ្វើការបណ្តុះបណ្តាល និងការផ្សព្វផ្សាយឡើយ ដែលនាំឱ្យការអនុវត្តមិនបានល្អ ហើយភាពជោគជ័យក្នុងវិស័យនេះនៅមានកំរិត។ អ្នកផ្សព្វផ្សាយក៏ត្រូវមានការយល់ដឹងអំពីតម្រូវការនៃកសិករចិញ្ចឹមត្រីផងដែរ ឧទាហរណ៍ ដូចជា ស្ត្រី (មើលប្រអប់ ទី៣) ឬ អ្នកដែលនិយាយភាសាជាតិមិនសូវបានល្អ ។

**ប្រអប់ទី៣ : ស្ត្រីជាគោលដៅក្នុងការផ្សព្វផ្សាយវារីវប្បកម្ម**

ខណៈពេលដែលស្ត្រីមិនបានចូលរួមក្នុងដំណាក់កាលនៃវារីវប្បកម្ម ស្ត្រីជាគោលដៅមួយក្នុងការផ្សព្វផ្សាយវារីវប្បកម្ម។ សកម្មភាព បណ្តុះបណ្តាល និងការជួបជុំគ្នា (ប្រជុំ) នាពេលថ្ងៃ ជារឿយៗតែងតែចំពេលដែលស្ត្រីជាប់រវល់កិច្ចការផ្ទះ។ ស្ត្រីមិនអាចធ្វើដំណើរពីភូមិមួយទៅភូមិមួយ និងមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួមវគ្គបណ្តុះបណ្តាល។ ការផលិតកូនត្រីពូជគឺជាសកម្មភាពមួយដែលសក្តិសមចំពោះស្ត្រីក្នុងការចូលរួមចំណែក ព្រោះទីកន្លែងផលិតកម្មគឺស្ថិតនៅជិតផ្ទះ។

នៅក្នុងតំបន់អាងទឹកទន្លេមេគង្គ បុគ្គលិកផ្សព្វផ្សាយមានចំនួនតិច បើប្រៀបធៀបទៅនឹងចំនួនកសិករ។ នៅក្នុងខេត្តទៀនយាង (Tien Giang) នៃប្រទេសវៀតណាម គម្រោង READ បានធ្វើការប៉ាន់ស្មានថា មានចំនួនបុគ្គលិកផ្សព្វផ្សាយវារីវប្បកម្មតែ ១០ នាក់ប៉ុណ្ណោះសម្រាប់ ៣៥០.០០០ គ្រួសារ តែនៅក្នុងប្រទេសកម្ពុជា និងប្រទេសឡាវមានតែបុគ្គលិកផ្សព្វផ្សាយវារីវប្បកម្មតែម្នាក់ប៉ុណ្ណោះសម្រាប់មួយខេត្ត ។ ស្ថានភាពនេះហាក់ដូចជាមិនមានការផ្លាស់ប្តូរទេនាពេលអនាគត ហេតុដូច្នេះហើយការបញ្ចូលនូវរបៀបថ្មីស្តីពីការផ្សព្វផ្សាយ និងភាពជាដៃគូរត្រូវតែធ្វើឱ្យមានសន្ទុះឡើង។ វាមានកត្តាជោគជ័យជាច្រើន ដូចជាការប្រើប្រាស់នូវសេវាផ្តល់កូនត្រីពូជជាលក្ខណៈឯកជនដើម្បីបំពេញនូវសកម្មភាពផ្សព្វផ្សាយរបស់រដ្ឋាភិបាល។ នៅប្រទេសឡាវ ក្រុមកសិករដែលត្រូវបានបង្កើត ហើយបានទទួលជោគជ័យដោយសារតែការជួយដោយខ្លួនឯង និងការផ្សព្វផ្សាយរបស់រដ្ឋាភិបាល (មើលប្រអប់ទី៤)។ រយៈពេល ១០ ឆ្នាំកន្លងមកនេះ បានឃើញនូវភាពជោគជ័យមួយចំនួនក្នុងការងារផ្សព្វផ្សាយនៅក្នុងតំបន់អាងទន្លេមេគង្គ ហើយឥឡូវនេះការបញ្ចូលនូវបច្ចេកទេសថ្មីៗក៏កាន់តែប្រសើរជាងពេលមុនដែរ។ ដើម្បីឆ្លើយតបតាមតម្រូវការ ការងារនាពេលអនាគតត្រូវតែផ្តោតជាសំខាន់ទៅលើការបញ្ចូលនូវបច្ចេកទេសថ្មីៗ ដែលធ្វើបែបនេះនឹងអាចនាំមកនូវកត្តាជោគជ័យ។

ស្ថាប័នមួយចំនួនធំ ដូចជាអ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាល (NGOs) ដែលគាំទ្រដល់វារីវប្បកម្មគឺជាផ្នែកមួយនៃការអភិវឌ្ឍតំបន់ជនបទជួយសម្របសម្រួលនូវតម្រូវការ និងធ្វើឱ្យមានប្រសិទ្ធភាពក្នុងការទំនាក់ទំនងកាន់តែប្រសើរឡើង។

## ១.៧. វារីវប្បកម្ម និង បរិស្ថាន

ដំណើរការនៃវារីវប្បកម្មអាចជះឥទ្ធិពលដល់បរិស្ថានដែលនៅជុំវិញ ហើយវាក៏អាចទទួលផលពីបរិស្ថានជុំវិញផងដែរ។ វារីវប្បកម្មលក្ខណៈគ្រួសារអាចជួយឱ្យបរិស្ថានមានភាពប្រសើរឡើង ប៉ុន្តែអន្តរអំពើរវាងតម្រូវការនៃការចិញ្ចឹមត្រី និងតម្រូវការនៃសកម្មភាពផ្សេងៗនៃប្រព័ន្ធបរិស្ថានជុំវិញត្រូវតែគិតគូរពិចារណាក្នុងការអភិវឌ្ឍវារីវប្បកម្មនៅក្នុងតំបន់អាងទឹកទន្លេមេគង្គនេះ។

### ១.៧.១.វារីវប្បកម្មផ្តល់ផលវិជ្ជមានចំពោះបរិស្ថាន

ទឹកស្រះចិញ្ចឹមត្រីលក្ខណៈគ្រួសារអាចប្រើសម្រាប់សត្វពាហនៈ សម្រាប់ស្រោចដំណាំបន្លែ ព្រមទាំងជាប្រភពទឹកនៅរដូវប្រាំង

**ប្រអប់៤ : អ្នកផលិតកូនត្រីពូជ ជាអ្នកផ្សព្វផ្សាយ**

យុទ្ធសាស្ត្រជាមូលដ្ឋានដើម្បីផ្សព្វផ្សាយក្នុងការផ្លាស់ប្តូរយោបល់ និងការកកើតឡើងដំណាលគ្នានៃប្រព័ន្ធផ្គត់ផ្គង់ និងចែកចាយកូនត្រីពូជ។ ជាទូទៅនៅពេលដែលការផ្គត់ផ្គង់កូនត្រីពូជត្រូវបានបង្កើតឡើងហើយមិនអាចឆ្លើយតបតាមតម្រូវការបាន ការនេះបានជម្រុញទឹកចិត្តដល់កសិករដទៃទៀតងាកមកចូលរួមក្នុងផលិតកម្មកូនត្រីពូជវិញ។ កង្វះខាតនៃធនធានដែលជាតម្រូវការសម្រាប់គាំទ្រការផ្សព្វផ្សាយរយៈពេលវែង កសិករត្រូវតែក្លាយទៅជាអ្នកឯកទេសក្នុងដំណាក់កាលនៃការទទួលផលត្រីម្តង ឬពីរដង។ ការផ្តោតទៅលើផលិតកម្មផលិតកូនពូជ គឺត្រូវកំណត់ចំនួនកសិករដែលត្រូវជួយ ប៉ុន្តែមិនមានចំនួនច្រើនទេចំនួនតិចទើបជាការល្អ។ នៅពេលដែលរដ្ឋាភិបាលគាំទ្រផលិតកម្មផលិតកូនត្រីពូជនៅក្នុងតំបន់ដាច់ស្រយាល កសិករដែលមកពីតំបន់ដាច់ស្រយាលផ្សេងៗជាច្រើនទៀតអាចទទួលបានកូនត្រីពូជទាំងនេះ។ អ្នកផលិតកូនត្រីពូជអាចជាអ្នកបណ្តុះបណ្តាលដ៏មានប្រសិទ្ធភាពមួយ ពីព្រោះពួកគេតែងតែមានការយល់ដឹងបានល្អថាតើអ្វីទៅដែលអាចសម្រេចបាននៅក្រោមលក្ខណ្ឌនៃតំបន់នេះ? វាត្រូវបានគេទទួលស្គាល់ហើយឬនៅថា អ្នកផលិតកូនត្រីពូជ និងអ្នកជំនួញមិនបានផ្តល់ជាជំនួយដល់ភាពក្រីក្រទេនោះ? តែយ៉ាងណាក៏ដោយពួកគេអាច ជួយកាត់បន្ថយបាននូវការកើតឡើង ជាយថាហេតុដល់គ្រួសារក្រីក្រដែលពាក់ព័ន្ធវារីវប្បកម្មផងដែរ។ យុទ្ធសាស្ត្រគាំទ្ររយៈពេលវែងដល់អ្នកផលិតកូនត្រីពូជតាមរយៈផ្តល់ត្រីពូជអាចកាត់បន្ថយថ្លៃនៃការផ្សព្វផ្សាយ ប៉ុន្តែការប៉ះពាល់នឹងអាចរីកកាន់ តែធំឡើងដល់ក្រុមគោលដៅ។

ផងដែរ។ ការរួមបញ្ចូលគ្នានៃស្រះចិញ្ចឹមត្រីជាច្រើនចូលក្នុងបណ្តាញទឹក (ប្រឡាយ) អាចបង្កើននូវគុណប្រយោជន៍ដល់វារិជាតនៅតាមវាលស្រែផងដែរ។ ប្រាក់ចំណូលដែលបានមកពីផលិតកម្មត្រីគឺច្រើនជាងប្រាក់ចំណូលដែលបានមកពីផលិតកម្មស្រូវ ហើយជាទូទៅតម្រូវការទឹកសម្រាប់សកម្មភាពវារីវប្បកម្មតិចជាងទៀតផង។ មិនតែប៉ុណ្ណោះស្រះចិញ្ចឹមត្រីបានផ្តល់ផងដែរនូវវត្ថុនៃចំណីនិងសារធាតុសរីរាង្គសម្រាប់ត្រីផងដែរ។ ជាការរួមចំណែកក្នុងយុទ្ធសាស្ត្រនៃការចិញ្ចឹមជីវិតគ្រួសារ ស្រះចិញ្ចឹមត្រីគឺជាទ្រព្យធុនយ៉ាងសំខាន់សម្រាប់ចិញ្ចឹមទ្រង់ទ្រាយជីវភាពរស់នៅបន្ថែមទៀត។

## ១.៧.២.ឥទ្ធិពលលើបរិស្ថានដែលកើតឡើងក្រៅពីវារីវប្បកម្ម

លក្ខ័ណ្ឌបរិស្ថានជះឥទ្ធិពលយ៉ាងខ្លាំងមកលើវារីវប្បកម្មបង្កឡើងដោយភាពប្រែប្រួលនៃអាកាសធាតុធម្មជាតិ ឬបំរែបំរួលដែលបង្កដោយមនុស្ស។ ឧទាហរណ៍ នៅក្នុងប្រទេសឡាវ ស្រះចិញ្ចឹមត្រីជាច្រើនគឺធ្វើឡើងតាមរដូវកាលដោយសារមានរដូវរាំងស្ងួតរយៈពេល ៦ ខែ។ ស្រះចិញ្ចឹមត្រីឆាប់រាក់ និងឆាប់ស្ងួតណាស់ ហើយសីតុណ្ហភាពខ្ពស់ក៏អាចជាបញ្ហាមួយផងដែរ។ ភ្លៀងច្រើនក្នុងរដូវវស្សាអាចបង្កឱ្យមានទឹកជំនន់ភ្លាម១ដែលអាចឱ្យត្រីរួចចេញពីស្រះចិញ្ចឹមបាន។

ក្នុងតំបន់ដីសណ្តទន្លេមេគង្គនៃប្រទេសវៀតណាម ទឹកជំនន់ធំបានបង្កនូវការខូចខាតយ៉ាងខ្លាំងដល់វារីវប្បកម្ម តែទោះបីជាយ៉ាងណាក៏ដោយ ការបាត់បង់ត្រូវបានកាត់បន្ថយដោយសារត្រីធម្មជាតិចូលក្នុងស្រះចិញ្ចឹមត្រីជំនួសវិញ។ ស្រះចិញ្ចឹមត្រីនៅកន្លែងមិនល្អ ដូចជាស្រះទប់ទឹកក្នុងអូរទប់ទឹកក្នុងតំបន់ភ្នំនៃប្រទេសឡាវគឺងាយទទួលរងនូវការខូចខាតដោយសារទឹកជំនន់។ ទឹកជំនន់និងការរាំងស្ងួតដែលបង្កឡើងដោយធម្មជាតិនៃអាកាសធាតុមូសុងអាចនឹងកាន់តែធ្ងន់ធ្ងរឡើងទៀត ដោយសារតែការកាប់ ឆ្ការព្រៃនិងគម្រោងការគ្រប់គ្រងទឹកដែលមិនពិចារណាឱ្យគ្រប់ជ្រុងជ្រោយ។ ដូចគ្នានោះ ការបែងចែកទឹកទៅឱ្យស្រះចិញ្ចឹមត្រីអាចជះឥទ្ធិពលមិនល្អដល់អ្នកប្រើប្រាស់ទឹកដទៃទៀត។

សកម្មភាពផ្សេង១របស់មនុស្សក៏អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វារីវប្បកម្មដែរ ដូចជាការបោះចោលនូវកាកសំណល់បំពុលចូលក្នុងទន្លេ និងប្រព័ន្ធប្រឡាយដោយអ្នកដែលនៅដើមទឹកអាចធ្វើឱ្យប៉ះពាល់ខូចខាតស្រះវារីវប្បកម្មនៅភាគខាងក្រោមនោះនេះគឺជាការព្រួយបារម្ភយ៉ាងខ្លាំងមួយនៅក្នុងតំបន់ដីសណ្តទន្លេមេគង្គ ព្រោះថាទីនេះមានប្រជាជនច្រើន។ កាកសំណល់បង្កអន្តរាយដែលអាចកើតមានឡើងនៅក្នុងអាងទឹកទន្លេមេគង្គមានដូចជា ថ្នាំសម្លាប់សត្វចង្រៃ និងកាកសំណល់រាវដែលសល់ពីដំណើរការផលិតស្បែក និងស្ករ។ ថ្នាំសម្លាប់សត្វប្រើនៅក្នុងវាលស្រែអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ការចិញ្ចឹមត្រីនៅក្នុងវាលស្រែដែរ។ តែទោះជាយ៉ាងណាក៏ដោយ ការបង្វែរមកប្រើបច្ចេកវិទ្យាការគ្រប់គ្រងសត្វល្អិតចំរុះ (Integrated Pest Management) អាចបន្ថយកម្រិតការប្រើថ្នាំសម្លាប់សត្វល្អិត ហើយវាក៏ផ្តល់នូវភាពប្រសើរឡើងដល់ត្រី និងទិន្នផលស្រូវដែរ។ ការសម្រេចបានបែបនេះ ត្រូវបានយកចិត្តទុកដាក់ជាសំខាន់បន្ថែមទៀតនៅតំបន់ដីសណ្តទន្លេមេគង្គនៃប្រទេសវៀតណាមដែលប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងផលវិបាកចំពោះសុខភាព និងបរិស្ថាន (Anon 2002)។

## ១.៧.៣.ការជះឥទ្ធិពលលើបរិស្ថានដែលកើតមានឡើងក្នុងរង្វង់នៃវារីវប្បកម្ម

វារីវប្បកម្មអាចនាំទៅដល់ការជះឥទ្ធិពលមិនល្អទៅលើបរិស្ថាន រួមមានការជះឥទ្ធិពលទៅលើអ្នកប្រកបរបរអាជីវកម្មនេសាទត្រីពីបឹងធម្មជាតិ។ បញ្ហាបរិស្ថានទាំងនេះគឺគួរត្រូវបានធ្វើការវាយតម្លៃ និងគ្រប់គ្រងឱ្យបានសមស្រប ទោះបីជាការជះឥទ្ធិពលមានតិចតួចជាងវិស័យផ្សេង១ក្រៅពីវារីវប្បកម្មក៏ដោយ។

ផលិតកម្មវារីវប្បកម្មនៅក្នុងតំបន់អាងទន្លេមេគង្គពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រភេទត្រីនាំចូលពីបរទេស ដូចជាត្រីកាប និងត្រីទីឡាព្យ៉ាដែលជារឿយ១រួចចូលទៅក្នុងបឹងធម្មជាតិ ហើយអាចផ្តល់ផលប៉ះពាល់ដល់ប្រភេទត្រីផ្សេង១ក្នុងបឹងធម្មជាតិ (Welcomme and Vidthayaonon 1999)។ គោលនយោបាយរបស់រដ្ឋាភិបាលក្នុងតំបន់ទន្លេមេគង្គ បានផ្តោតជាសំខាន់ទៅលើការចិញ្ចឹមប្រភេទត្រីក្នុងស្រុក។ សេចក្តីសំអាងឱ្យមានការចិញ្ចឹមប្រភេទត្រីក្នុងស្រុកជាជាងប្រភេទត្រីនាំចូលពីបរទេសគឺដើម្បីកាត់បន្ថយភាពគ្រោះថ្នាក់ដល់វារីជីវសាស្ត្រចំរុះក្នុងអាងទឹកទន្លេមេគង្គដែលបណ្តាលមកពីការរាតត្បាតនៃប្រភេទត្រីក្រៅស្រុក។ ការទទួលជោគជ័យរហូតមកដល់បច្ចុប្បន្នបានបង្ហាញឱ្យឃើញថា ប្រភេទត្រីក្នុងស្រុកគឺទទួលបាននូវប្រាក់កម្រៃច្រើនជាងប្រភេទត្រីនាំចូល ហើយប្រភេទត្រីទាំងនោះត្រូវបានយកមកចិញ្ចឹមផងដែរ។ ឧទាហរណ៍ នៅប្រទេសឡាវ ត្រីឆ្កិនត្រូវបានកសិករផលិតកូនត្រីពូជ និងកសិករចិញ្ចឹមត្រីចាប់យកវាមកចិញ្ចឹម ហើយគេអាចផលិតកូនត្រីពូជបានស្រួល ដោយត្រីឆ្កិនមានភាពងាយស្រួលក្នុងការបង្កាត់ភ្ញាស់ ។

ការជ្រើសរើសប្រភេទត្រីក្នុងស្រុកសម្រាប់វារីវប្បកម្មក៏មានផងដែរនូវកម្មវិធីគ្រប់គ្រងត្រីមេពូជ ដើម្បីរក្សានានាភាពនៃសេនេទិច (Genetic diversity) ។ ឧទាហរណ៍ នៅក្នុងប្រទេសថៃ មានការបង្ហាញជាភស្តុតាងឱ្យដឹងពីការបាត់បង់នូវភាពផ្សេង១គ្នានៃសេនេទិចតាមរយៈស្ថានីយ៍ភ្ញាស់ត្រីផ្តិន ។ ហេតុដូច្នេះ នៅពេលដែលមានភាពពេញចិត្តទៅលើប្រភេទត្រីក្នុងស្រុក នោះគឺជាសញ្ញាវិជ្ជមានមួយដល់បរិស្ថាន ។ ដើម្បីទទួលជោគជ័យជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពលើការគ្រប់គ្រងត្រីមេពូជ និងប្រភេទត្រីដែលត្រូវកាត់បន្ថយការចិញ្ចឹមចំរុះ និងពូជផ្សេង១គ្នា ។

ជំងឺត្រីមួយចំនួនមានកើតឡើងនៅក្នុងអាងទន្លេមេគង្គ វានឹងអាចរីករាលដាលយ៉ាងធំ ហើយបង្កឱ្យមានបញ្ហារឹតតែខ្លាំងឡើងនាពេលអនាគត ប្រសិនបើមានការពង្រីកវារីវប្បកម្មជាទ្រង់ទ្រាយធំ និងវិបុលវប្បកម្ម (Intensive culture) ។ ជំងឺកើតឡើងជាលក្ខណៈទ្រង់ទ្រាយធំតាំងពីមានការរាតត្បាតដោយជំងឺដំបៅរលួយ (epizootic ulcer) នាឆ្នាំ ១៩៨០ មក តែការកើតឡើងធ្ងន់ធ្ងរ និងជួនកាលក្នុងកម្រិតស្រាល ភាពរាំរៃ បញ្ហាសុខភាពត្រី ត្រូវកើតឡើងចំពោះការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ។ ថ្មី១នេះមានការកើតឡើងនៃជំងឺលើបង្កងនៅតំបន់ដីសណ្តទន្លេមេគង្គ និងការចិញ្ចឹមត្រីតាមបែ តាមដងទន្លេមេគង្គ និងទន្លេបាសាក់ និងអាងស្តុកទឹកនៅក្នុងប៉ែកកណ្តាលនៃប្រទេសវៀតណាម បានទទួលរងនូវការបាត់បង់ត្រីអស់ក្នុងរយៈពេល ៥ ឆ្នាំកន្លងទៅ ។

ការឆ្លងមេរោគដល់មនុស្សដោយមេរោគដង្កូវថ្លើម (ព្រូនរាងសំប៉ែត) គឺជាការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសុខភាពមនុស្សនៅកន្លែងមួយចំនួននៃអាងទន្លេមេគង្គ ដោយសារបរិភោគត្រីឆៅ (WHO 1999) ។ វារីវប្បកម្មអាចកាត់បន្ថយនូវការឆ្លងមេរោគនៃសត្វព្រូនសំប៉ែត តែវាក៏ជាប្រភពនៃមេរោគឆ្លងដែរ ។ នៅប្រទេសឡាវ ការឆ្លងមេរោគព្រូនសំប៉ែតដល់ត្រីក្នុងធម្មជាតិកើតមាននៅទន្លេ អូរ និងវាលស្រែដែលប្រើបង្គន់ ។ ប៉ុន្តែនៅក្នុងប្រទេសឡាវ ការឆ្លងមេរោគពីត្រីចិញ្ចឹម គឺហាក់ដូចជាមានតិចតួចចាប់តាំងពីឈប់ប្រើលាមកមនុស្សក្នុងទឹកស្រះចិញ្ចឹមត្រី ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានបង្គន់ជាច្រើនស្ថិតនៅក្នុងស្រះចិញ្ចឹមត្រីក្នុងតំបន់ដីសណ្តទន្លេមេគង្គ ។ អ្នកសិក្សារោគរាតត្បាត (epidemiology) បានសិក្សាទៅលើតួនាទីក្នុងការបង្កនូវមេរោគឆ្លងគឺនៅមានភាពខ្វះចន្លោះ ។ កត្តាដែលកើតឡើងជាយថាហេតុ និងយុទ្ធសាស្ត្រគ្រប់គ្រងការពារគឺតម្រូវឱ្យមានការស្រាវជ្រាវបន្ថែមទៀត ។ នៅប្រទេស វៀតណាម លាមករបស់មនុស្សត្រូវបានយកមកប្រើប្រាស់ជាជីសម្រាប់ស្រះចិញ្ចឹមត្រី ទោះបីជាការអនុវត្តនេះត្រូវបានហាមឃាត់ដោយរដ្ឋាភិបាលក៏ដោយ ។ ពិតមែនហើយវាអាចមានបរិស្ថានល្អប្រសើរដែលប្រើស្រះដូចជាបង្គន់ ជាជាងការចាក់ចោលលាមកមនុស្សនៅជុំវិញកសិដ្ឋាននោះ ។

ការផ្លាស់ប្តូរតំបន់ដីសើម និងដីស្រែឱ្យទៅជាស្រះចិញ្ចឹមត្រីនោះ វានាំឱ្យមានការបាត់បង់តំបន់ដីសើម និងធនធានត្រីក្នុងធម្មជាតិ ។ បញ្ហាទាំងនេះត្រូវតែជៀសវាងដោយបង្កើតនូវគម្រោងជោគជ័យមួយដែលគិតគូរពិចារណាទៅលើវារីវប្បកម្ម និងធនធានត្រីក្នុងធម្មជាតិ ។ វារីវប្បកម្មគួរតែបន្ថែម "តម្លៃ" ជាធនធានធម្មជាតិ និងការចិញ្ចឹមជីវិតរបស់ប្រជាជនដែលពឹងផ្អែកលើធនធានធម្មជាតិ ។

ការព្រួយបារម្ភមួយទៀតអំពីបរិស្ថាន គឺទាក់ទងនឹងការចិញ្ចឹមប្រភេទត្រីដែលស៊ីសាច់ជាអាហារ ដោយយកត្រីពីធម្មជាតិធ្វើជាចំណីដើម្បីទ្រទ្រង់ដល់ការចិញ្ចឹមត្រីប្រភេទនេះ ។ នេះជាការព្រួយបារម្ភចំពោះការចិញ្ចឹមត្រីតាមបែនៃប្រភេទត្រីរស់ និងត្រីប្រានៅក្នុងប្រទេសកម្ពុជា និងប្រទេសវៀតណាម ។ បរិស្ថាន ឬភាពជាប់ទាក់ទងគ្នានូវចំណីអាហាររបស់មនុស្សក្នុងការប្រើប្រាស់នូវបរិមាណត្រីយ៉ាងច្រើនសម្រាប់ជាអាហារគឺមិនត្រូវបានដោះស្រាយទេ ។ ឧទាហរណ៍ សកម្មភាពទាំងនេះដូចជាការយកចំណីអាហារពីក្រុមប្រជាជនអ្នកក្រីក្រតើនេះជាការគួរអនុវត្តដែរទេ? តើគួរតែទិញទឹកកកដែលមានតម្លៃថោកយកមកក្លាស្សេបង្កើននូវគុណភាពត្រីទាំងនោះឬ? តើអាចកែច្នៃត្រីទាំងនោះលក់នៅទីផ្សារបានដែរឬទេ? តើអាចផលិតត្រីទាំងនោះជាចំណីបានទេ? ដើម្បីយល់ដឹងនូវបញ្ហាទាំងនេះឱ្យកាន់តែច្បាស់ តាមរយៈការសិក្សាអំពីចំណី និងជីវសេដ្ឋកិច្ចនៃប្រភេទត្រីនីមួយ១ គឺតម្រូវឱ្យមានការគាំទ្រដល់គោលនយោបាយក្នុងការប្រើប្រាស់នូវធនធានឱ្យមានតម្លៃ ។

នៅក្នុងប្រទេសកម្ពុជា ភាគច្រើនកូនត្រីពូជដែលដាក់ចិញ្ចឹមបានមកពីស្ថានីយ៍ភ្ញាស់ត្រី ឧទាហរណ៍ ដូចជាកូនត្រីប្រា និងត្រីរស់បង្កងនៅក្នុងប្រទេសវៀតណាម និងមានប្រភេទត្រីមួយចំនួនតូច ដូចជាប្រភេទត្រីដំរី ត្រូវបានចាប់ពីធម្មជាតិ ។ នៅប្រទេសវៀតណាមនាពេលថ្មី១នេះ ការបង្កាត់ត្រីប្រាប្រភេទត្រីប្រាអៀវ និងត្រីប្រា *(Pangasius bocourti* និង *Pangasianodon hypophthalmus)* បានទទួលជោគជ័យដែលមានកសិករជាច្រើនចិញ្ចឹមកូនត្រីពូជប្រភេទនេះ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏កសិករចិញ្ចឹមនៅតែចូលចិត្ត

កូនត្រីពូជដែលចាប់ពីធម្មជាតិ។ នៅតាមដីសណ្តទន្លេមេគង្គមានការកើនឡើងនូវវារីវប្បកម្មបង្កង ដែលកូនបង្កងទាំងនោះបានមកពីស្ថានីយ៍ ជាពិសេសបន្ទាប់ពីកូនញាស់ តើនេះបណ្តាលមកពីការចុះថយកូនបង្កងក្នុងធម្មជាតិឬ? ឬក៏មានតម្រូវការច្រើន? ឬក៏មាន ការថយចុះក្នុង ធម្មជាតិ និងមានតម្រូវការច្រើន? ទាំងអស់នេះ គឺមិនទាន់បានដឹងនៅឡើយទេ។ គ្មានភស្តុតាងណាដែលថា ការចាប់បង្កងពេញវ័យ បានបង្កមហន្តរាយដល់ប្រភពធនធាននោះទេ តែទោះជាយ៉ាងណាក៏ដោយ ប្រភេទផ្សេងទៀតត្រូវបាន បោះបង់ ចោល។

តាមរយៈការរកឃើញក្នុងអាងទន្លេមេគង្គទាំងមូល ទឹក និងកករ ដែលបានប្រើដីក្នុងស្រះចិញ្ចឹមត្រីជាលក្ខណៈពាក់កណ្តាលវិបុលវប្បកម្ម អាចផ្តល់ផលប្រយោជន៍យ៉ាងខ្លាំងដល់ទិន្នផលស្រូវ និងមិនមានផលប៉ះពាល់ដល់បរិស្ថានឡើយ។ ប៉ុន្តែផ្ទុយមកវិញការចិញ្ចឹមត្រីជាលក្ខណៈប្រពលវប្បកម្ម ជាពិសេសការចិញ្ចឹមត្រីតាមបៃ ដែលទឹកត្រូវបានបញ្ចេញមកដោយផ្ទាល់ចូលទៅក្នុងមជ្ឈដ្ឋានទឹកដោយមិនបានសំលាប់មេរោគ គឺធ្វើឱ្យទឹកមានជាតិពុល នាំឱ្យទឹកអន់គុណភាព ហើយត្រីកើតជំងឺ ជាឧទាហរណ៍ ការចិញ្ចឹមត្រីកាបតាមបៃនៅអាងទឹកដាក់ឡាក់។ ការអភិវឌ្ឍការចិញ្ចឹមត្រីតាមបៃជាលក្ខណៈទ្រង់ទ្រាយធំអាចឱ្យអ្នកនេសាទត្រីតាមបែបបុរាណឈប់ចាប់ត្រីបឹងធម្មជាតិ។ បញ្ហាទាំងអស់នេះអាចផ្តោតជាសំខាន់តាមរយៈការគ្រប់គ្រងបៃចិញ្ចឹមត្រី ដែលអាចកាត់បន្ថយភាពខាតបង់ចំណី ការជ្រើសរើសទីតាំងសម្រាប់ដាក់បៃចិញ្ចឹមត្រី និងគ្រប់គ្រងរៀបចំទីកន្លែងបៃដែលអាចកាត់បន្ថយនូវជំលោះហើយអាចរក្សាបាននូវចំនួនបៃចិញ្ចឹមត្រី និងទិន្នផលត្រីក្នុងមួយខ្នាតនៃបរិមាណទឹក។

# ការវិភាគអនុវិស័យវារីវប្បកម្ម ២

## ២.១ ការអភិវឌ្ឍ ឱកាស និង ការគំរាមកំហែង

### ២.១.១ វារីវប្បកម្ម តួនាទីក្នុងសុវត្ថិភាពស្បៀង និង ជីវភាពរស់នៅ

វារីវប្បកម្មទឹកសាបនៅបន្ថែមចំណែកដល់សន្តិសុខស្បៀង និងលើកកំពស់ជីវភាពរបស់ប្រជាជនក្រីក្រក្នុងចំណោមប្រជាជនដែលរស់នៅតំបន់ទន្លេមេគង្គក្រោមទាំងក្នុងទ្រង់ទ្រាយធំ និងទ្រង់ទ្រាយតូច។

ចំពោះទ្រង់ទ្រាយធំ អាងទន្លេមេគង្គត្រូវការផលិតផលវារិជាតគ្រប់យ៉ាងដើម្បីបំពេញការប្រើប្រាស់របស់មនុស្ស។ ជាង ១០ឆ្នាំទៅមុខនឹងត្រូវការប្រភពត្រីបន្ថែមទៀត ដូច្នេះវារីវប្បកម្មនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការឆ្លើយតបនូវតម្រូវការនេះ។ តាមការគណនាលើកដំបូងដោយផ្អែកលើតួលេខដែលបានផ្តល់ដោយគំរោងគណៈកម្មការទន្លេមេគង្គ ស្នើឡើងត្រូវការត្រីប្រមាណ ២.៤៤០.០០០តោន ក្នុងរយៈពេល ១០ ឆ្នាំ (ប្រអប់៥)។ ដូច្នេះតាមការប្រមាណ ផលិតផលវារីសត្វ ៤៤០.០០០ តោន បន្ថែមទៀតនឹងត្រូវការចាំបាច់ក្នុងអាងមេគង្គក្រោម ដើម្បីបំពេញសេចក្តីត្រូវការនៅពេលបច្ចុប្បន្ន។ ការប៉ាន់ប្រមាណនេះ គឺមិនប្រាកដប្រជាប៉ុន្មានទេ ដោយសារគេមិនដឹងនូវភាគជាច្រើនទៀតប៉ុន្តែវាក៏បានចង្អុលបង្ហាញពីទំហំនៃបញ្ហា។ ដោយតម្រូវការផលិតផលវារិជាតកើនឡើងឆ្លើយតបនឹងបំពេញតំរូវការតាមគ្រប់មធ្យោបាយ ផ្សេងៗទៀត។ ផលិតផលផលផលដែលចាប់បានជាប្រភពមួយ ទោះបីយ៉ាងណាក៏ដោយទិន្នផលសមស្របមិនត្រូវបានគេដឹងច្បាស់លាស់ទេ ហើយបញ្ហាបានកើតឡើងយ៉ាងច្បាស់កាលពីជាង ១០ ឆ្នាំមុន។ ផលស្តុក និងការប្រមូលផលធម្មជាតិប្រហែលអាចចូលរួមចំណែកផងដែរ។ ការកែលំអហេដ្ឋារចនាសម្ព័ន្ធនឹងមានផលប៉ះពាល់ដែលនឹងផ្តល់ឱកាសដ៏សំខាន់ដល់ការនាំចូលត្រី (ដូចជាករណីការដឹកជញ្ជូនត្រីទឹកសាប និងទឹកប្រៃពីភាគកណ្តាលប្រទេសថៃទៅកាន់តំបន់ជាយក្រុងប៉ៃកញ្ញសានប្រទេសថៃ)។ ប្រសិនបើគ្មានត្រីទេប្រជាជនប្រហែលជំនួសប្រភពប្រូតេអ៊ីនផ្សេងទៀតទោះបីប្រូតេអ៊ីនទាំងនេះមិនមែនជាសារធាតុដ៏ល្អប្រសើរសម្រាប់ការចិញ្ចឹមជីវិតដល់រាងកាយក៏ដោយ ដោយសារតែកង្វះខាតនូវប្រូតេអ៊ីនសត្វ។

**ប្រអប់៥: កំណើនប្រជាជន និង ការប៉ាន់ប្រមាណទិន្នផលត្រី**

តាមការគ្រោងទុក កំណើនប្រជាជននៅក្នុងអាងទន្លេមេគង្គមាន ២% ក្នុងមួយឆ្នាំដូចនេះ តម្រូវការសាច់ត្រីគេរំពឹងថា នឹងកើនឡើង ស្របជាមួយគ្នាដែរ ហើយក្នុងរយៈពេល១០ឆ្នាំ តម្រូវការត្រីនិងកើនដល់២២%។ ដោយផ្អែកលើការប៉ាន់ប្រមាណនៃការផ្គត់ផ្គង់ពេលបច្ចុប្បន្នមានប្រហែល ២លានតោនក្នុងមួយឆ្នាំ មានន័យថា ផលិតផល វារិជាតត្រូវការ បន្ថែមចំនួន ៤៤០.០០០ តោន។ តួរលេខទាំងនេះ ត្រូវការផ្ទៀង ផ្ទាត់តាមការស្រាវជ្រាវ និងការវិភាគ លំអិតបន្ថែម ប៉ុន្តែការស្នើឡើងថា ការផ្គត់ផ្គង់ត្រីត្រូវ បង្កើនឱ្យលើស ៤០.០០០តោន ក្នុងមួយឆ្នាំនៅទសវត្សក្រោយ គឺត្រឹមត្រូវដើម្បីថែរក្សា កំរិតការប្រើប្រាស់ពេលបច្ចុប្បន្ន។ គេនៅមិនទាន់ច្បាស់នៅឡើយទេថា តើទិន្នផលត្រីដែល បានមកពីធម្មជាតិអាចកើនតាមតម្រូវការនេះ ឬអត់? ហើយផលិតផលវារីវប្បកម្ម ដូចជា ការចិញ្ចឹមដោយផ្អែកលើធនធានជលផលដូចនេះអាចនឹងរំពឹងថានឹងកើនឡើងដែរឬទេ ដើម្បីចូលរួមចំណែកទៅផលតម្រូវការកើនឡើងនេះ។ ដូច្នេះវាដូចជាចំនងថាវារីវប្បកម្មនឹងក្លាយជាអ្នកចូលរួមចំណែកយ៉ាងចំបង ទៅដល់ការផ្គត់ផ្គង់ជាក់ស្តែង ផលិតផលវារីវប្បកម្មនៅ អាងទន្លេមេគង្គមាន ប្រហែល ២៦០.០០០ តោន ក្នុងមួយ ឆ្នាំ។ ការកើនឡើងយ៉ាង ច្រើននេះ គឺជាការមួយបញ្ជាក់ច្បាស់ថា មានប្រយោជន៍។ ប្រសិនបើមានវារីវប្បកម្មតែម្នាក់ឯងត្រូវបានស្នើឱ្យបំពេញកង្វះខាត ដូច្នេះ នៅឆ្នាំ២០១០នឹងត្រូវឱ្យមានទិន្នផលត្រីពីវារីវប្បកម្មប្រចាំឆ្នាំប្រមាណ ៧០០.០០០តោន ទើបអាចឆ្លើយបាននូវរាល់សេចក្តីត្រូវការរបស់មនុស្ស។

វារីវប្បកម្មគឺជាគន្លឹះយ៉ាងពិតប្រាកដនាំឱ្យមានការកើនឡើងទិន្នផលត្រីយ៉ាងសំខាន់នៅពេលអនាគត ទោះបីគេពិបាកនឹងព្យាករណ៍ទុកនូវបរិមាណរបស់វាក៏ដោយ។ ចំពោះវារីវប្បកម្មគឺជាសកម្មភាពមួយសម្រាប់បំពេញនូវកង្វះខាតដែលគេព្យាករណ៍ទុកគឺជាការចាំបាច់ដូចមានចង្អុលបង្ហាញនៅក្នុងប្រអប់ទី ៥ ដែលបានលើកឡើងការបង្កើនទិន្នផលត្រីចំនួន ៤០.០០០ តោនក្នុងមួយឆ្នាំ។ ការពង្រីកបន្ថែមកាលពីជាង ១០ ឆ្នាំមុន គឺបានកើនឡើង ៤ ដង មានប្រហែល ៦០.០០០ តោន ក្នុងឆ្នាំ ១៩៩០ ដល់ ២៦០.០០០ តោន ក្នុងឆ្នាំ ២០០០។ ការពង្រីកបន្ថែមនូវអត្រានេះ ពិតជាបានជួយបំពេញនូវការខ្វះខាតខាងម្ហូបអាហារ ទោះបីជាមានបញ្ហាលំបាកខ្លះក៏ដោយ។

នៅទូទាំងអាងទន្លេមេគង្គ វារីវប្បកម្មជាលក្ខណៈគ្រួសារបានផ្គត់ផ្គង់ដល់តម្រូវការសាច់ត្រីនៅក្នុងរូបភាពផ្សេងៗគ្នាហើយសក្តានុពលសម្រាប់វារីវប្បកម្មនេះមិនមានលក្ខណៈស្មើគ្នាទេ។ នៅក្នុងតំបន់ជាប់ទំនាបលិចទឹកដែលមានវិសាលភាពយ៉ាងធំ ការផ្គត់ផ្គង់ត្រីធម្មជាតិប្រហែលអាចត្រូវការទិន្នផលវារីជាតនៅតាមតំបន់មួយចំនួន ការផ្គត់ផ្គង់ត្រីក៏មានកំណត់ ហើយមានការខ្វះខាតសន្តិសុខស្បៀង (ដូចជាក្នុងតំបន់ខ្ពង់រាប ឬនៅឆ្ងាយពីតំបន់បឹងទន្លេសាប និងតាមបណ្តោយដងទន្លេមេគង្គក្នុងប្រទេសកម្ពុជា) វារីវប្បកម្ម អាចចូលរួមចំណែកដល់តម្រូវការថ្នាក់មូលដ្ឋាន។ ចំពោះតំបន់ដាច់ស្រយាលពីអាងទន្លេមេគង្គទាំងនេះមានសំបូរទៅដោយប្រជាជនមានជីវភាពក្រីក្រ (Haylor2001)។

យោងតាមបទពិសោធន៍ដែលបានស្នើឡើងបានបញ្ជាក់ថា ទីកន្លែងណាមានវត្ថុធាតុដើម និងតំរូវការទីផ្សារ (ជាពិសេសកូនត្រីពូជ) គឺជាកត្តាជំរុញឱ្យមានសេវាកម្មផ្គត់ផ្គង់ផងដែរ។ វារីវប្បកម្មដែលអនុវត្តដោយកសិករនៅតាមជនបទមានការរីកចំរើនយ៉ាងឆាប់រហ័ស (គណៈកម្មការទន្លេមេគង្គ) នៅតាមតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍ មានការកើនឡើងនូវចំនួនកសិករចិញ្ចឹមត្រីពី ២០-៣០ ភាគរយក្នុងរយៈពេល២ឆ្នាំកន្លងមកនេះ។ ករណីនេះវាមានភាពស្រដៀងគ្នាដែរទៅនឹងអត្រារីកចំរើននៃកសិករចិញ្ចឹមត្រីដែលត្រូវបានគេជួបប្រទះនៅតំបន់ភ្នំភាគខាងជើងប្រទេសឡាវ។ ដោយសារមានការផ្តល់នូវវត្ថុធាតុដើមជាពិសេសដូចជាកូនត្រីពូជ និងសេវាកម្មនានាសម្រាប់ផ្គត់ផ្គង់ដល់វិស័យវារីវប្បកម្ម នឹងអាចរួមចំណែកយ៉ាងសំខាន់ដល់តម្រូវការពេលអនាគត។

វាជាការសំខាន់ដែលបញ្ជាក់ថា ការគ្រប់គ្រងវារីវប្បកម្ម និងត្រីធម្មជាតិមិនគួរត្រូវបានគេចាត់ទុកឱ្យនៅដាច់ដោយឡែកពីគ្នាទេ។ ប៉ុន្តែសកម្មភាពដូចនេះបានដាច់ការទាក់ទងគ្នាចាប់តាំងពីកសិករចូលប្រឡូកក្នុងការងារទាំងពីរនេះយ៉ាងញឹកញាប់។ ទិសដៅនៃកិច្ចប្រឹងប្រែងអភិវឌ្ឍ និងគោលនយោបាយចំពោះវិស័យវារីវប្បកម្ម គឺជាការងាយស្រួលមួយដល់មធ្យោបាយនៃការបង្កើនផលិតផលត្រី។ ករណីដូចនេះបានកើតឡើងដោយសារមកពីពេលបច្ចុប្បន្នមានការបាត់បង់យ៉ាងខ្លាំងនូវធនធានត្រីធម្មជាតិ។ ប្រសិនបើមានការយកចិត្តទុកដាក់ទាំងលើត្រីធម្មជាតិ និងសកម្មភាពវារីវប្បកម្មសន្តិសុខស្បៀងក៏មិនអាចថយចុះផងដែរ ហើយក៏ជួយដល់ការលើកកំពស់ជីវភាពរស់នៅ ជាពិសេសសម្រាប់ប្រជាជនក្រីក្រ។

**ប្រអប់ទី ៦ : ស្រូវ និង ត្រី**

តម្រូវការប្រូតេអ៊ីនរបស់មនុស្សពេញវ័យគិតជាមធ្យមគឺនៅចន្លោះពី០.៨ ដល់ ១ ប្រូតេអ៊ីនក្នុងមួយគីឡូក្រាមនៃទម្ងន់ដងខ្លួនក្នុងមួយថ្ងៃដែលក្នុងនោះតំបន់ទន្លេមេគង្គគឺតែងតែបំពេញតំរូវការជាមូលដ្ឋានប្រចាំឆ្នាំ។ទោះបីយ៉ាងណាក៏ដោយ ជាធម្មតាក៏មានកង្វះខាតចំណីអាហារតាមរដូវកាលក្នុងតំបន់មួយចំនួន ដូច្នេះការតម្រូវឱ្យមានប្រូតេអ៊ីនគ្រប់គ្រាន់គឺត្រូវតែប្រើប្រាស់ប្រូតេអ៊ីនផ្សេងទៀតដែលមាននៅក្នុងចំណីអាហារមនុស្ស នៅពេលណាមានករណីកង្វះខាតចំណីអាហារ។ ទី ១ ជាងពាក់កណ្តាលនៃតម្រូវការប្រូតេអ៊ីនប្រចាំថ្ងៃត្រូវផ្តល់តាមរយៈអង្ករ និងចំណីអាហារ។ ទី ២ ក្នុងតំបន់ទំនាប (ដែលប្រជាជនភាគច្រើនរស់នៅទីនោះ) ប្រហែល ៤០-៨០ ភាគរយនៃប្រូតេអ៊ីនបានមកពីវារីសត្វ (គណៈកម្មការបណ្តោះអាសន្នសម្រាប់សម្របសម្រួលការអង្កេតតំបន់អាងទន្លេមេគង្គក្រោម ១៩៩២)។ ទី ៣ គុណភាពចំណីដែលមានប្រូតេអ៊ីន មានការប្រែប្រួលយ៉ាងខ្លាំង ហើយអាចធ្វើឱ្យមានការប៉ះពាល់ដល់សុខភាពរបស់មនុស្ស។

ស្រូវ-អង្ករ គឺជាប្រភពនៃជាតិអាស៊ីតអាមីនេ (ប្រភេទអាស៊ីតអាមីនេខ្លែតដែលមិនអាចធ្វើរស្មីសំយោគជាមួយប្រភពមួយផ្សេងទៀត) យ៉ាងសំខាន់តែខ្វះខាតលីស៊ីនសម្រាប់ការប្រើប្រាស់ដល់មនុស្ស។ ទោះបីយ៉ាងនេះក៏ដោយ យើងអាចបំពេញបានព្រោះថា លីស៊ីនមាននៅក្នុងសាច់សត្វដូចជា សាច់មាន់ ជ្រូក និងគោដែលមានលីស៊ីនខ្ពស់ជាងស្រូវ-អង្ករហើយមានប្រហែល ៣ ភាគ ៤ នៃកំហាប់ប្រូតេអ៊ីនដែលមានលើត្រី និងផលិតផលវារីជាតផ្សេងទៀត (Garrow and James 1993)។ ឋត្រី និងវារីសត្វផ្សេងទៀតដែលប្រើជាចំណីអាហារនៅតំបន់ទំនាបកណ្តាលវិញ គឺ ៥២ ភាគរយនៃប្រូតេអ៊ីនបានមកពីស្រូវ-អង្ករ ៣៦ ភាគរយបានមកពីវារីសត្វ ១២ ភាគរយបានមកពីសាច់សត្វផ្សេងទៀត ហើយត្រូវបានគេជំនួសដោយប្រភេទសាច់ផ្សេងទៀត។ ជាលទ្ធផល គឺភាគច្រើនចំណីអាហារដែលផលិតពីស្រូវ-អង្ករមានសារធាតុលីស៊ីនគ្រប់គ្រាន់។

ទោះបីយ៉ាងនេះក្តី ប្រហែលមិនទាន់មានការធ្វើកសិកម្មក្នុងរយៈពេលខ្លីទេ គោលនយោបាយរបស់រដ្ឋាភិបាលគឺជំរុញឱ្យបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់ដែលជាហេតុនាំមានការកើនឡើងនូវការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ក៏ដូចជាហេតុនាំមានការគាំទ្រដែលស្របពេលមានការផ្លាស់ប្តូរ (ដីភក់) ឱ្យក្លាយទៅជាដីស្រែ។ ការថយចុះត្រីក្នុងរបបម្ហូបអាហារគឺជាផលវិបាកចំពោះមុខ។ ប្រការសំខាន់គឺផលិតផលសត្វផ្សេងទៀតមិនអាចជំនួសត្រីបានទេ ដោយសារមានជីវជាតិលីស៊ីន ស្រូវ អង្ករដែលមានក្នុងស្រូវពុំគ្រប់គ្រាន់សំរាប់តំរូវការរបស់មនុស្សទេ។ គោលនយោបាយគ្រប់គ្រងធនធានជលផល (រាប់បញ្ចូលទាំងនេសាទទ្រង់ទ្រាយតូច) រួមទាំងការជំរុញវារីវប្បកម្មទ្រង់ទ្រាយតូចអាចធានាផ្គត់ផ្គង់អាហារនៅតាមជនបទឱ្យមានតុល្យភាពបំពេញតំរូវការជីវជាតិនៃរាងកាយរបស់មនុស្ស។

### ២.១.២ តើអ្នកណាជាអ្នកចិញ្ចឹមត្រី?

តំបន់ដាច់ស្រយាលនៃអាងទន្លេមេគង្គ ជាពិសេសកសិដ្ឋានរបស់ប្រជាកសិករចិញ្ចឹមត្រីក្នុងស្រែបានផ្តល់សក្តានុពលភាពសម្រាប់ពង្រីកសកម្មភាពវារីវប្បកម្ម។ កសិករចិញ្ចឹមត្រីជាលក្ខណៈគ្រួសារជាច្រើនបានលក់ត្រីសាច់មួយចំនួនដែលគាត់ផលិតបាន និងទុកខ្លះប្រើប្រាស់ក្នុងគ្រួសារ។ កសិករដែលមានជំនាញខាងវារីវប្បកម្ម បានលក់ផលិតផលសាច់ត្រីទាំងអស់។ ការអភិវឌ្ឍវារីវប្បកម្មគឺមានឥទ្ធិពលយ៉ាងខ្លាំងក្លាតាមរយៈតម្រូវការទីផ្សារ ជាពិសេសទីផ្សារនៅតាមភូមិ។ តម្រូវការទីផ្សារនឹងពឹងផ្អែកលើពេលវេលាមានអ្នក ប្រើប្រាស់ដែលអាចទិញជាប្រចាំក្នុងតម្លៃពី ០.៧៥ ដល់ ១ ដុល្លារក្នុងមួយគីឡូក្រាម ឬច្រើនជាងនេះ។ ប្រាក់ចំណូលរបស់ប្រជាកសិករនៅតាមជនបទគឺនៅចន្លោះពី ១២០ ដល់ ១៥០ ដុល្លារអាមេរិកក្នុងមួយឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយ ចំពោះប្រទេសឡាវ និងកម្ពុជាទទួលបានប្រាក់ចំណូលជាសាច់ប្រាក់ទាបជាងនេះ។ នេះប្រហែលមកពីការកំណត់នៃទំហំអភិវឌ្ឍន៍វារីវប្បកម្មក្នុងតំបន់ ហើយកត្តានេះទាក់ទងយ៉ាងជិតស្និទ្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការពង្រីកតំបន់នៅតាមជាយក្រុង។ នេះប្រហែល មានការអភិវឌ្ឍជាបណ្តើរៗ ការអភិវឌ្ឍមួយចំនួនត្រូវមានការប្រុងប្រយ័ត្ន ហើយត្រូវផ្តល់ដំបូន្មានដោយផ្អែកលើការយល់ដឹង អំពីទីផ្សារជាមូលដ្ឋាន ។

ក្នុងការជំរុញអភិវឌ្ឍន៍វារីវប្បកម្ម មានជម្រើសមួយរវាងការផលិត និងអ្នកផលិតនៅទូទាំងតំបន់ដាច់ស្រយាលនៃអាងទន្លេមេគង្គ។ បទពិសោធន៍បានបង្ហាញថា កសិករចិញ្ចឹមត្រីទ្រង់ទ្រាយតូចធ្វើការចិញ្ចឹមជាលក្ខណៈបុគ្គល ប៉ុន្តែការងារសំខាន់នោះគឺការចូលរួមចំណែកក្នុងផលិតកម្មវារីវប្បកម្ម។ ចំពោះគ្រួសារកសិករដែលមានសមាជិកតិច វារីវប្បកម្មបានចូលរួមចំណែកដល់ប្រាក់ចំណូលតាមរយៈការលក់ត្រី ប៉ុន្តែស្រះចិញ្ចឹមត្រីភាគច្រើនគឺផ្តល់ម្ហូបអាហារសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ជួនកាលម្ហូបអាហារអាចរកបានតាមរយៈការចាប់ត្រីពីធម្មជាតិនៅក្បែរ (ស្ទឹង និងទន្លេ) និងការប្រមូលផលនៃប្រភេទវារីរុក្ខជាតិដែលមាននៅក្នុងស្រះ។ យុទ្ធសាស្ត្រដែលចែងក្នុងអនុសាសន៍ គឺសង្កត់ធ្ងន់លើការជំរុញឱ្យមានការចូលរួមក្នុងផលិតកម្មវារីវប្បកម្មជាលក្ខណៈគ្រួសារនៅតាមជនបទក្នុងតំបន់អាងទន្លេមេគង្គ ហើយយុទ្ធសាស្ត្រមួយបែបទៀត គឺអាចចូលរួមចំណែកដល់សន្តិសុខស្បៀងក្នុងចំណោមគ្រួសារក្រីក្រ ដើម្បីធ្វើការអភិវឌ្ឍនៅតាមជនបទសំដៅកាត់បន្ថយភាពក្រីក្រ។ មានការសង្កត់ធ្ងន់យ៉ាងខ្លាំងផងដែរទៅលើផលិតកម្មវារីវប្បកម្មទ្រង់ទ្រាយធំសម្រាប់នាំចេញ។ នេះអាចបន្ថយការគាំទ្រដល់ផ្នែកវារីវប្បកម្មគ្រួសារដែលនឹងអាចនាំទៅដល់ភាពមិនស្មើគ្នាក្នុងការអភិវឌ្ឍជនបទ ហើយថែមទាំងបង្កើតបញ្ហាដល់បរិស្ថានតាមរយៈការផ្លាស់ប្តូរយោបល់នៃតំបន់ដីសើម និងការបំពុលពីកសិដ្ឋានបែបប្រពលវប្បកម្ម។

មានទឡ្ហីករណ៍មួយបញ្ជាក់ថា ប្រជាជនក្រីក្រមិនអាចចូលរួមក្នុងវារីវប្បកម្មបានទេ ពីព្រោះពួកគេមិនមានទ្រព្យសម្បត្តិ។ ទោះបីយ៉ាងណាក៏ដោយ បទពិសោធន៍ដែលមានក្នុងអាងទន្លេមេគង្គបានបង្ហាញថា ប្រជាជនក្រីក្រអាចក្លាយជាអ្នកដែលពាក់ព័ន្ធ និងទទួលផលប្រយោជន៍ពីវារីវប្បកម្ម ហើយពួកគេក៏មានដី ឬអាងទឹកដែលពួកគេអាចដាក់ត្រីចិញ្ចឹមបាន។ ជាការពិតវារីវប្បកម្មបែបនេះប្រហែលជានឹងមិនអាចបង្កឱ្យមានផលជាយថាហេតុធ្ងន់ធ្ងរទេតែបានជួយគ្រួសារក្រីក្រចេះឱ្យប្រើប្រាស់ដីរបស់គេរឹតតែបានប្រសើរឡើង។ ក្នុងករណីប្រជាជនដែលគ្មានដីក៏មានឱកាសជាច្រើនសម្រាប់ពួកគាត់ក្នុងការផ្តល់សេវាកម្មដល់វិស័យវារីវប្បកម្ម (ដូចជាការប្រមូលកូនត្រីការថែបំប៉នកូនត្រីពូជ ឬការប្រមូលផ្តុំវត្ថុធាតុដើមសម្រាប់ស្រះចិញ្ចឹមត្រី)។ ទោះបីយ៉ាងណាក៏ដោយ វិធានការនេះត្រូវបានគេប្រើឱ្យចំទិសដៅដើម្បីដោះស្រាយបញ្ហាពិសេសទាំងឡាយដែលប្រជាជនក្រីក្រកំពុងប្រឈមមុខ ដូចជាការផ្តល់ឥណទាន និងការជួយផ្សព្វផ្សាយបច្ចេកទេស។ យន្តការដើម្បីអភិវឌ្ឍវារីវប្បកម្មគួរផ្តោតការយកចិត្តទុកដាក់ដល់ការកាត់បន្ថយភាពក្រីក្រក្នុងគ្រួសារ របស់ពួកគាត់ដោយរាប់បញ្ចូលបន្ថែមនូវការផ្តល់បច្ចេកទេសដែលពួកគាត់ងាយទទួលយក និងការជួយឧបត្ថម្ភបណ្តុះបណ្តាលការចិញ្ចឹម និងជំនាញគ្រប់គ្រងក្នុងចំណោមប្រជាជនគ្មានដី និង ប្រជាជនក្រីក្រជួបបញ្ហាគ្រោះជាយថាហេតុដោយសារមានប្រាក់ទុនកំណត់ (Haylor 2000)។

### ២.១.៣ តើគេដាក់ត្រីចិញ្ចឹមយ៉ាងដូចម្តេច?

បច្ចេកវិទ្យាសម្រាប់វារីវប្បកម្មគ្រួសារដែលអនុវត្តជាមួយគ្រួសារក្រីក្រតាមជនបទ ត្រូវបានគេកំណត់ថាជាផ្នែកមួយដែលចំណាយទុនតិចក្នុងការធ្វើវិនិយោគ ព្រោះមានផលប៉ះពាល់ដោយហេតុការណ៍ជាយថាហេតុតិចតួច ហើយឆាប់បានទទួលផល មកវិញ។ បច្ចេកទេសទាំងនេះងាយស្រួលក្នុងការបង្រៀន និងងាយស្រួលក្នុងការទទួលយក ជាពិសេសបច្ចេកទេសទាំងនេះបានចូលរួមចំណែកដល់ការផ្គត់ផ្គង់ត្រីតាមមូលដ្ឋាន។ បច្ចេកវិទ្យាវារីវប្បកម្មទាំងនេះត្រូវបានគេរាប់បញ្ចូល ដូចជាស្រះចិញ្ចឹមត្រី ការបំប៉នត្រីក្នុង

ហាប៉ា ក្នុងទឹកស្រះធម្មតា ការចិញ្ចឹមត្រីតាមវាលស្រែ និងការចិញ្ចឹមត្រីក្នុងបែជាលក្ខណៈគ្រួសារ ។ គេគួរតែចាប់អារម្មណ៍ផងដែរទៅលើបច្ចេកវិទ្យាចិញ្ចឹមបែបប្រព័ន្ធចំរុះជាមួយប្រព័ន្ធកសិកម្ម ជាពិសេសគឺនៅតាមកសិដ្ឋានស្រូវដែលមានលក្ខណៈល្អប្រសើរហើយមានទីតាំងនៅក្នុងតំបន់អាងទន្លេមេគង្គ ។

នៅប្រទេសវៀតណាម និងឡាវ គ្រួសារដែលបានអនុវត្តវារីវប្បកម្មអាចកើនប្រាក់ចំណូល និងកែលំអសន្តិសុខស្បៀងតាមរយៈការផ្តួចផ្តើមការចិញ្ចឹមត្រីក្នុងប្រព័ន្ធកសិដ្ឋានរបស់ពួកគាត់ ។ ដើម្បីកែលំអប្រាក់ចំណូលរបស់កសិករឱ្យស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលក្នុងបណ្តាប្រទេសទាំងនោះ ការជំរុញវារីវប្បកម្មគឺត្រូវបង្កើតបន្ថែមកសិដ្ឋានច្រើនទៀត ។ ទាក់ទងបញ្ហានេះមានជម្រើសជាច្រើនស្តីពីរបៀបបង្កើតប្រព័ន្ធកសិកម្មចំរុះជាមួយស្រូវ ។ ពេលដែលគេបង្កើតប្រព័ន្ធចំរុះ ហើយទាក់ទងដល់ការដាំដុះស្រូវលើកទី ២ ឬលើកទី ៣ ទិន្នផលត្រីនឹងត្រូវបានគេបោះបង់ចោលដោយសារពូជស្រូវដែលត្រូវដាំនោះ ជាពូជមានលក្ខណៈផ្សេងគ្នាហើយត្រូវការទឹកតិចតែប្រើនូវប្រភេទថ្នាំសម្លាប់សត្វល្អិតច្រើន ។ ជាការពិតការដាក់ត្រីចិញ្ចឹមជាមួយដំណាំស្រូវ២ ឬ៣ មុខ និងការប្រើដំណាំស្រូវផ្សេងទៀត តាមទំលាប់បុរាណ គឺជួយផ្គត់ផ្គង់ប្រាក់ចំណូល និងផលិតកម្មស្បៀងក្នុងគ្រួសារ ( ប្រអប់ ៦ ) ។ ការអះអាងពីសារធាតុចិញ្ចឹមយ៉ាងខ្លាំងដើម្បីធ្វើឱ្យមានប្រសិទ្ធភាពសម្រាប់រក្សានូវតុល្យភាពរវាងស្រូវ និងត្រី ។ គោលនយោបាយក្នុងការគ្រប់គ្រងធនធានជលផលគឺរាប់បញ្ចូលផងដែរនូវការប្រមូលផលិតផលជលផលជាលក្ខណៈគ្រួសារពីដែននេសាទធម្មជាតិ និងការជំរុញឱ្យធ្វើវារីវប្បកម្មទ្រង់ទ្រាយតូច ហើយអាចធានាថាស្បៀងអាហារតាមជនបទនៅតែមានតុល្យភាពសម្រាប់ចិញ្ចឹមរាងកាយមនុស្ស ។

## ២.១.៤ វត្ថុធាតុដើមសំរាប់វារីវប្បកម្ម

មានវត្ថុធាតុដើមសំខាន់ជាច្រើនដែលបានប្រើសម្រាប់វារីវប្បកម្ម ជាពិសេសកូនត្រីពូជត្រូវផ្តល់ចំណីឱ្យបានគ្រប់គ្រាន់ ( ដាក់ជី និងចំណី ) ។ ទាក់ទងនឹងការចិញ្ចឹម ផ្ទៃដី និងប្រភពទឹកគ្រប់គ្រាន់គឺជាប្រភពដ៏សំខាន់មួយសម្រាប់ចិញ្ចឹមត្រី ដូច្នេះតើប្រភពធនធានទាំងនេះនឹងមានគ្រប់គ្រាន់សម្រាប់ឧបត្ថម្ភដល់វិស័យវារីវប្បកម្មដែរឬទេ ?

### កូនត្រីពូជ

ប្រសិនបើ កូនត្រីមានគុណភាព និងសុខភាពល្អគឺជាតម្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍវារីវប្បកម្ម ។ ការផ្គត់ផ្គង់កូន ត្រីពូជសម្រាប់វារីវប្បកម្មបានកើនឡើងយ៉ាងច្រើនក្នុងរយៈពេល ១០ ឆ្នាំកន្លងមក ។ ជាពិសេសប្រទេសថៃ និងប្រទេសវៀតណាមបានអភិវឌ្ឍនូវអាងបំប៉ន និងអាងភ្ញាស់ ហើយបានកើតឡើងទាំងនៅក្នុងស្ថាប័នរដ្ឋាភិបាល និងឯកជន ។ នៅប៉ែកឧត្តរនៃប្រទេសថៃកូនត្រីពូជត្រូវបានគេលក់នៅនឹងកន្លែងកសិដ្ឋាន ( ហើយរដ្ឋាភិបាលក៏បានផ្គត់ផ្គង់កូនត្រីមួយចំនួនផងដែរ សំខាន់ជាងនេះទៀតរដ្ឋាភិបាលក៏កំពុងធ្វើឱ្យមានការផ្លាស់ប្តូរនូវប្រព័ន្ធអាងស្តុកទឹកថ្មីទុកឱ្យប្រើប្រាស់ជាសាធារណៈទៀតផង ) ។ កូនត្រីត្រូវបានគេលក់នៅតាមតំបន់ដីសណ្តទន្លេមេគង្គប្រទេសវៀតណាមតាមរយៈប្រព័ន្ធអាងភ្ញាស់ស្ថានីយ៍បំប៉នកូនត្រី និងឈ្មួញលក់កូនត្រីម៉ៀវ និងកូនត្រីពូជ ។ ចំណែកនៅក្នុងប្រទេសកម្ពុជា និងឡាវវិញស្រះចិញ្ចឹមត្រីជាច្រើនមិនត្រូវបានគេដាក់ចិញ្ចឹមត្រីឱ្យបានទៀងទាត់ទេ ដោយសារមិនអាចរកពូជត្រីបាន ឬក៏ខ្វះកូនត្រីពូជដាក់ចិញ្ចឹម ។ ដូច្នេះការផ្តល់កូនត្រីពូជត្រូវវិឱ្យស្របពេលជាមួយនូវការកើនឡើងចំនួនកសិករចិញ្ចឹមត្រីដោយកែលំអនូវហេដ្ឋារចនាសម្ព័ន្ធ ការបង្កើតទីផ្សារ និងការផ្គត់ផ្គង់កូនត្រីពូជនឹងត្រូវកើនឡើងដែរ ។ ភាពងាយស្រួលនៃបច្ចេកទេសបំប៉នកូនត្រីក្នុងហាប៉ា ( ការបំប៉នកូនត្រីម៉ៀវទៅកូនត្រីពូជក្នុងហាប៉ា ) ក្នុងតំបន់អាងទន្លេមេគង្គគឺបានរីកសុះសាយ ហើយការធ្វើដូចនេះបានជំរុញឱ្យកូនត្រីពូជឆាប់ធំ និងអាចគេចផុតពីត្រីកាចដែលមានក្នុងធម្មជាតិនៅពេលកូនត្រីត្រូវបានគេដាក់ចិញ្ចឹមក្នុងស្រះ ។

យ៉ាងហោចណាស់ក៏មានកូនត្រីចំនួន ២ លានក្បាលត្រូវបានគេដាក់ចិញ្ចឹម ហើយប្រមូលទិន្នផលត្រីចិញ្ចឹមបានប្រហែលចំនួន ២៥០.០០០ តោន ក្នុងតំបន់អាងទន្លេមេគង្គ ។ ចំពោះការអភិវឌ្ឍវារីវប្បកម្មឱ្យកើនឡើង ការពង្រីកសមត្ថភាពអាងភ្ញាស់ និងបំប៉ន គឺជាកត្តាយ៉ាងសំខាន់នឹងត្រូវការជាចាំបាច់ ។ វារីវប្បកម្មនៅតាមជនបទគឺជួបបញ្ហាចរាចរកូនត្រីពូជ ប៉ុន្តែយោងតាមបទពិសោធន៍ បានលើកឡើងថា អាងភ្ញាស់ជាលក្ខណៈគ្រួសារនៅតាមមូលដ្ឋានអាចមានឥទ្ធិពលយ៉ាងធំធេង ។ វិទ្យាស្ថានបច្ចេកទេសអាស៊ី (Asian Institution of technology) ១៩៩៧ចាត់ទុកគំរូអាងភ្ញាស់ត្រីរបស់រដ្ឋាភិបាលជាច្រើនថ្នាក់ជាតិមិនសូវបានទទួលជោគជ័យទេ ។ អាងភ្ញាស់ជាលក្ខណៈគ្រួសារថ្នាក់ភូមិ ការថែបំប៉នកូនត្រីក្នុងហាប៉ា បណ្តាញលក់កូនត្រី និងការបង្កាត់ភ្ញាស់កូនត្រីតាមភូមិបានផ្តល់ជាចលករយ៉ាងល្អប្រសើរ សម្រាប់វារីវប្បកម្មទ្រង់ទ្រាយតូចថ្នាក់មូលដ្ឋាននៅតាមជនបទ ។ ដូច្នេះការអភិវឌ្ឍបន្ថែមដល់ការថែបំប៉នកូនត្រីក្នុងហាប៉ា និងបណ្តាញបំប៉នកូនត្រីជាការសំខាន់ក្នុងការគាំទ្រដល់សកម្មភាពវារីវប្បកម្ម ជាពិសេសនៅតាមតំបន់ជនបទប្រទេសកម្ពុជា និងឡាវដែលនៅខ្វះខាតនូវហេដ្ឋារចនាសម្ព័ន្ធល្អ ។ ការដែលគ្មានបណ្តាញនៅតាមមូលដ្ឋាន កូនត្រីនឹងត្រូវបានគេដឹកយ៉ាងឆ្ងាយទៅ

7. ចាប់ពីប្រមាណអត្រារស់រប 50% នៃកូនត្រី (Fingerlings) មានទំហំសំរាប់ទីផ្សារ 250 ក្រាម ។ តួលេខនៅតារាង 2 នៅពុំទាន់ឯកភាពគ្នានៅឡើយ ហើយត្រូវការស្រាវជ្រាវបន្ថែមទៀត ។

កាន់តំបន់វង់ទឹកភ្លៀង ហើយក៏មិនបានគិតពីបច្ច័យអាក្រក់ចែដន្យលើការច្រឡំគ្នានៃសេនេទិចផលស្តុក និងការរាលដាលនៃជំងឺត្រី ។

មានបញ្ហាមួយចំនួនផងដែរដល់អាងភ្ញាស់ទ្រង់ទ្រាយតូចដែលចាំបាច់ត្រូវតែធ្វើការដោះស្រាយ ដូចជាបញ្ហាអាងបង្កាត់ពូជតែមួយ និងការលំបាកក្នុងការបង្កាត់ប្រភេទត្រីមួយចំនួនទៀត (ដូចជាប្រភេទត្រីប្រា) ដោយសារការខ្វះខាតស្រះ និងបច្ចេកវិទ្យាបង្កាត់ព្រមទាំងខ្វះខាតការគ្រប់គ្រងត្រីមេពូជ ។ ដូច្នេះការយកចិត្តទុកដាក់ជាសំខាន់នោះ គឺការផ្គត់ផ្គង់អាងភ្ញាស់ទ្រង់ទ្រាយតូច ព្រោះថាវាជាតម្រូវការចាំបាច់សម្រាប់មូលដ្ឋានតាមរយៈការឧបត្ថម្ភទូវហាប៉ា និងបណ្តាញបំប៉នកូនត្រីតាមមូលដ្ឋាននឹងផ្តល់សម្ភារៈមួយចំនួនទៀតសម្រាប់ជួយឧបត្ថម្ភដល់អាងភ្ញាស់ធំៗ ឬ កន្លែងស្តុកត្រីមេពូជដែលរក្សាទុកនូវសេនេទិចផ្សេងៗ និងត្រីមេពូជប្រភេទធំ ។ តួនាទីរបស់រដ្ឋាភិបាល និងការដាក់វិនិយោគទុនផ្នែកឯកជនក្នុងថ្នាក់មធ្យមបែបនេះចាំបាច់ត្រូវធ្វើការវិភាគដោយប្រុងប្រយ័ត្ន ពីព្រោះមូលដ្ឋានសម្រាប់ការអភិវឌ្ឍគឺការគ្រប់គ្រងសេនេទិចឱ្យមានប្រសិទ្ធភាព និងជាយុទ្ធសាស្ត្របន្សុតប្រភេទនៅក្នុងតំបន់អាងមេគង្គ ។ ជាពិសេសរដ្ឋាភិបាលមានតួនាទីសំខាន់ក្នុងការអភិរក្សសេនេទិច ទោះជាមានការលើកទឹកចិត្តដល់ផ្នែកឯកជនក៏ដោយ ។ ដើម្បីធ្វើវិយោគឱ្យបានច្រើនក្នុងសកម្មភាពការងារទាំងនេះចាំបាច់ត្រូវធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត ។

**ប្រអប់ទី៧: វិមជ្ឈការលើវិស័យឯកជនក្នុងការផ្គត់ផ្គង់កូនត្រី នៅភាគខាងត្បូងប្រទេសឡាវ**

(ផ្អែកលើការងាររបស់ RDC/AIT-See Haylor 2001)

ប្រព័ន្ធត្រូវបានគេផ្តល់សម្រាប់ :

- ជំរុញឱ្យមានវិមជ្ឈការលើផ្នែកឯកជនក្នុងការផលិតកូនត្រីពូជ និងបណ្តាញការងារនៅក្នុងចំណោមផ្នែកអ្នកផលិតកូនត្រីពូជទ្រង់ទ្រាយតូច ។
- ផ្តល់មុខងារចាំបាច់ដែលស្រដៀងគ្នានឹងប្រព័ន្ធការពារវ៉ាក់សាំងសត្វដែលមានស្រាប់
- បង្កើតកម្មវិធីទាក់ទង និងផ្សព្វផ្សាយឯកសារ ឬសម្ភារៈពាក់ព័ន្ធដល់សកម្មភាពវារីវប្បកម្ម
- ផ្តល់ឱកាសសម្រាប់ប្រតិបត្តការនៅតាមបណ្តាស្ថាប័នផ្សេងៗ
- បណ្តុះបណ្តាលសមត្ថភាពជំនាញការគ្រប់គ្រងថ្នាក់មូលដ្ឋាន

ការដោះស្រាយបញ្ហាផ្អែកលើសកម្មភាពអភិវឌ្ឍន៍ :

- តម្រូវឱ្យមានកូនត្រីពូជគ្រប់គ្រាន់សម្រាប់ប្រជាជនដែលមានបំណងចូលរួមក្នុងសកម្មភាពវារីវប្បកម្មជាលក្ខណៈគ្រួសារ
- កង្វះខាតលទ្ធភាពផលិតកម្មនៃអាងភ្ញាស់សាធារណៈទ្រង់ទ្រាយធំ និងការប្រកួតប្រជែងរបស់ពួកគេជាមួយផ្នែកឯកជន ។
- ចាំបាច់ឱ្យមានកម្មវិធីទាក់ទង និងផ្សព្វផ្សាយឯកសារ ឬសម្ភារៈ គឺជាគន្លឹះជំរុញឱ្យមានជាលក្ខណៈឧស្សាហកម្ម
- ឱកាសសម្រាប់ប្រតិបត្តិការរបស់បណ្តាស្ថាប័ននៅតាមមូលដ្ឋានមានកំរិត
- សមត្ថភាពគ្រប់គ្រងរបស់បណ្តាស្ថាប័នរដ្ឋពាក់ព័ន្ធតាមមូលដ្ឋាននៅមានកំរិត

**ប្រភេទត្រីដាក់ចិញ្ចឹម**

ត្រីដែលគេដាក់ចិញ្ចឹមគួរតែស៊ីចំណីចំរុះក្នុងខ្សែចង្វាក់ផលិតកម្មចំណី ពីព្រោះនេះនឹងអាចឱ្យកសិករប្រើចំណីដែលមានឱ្យបានច្រើន ពីព្រោះវាមានប្រសិទ្ធភាពដល់បរិស្ថានថែមទៀតផង ។ ភាគច្រើននៃផលិតកម្មវារីវប្បកម្ម គឺបានមកពីប្រភេទត្រីស៊ីរុក្ខជាតិ និងស៊ីចំណីចំរុះទាំងប្រភេទត្រីក្រៅស្រុក និងក្នុងស្រុកដែលអាចលូតលាស់ក្នុងមធ្យោបាយដោយបានផ្តល់ផលល្អនៃបរិស្ថាន ។ ការបញ្ជាក់នេះគួរតែបន្តអនុវត្តទោះបីត្រូវការទីផ្សារចាំបាច់ក៏ដោយ ។ ក្នុងតំបន់ជនបទជាច្រើននៃអាងទន្លេមានការពេញនិយមប្រភេទត្រីក្នុងស្រុក ហើយបញ្ហានេះគួរត្រូវបានគេគាំទ្រតាមរយៈយុទ្ធសាស្ត្រគ្រប់គ្រងត្រីមេពូជដែលថែរក្សាសេនេទិចចំរុះ ។ ចំពោះប្រភេទត្រីស៊ីសាច់ ដូចជាត្រីរស់ដែលនឹងបន្តដាក់ចិញ្ចឹម សូមបញ្ជាក់ថាគួរកែលំអប្រពន្ធ័ចំណីឱ្យមានប្រសិទ្ធភាព ដើម្បីធានាថា ចំណីត្រីសម្រាប់ត្រីឆ្តោមិនមែនជាមានត្រីធម្មជាតិដែលប្រជាជនក្រីក្រតែងតែបានប្រើប្រាស់សម្រាប់សន្តិសុខស្បៀងក្នុងគ្រួសារ និងជាពិសេសធ្វើជាប្រភពប្រូតេអ៊ីនដ៏មានប្រសិទ្ធភាព ហើយពួកគេកាត់បន្ថយការបំពុលបរិស្ថានផងដែរ ។ ជាងនេះក្នុងគោលដៅគេចឱ្យផុតពីករណីដូចនេះការងារស្រាវជ្រាវលើប្រភេទត្រីក្នុងស្រុកដូចដែលមានការជួយឧបត្ថម្ភដោយគម្រោង (AIM Project , MRC) ត្រូវបានគេលើកទឹកចិត្ត និងជួយជំរុញផងដែរ ។

**ចំណី និង ការបន្ថែមជី**

ចំណីត្រីត្រូវបានគេផ្តល់ដោយផ្ទាល់ ឬ តាមរយៈផលិតកម្មជំរុញបញ្ចូលទៅក្នុងស្រះ និងនៅវាលស្រែតាមរយៈដាក់បន្ថែមជីសរីរាង្គ និងអសរីរាង្គ។ ទោះបីយ៉ាងណាក៏ដោយ វត្ថុធាតុដើមបានមកពីកសិដ្ឋានភាគច្រើនពឹងផ្អែកពីស្រូវកត្តានេះបានធ្វើឱ្យអ្នកចិញ្ចឹមជួបបញ្ហាដោយខ្វះវត្ថុធាតុដើមសម្រាប់ស្រះវារីវប្បកម្មប្រពលវប្បកម្ម និងត្រូវការវត្ថុធាតុដើមផ្សេងទៀតពីខាងក្រៅកសិដ្ឋាន។ កន្ទក់គឺជាជីសំខាន់ ប៉ុន្តែវត្ថុធាតុដើមសមស្របផ្សេងទៀតដែលមានតាមមូលដ្ឋានក៏ត្រូវការផងដែរ។ ធនធានដែល សមស្របទាំងនោះត្រូវបានគេរាប់បញ្ចូលមានរុក្ខជាតិ ជីតីមី និងកាកសំណល់បានមកពីផលិតកម្ម និង មនុស្ស និងកាកសំណល់សត្វចំរុះដែលទទួលបានមកពីកន្លែងផលិតកម្ម។ វត្ថុធាតុដើមទាំងអស់នេះមានមិនទៀងទេ អាស្រ័យនឹងកសិករចិញ្ចឹម និងកំរិតកំណត់។ តាមភូមិសាស្ត្រវត្ថុធាតុដើមនៅក្រៅកសិដ្ឋានត្រូវបានគេត្រៀមមានច្រើនណាស់នៅប្រទេសវៀតណាម និងប្រទេសថៃ ប៉ុន្តែមិនមានក្នុងប្រទេសកម្ពុជា និងឡាវទេ។ ទោះបីយ៉ាងណាក៏ដោយ ប្រទេសទាំងពីរនេះ នៅពេលអនាគតនឹងមាននាំចេញនាំចូលវត្ថុធាតុដើមយ៉ាងច្រើន ដូចជាការកែលំអហេដ្ឋារចនាសម្ព័ន្ធ និងទីផ្សារសម្រាប់វត្ថុធាតុដើមកសិកម្ម ( ជី និង កំបោរ )។ នៅតាមតំបន់ជនបទនៃប្រទេសកម្ពុជា និងឡាវ កសិករទំនងបន្តប្រើប្រាស់ និងជម្រើសរកចំណីផ្សេងសម្រាប់ពេលណាមួយ។ ប្រភេទត្រីដែលបានដាក់ចិញ្ចឹមនឹងមានឥទ្ធិពលផងដែរដល់កត្តារកចំណី។ ឧទាហរណ៍ ការប្រើជីតីមីដើម្បីបង្កើតប្រពន្ធ័ទឹកបៃតងទាំងមូល គឺកាន់តែសមស្របសម្រាប់ប្រភេទត្រីទីឡាព្យាជាងប្រភេទត្រីក្នុងស្រុក។ ការចិញ្ចឹមត្រីចំរុះជាមួយសត្វបង្ហាញទូវឱកាសមួយ ប៉ុន្តែចំពោះតំបន់ជុំវិញជាយក្រុងវិញមានការពិបាកក្នុងការធ្វើប្រព័ន្ធចំរុះនេះព្រោះសត្វចិញ្ចឹមត្រូវបានគេរក្សាទុកក្នុងកន្លែងមួយដាច់ដោយឡែក។ ចំណែកឯនៅតាមតំបន់ដីសណ្តមេគង្គក្នុងប្រទេសវៀតណាម សត្វនៅតាមជនបទជាធម្មតាមិនត្រូវបានគេដាក់ឱ្យនៅនឹងមួយកន្លែងទេ។ បញ្ហាដែលគេលើកឡើងនេះបានបណ្តាលឱ្យមានការប្រណាំងប្រជែងរកលាមកសត្វ កន្ទក់ និងអនុផលកសិកម្មផ្សេងទៀត។ ដើម្បីមានការអភិវឌ្ឍលើផ្នែកនេះទាមទារជាចាំបាច់ត្រូវឱ្យមានដំណោះស្រាយតាមរយៈការវិភាគពីតម្រូវការពេលបច្ចុប្បន្ន និងអនាគត និងការឧបត្ថម្ភផ្សព្វផ្សាយដែលមានភាពសមស្រប។

**ទឹក និង ដី**

គុណភាព និងបរិមាណទឹកគ្រប់គ្រាន់ គឺជាតម្រូវការចាំបាច់សម្រាប់វារីវប្បកម្ម។ ភាគច្រើនស្រះចិញ្ចឹមទ្រង់ទ្រាយតូចក្នុងអាងទន្លេមេគង្គមានភ្លៀងធ្លាក់ ដូច្នេះការប្រើប្រាស់ និងការជោគជ័យអាចប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំដែលផ្អែកលើទឹកភ្លៀងធ្លាក់។ ការប្រើប្រាស់ទឹកទំនងជាមិនមានបញ្ហាជាមួយស្រះពឹងលើទឹកភ្លៀងទេ។ ប្រសិនបើបរិយាកាសមិនមានការប្រែប្រួលខ្លាំងក្នុងតំបន់អាងមេគង្គទេ អាចអំណោយផលដល់តំបន់កសិដ្ឋានឱ្យមានទឹកស្រោចស្រពគ្រប់គ្រាន់ និងទីកន្លែងដែលមានការប្រើទឹកច្រើនផ្សេងទៀត។ ការពិចារណាផ្សេងទៀតប្រហែលកើនឡើងលើគោលនយោបាយនៃការប្រើប្រាស់ទឹកដែលកំពុងតែមានការផ្លាស់ប្តូរក្នុងអាងទន្លេមេគង្គ ហើយការសង្កត់ធ្ងន់បន្ថែមត្រូវបានគេប្រគល់ឱ្យធ្វើការប្រើប្រាស់ទឹកមានលក្ខណៈសន្សំសំចៃ។ វារីវប្បកម្មនឹងត្រូវបានគេពិចារណាផងដែរក្នុងដំណើការនេះ ដែលវាគឺជាផ្នែកមួយនៃបរិស្ថានពហុប្រើប្រាស់ ( ស្រះក្នុងតំបន់ស្រោចស្រពការចិញ្ចឹមក្នុងបែ) ដូចនេះវារីវប្បកម្មអាចជាអ្នកប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព ជាពិសេសនៅក្នុងប្រព័ន្ធចំរុះជាមួយកសិកម្ម។កម្មវិធីការប្រើប្រាស់ទឹករបស់គណៈកម្មការទន្លេមេគង្គនឹងផ្តល់ជាវេទិការសម្រាប់ការពិភាក្សាស្តីពីបញ្ហាគោលនយោបាយដែលទាក់ទងនឹងការប្រើប្រាស់ទឹក ហើយការងារនេះក៏គេនឹងពិចារណាផងដែរចំពោះវារីវប្បកម្ម ទោះបីជាអ្នកប្រើប្រាស់ទឹកតិចតួចក៏ដោយ។

គុណភាពទឹកអាចក្លាយជាការចាប់អារម្មណ៍ក្នុងពេលអនាគត ផ្នែកជាច្រើននៃបណ្តាស្រះក្នុងអាងទន្លេមេគង្គបានប្រឈមមុខជាមួយភាពល្អក់ និងបញ្ហាផលិតកម្មដោយសារដីមានជាតិអាស៊ីត ដីខ្វះជីជាតិ និងការអនុវត្តគ្រប់គ្រងមិនសមស្រប។ បញ្ហានេះអាចត្រូវបានគេដោះស្រាយតាមរយៈការអនុវត្តការគ្រប់គ្រងទឹកឱ្យបានកាន់តែប្រសើរ។ ក្នុងប្រព័ន្ធកសិដ្ឋានធំៗជាច្រើន ដូចជាបែក្នុងបឹង ទន្លេ និងបឹងធម្មជាតិ ឬការចិញ្ចឹមត្រីក្នុងវាលស្រែ ការបំពុលទឹកជាបញ្ហាមួយ។ ការគ្រប់គ្រងសត្វចង្រៃចំរុះតាមគម្រោងរបស់ IPM ដែលកាត់បន្ថយការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតក្នុងកសិដ្ឋាន។ ការចិញ្ចឹមត្រីក្នុងបែ និងស្រះស្ថិតនៅក្នុងតំបន់ដែននេសាទការយកចិត្តទុកដាក់បន្ថែមទៀតនឹងត្រូវការជាចាំបាច់ដើម្បីធានាថាឥទ្ធិពលរបស់មនុស្ស និងឧស្សាហកម្ម មិនប៉ះពាល់ដល់វារីវប្បកម្មទេ។

ដីដែលស្ថិតនៅក្នុងតំបន់ខ្លះនៃអាងទន្លេមេគង្គអាចមានសក្តានុពលភាព ដើម្បីឧបត្ថម្ភដល់ការអភិវឌ្ឍវារីវប្បកម្ម ។ ដីដាំស្រូវ ឬដីបន្ទាប់បន្សំក្នុងតំបន់ដាំស្រូវអាចត្រូវបានគេបានប្រើសម្រាប់សាងសង់ស្រះ ។ ទោះបីយ៉ាងណាក៏ដោយក្នុងតំបន់ខ្លះ ដូចជានៅតំបន់ខ្ពង់រាបប្រទេសឡាវ បញ្ហាដីមានរាងបាតខ្លះបង្កការលំបាកដល់ការប្រើប្រាស់ដីសំរាប់ដំណាំស្រូវ ។ ទោះបីជួបបញ្ហាយ៉ាងនេះក៏ដោយ ដោយសារប្រទេសឡាវមានដង់ស៊ីតេប្រជាជនរស់នៅកំរិតទាប នោះគឺបានបង្កលទ្ធភាពដល់ដីកសិកម្មយ៉ាងល្អ និងដីដែលសមស្របសម្រាប់ដំណាំកសិកម្មហើយអាចទទួលបានទិន្នផលខ្ពស់ ។ យុទ្ធសាស្ត្រសម្រាប់វារីវប្បកម្មគួរតែផ្តល់តម្លៃបង្កើតឱ្យមានភាពផ្សេងគ្នា និងធ្វើឱ្យកាន់តែប្រសើរនូវការប្រើប្រាស់ដីឱ្យមានប្រសិទ្ធភាពគ្រប់ទីកន្លែងដែលវិស័យវារីវប្បកម្មកើតមានឡើង ។

## ២.២ តើមានសេវាកម្មគាំទ្រអ្វីខ្លះដែលគេត្រូវការជាចាំបាច់?

ដោយបច្ចេកវិទ្យាជាមូលដ្ឋានសម្រាប់វារីវប្បកម្មជាលក្ខណៈគ្រួសារមាននៅនឹងកន្លែងយ៉ាងធំធេងជាង ១០ ឆ្នាំមកហើយនោះ ការឧបត្ថម្ភនាពេលអនាគតគួរតែសង្កត់ធ្ងន់ទៅលើចំណេះដឹងផ្សព្វផ្សាយ និងការគាំទ្រដល់ការបង្កើតឱ្យមានជាវិទ្យាស្ថានសម្រាប់គ្រួសារនៅតាមជនបទដែលជាទីកន្លែងមានសក្តានុពលសម្រាប់អភិវឌ្ឍន៍វារីវប្បកម្ម ។ ជាក់ស្តែងបទពិសោធន៍ពីអាងទន្លេមេគង្គបានបង្ហាញថា ឧបសគ្គចំបងចំពោះការពាក់ព័ន្ធនឹងវារីវប្បកម្មរបស់ប្រជាជនក្រីក្រនោះគឺខ្វះការយល់ដឹងពីការចិញ្ចឹមជីវិតរបស់ពួកគេ និងគោលបំណងជាក់លាក់មួយ ។ ប្រជាជនក្រីក្រដែលពាក់ព័ន្ធត្រូវការផ្លាស់ប្តូរយ៉ាងច្រើននូវរាល់ការងារបច្ចេកវិទ្យា និងការប្រើពេលយូរមិនដូចប្រជាជនដែលនៅទីក្រុងមានលក្ខណៈបត់បែនបានច្រើនជាង និងមានការចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយ និងការងារស្រាវជ្រាវ ។ គោលនយោបាយរបស់ស្ថាប័នពាក់ព័ន្ធនឹងដំណើការទាំងអស់គួរតែឧបត្ថម្ភដល់វារីវប្បករដែលបានចូលរួមក្នុងសកម្មភាពវារីវប្បកម្ម ជាពិសេសប្រជាជនក្រីក្រ (Haylor 2001) ។

### ២.២.១. សមាគមន៍មូលដ្ឋាន

ការកសាងសេវាកម្មឧបត្ថម្ភនៅកំរិតមូលដ្ឋានគឺជាការសំខាន់ក្នុងការពង្រីកវារីវប្បកម្ម ។ យោងតាមបទពិសោធន៍ពីអាងទន្លេមេគង្គបានបញ្ជាក់ថាវារីវប្បកម្មបានទទួលបរាជ័យបណ្តាលមកពីគ្មានការគាំទ្រផ្សព្វផ្សាយឱ្យមានប្រសិទ្ធភាព ឬការផ្តោតយ៉ាងខ្លាំងទៅលើបច្ចេកទេស និងខ្វះការយល់ដឹងពីបញ្ហាសេដ្ឋកិច្ចសង្គមរបស់គ្រួសារនៅតាមតំបន់ជនបទ ។

ករណីដូចនេះដោយសារការខ្វះមនុស្សមានសមត្ថភាព និងប្រភពធនធានដែលជាការលំបាកមួយដល់ប្រព័ន្ធផ្សព្វផ្សាយ ។ រដ្ឋាភិបាលគួរតែចាប់ដៃជាមួយផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីប្រមូលនូវរាល់ព័ត៌មានជាច្រើនដែលអាចត្រូវបានគេប្រើ និងភ្ជាប់ផងដែរនូវយុទ្ធសាស្ត្រថ្មីៗ ដើម្បីផ្សព្វផ្សាយព័ត៌មាន ឬបច្ចេកទេស។ ឧទាហរណ៍ នៅប្រទេសឡាវដៃគូរវាងរដ្ឋាភិបាល ក្រុមកសិករអ្នកលក់កូនត្រីម្យ៉ៅ និងបណ្តាញថៃបំប៉នកូនត្រីត្រូវបានគេប្រើយ៉ាងមានប្រសិទ្ធភាពសម្រាប់ការផ្សព្វផ្សាយហើយមានអង្គការមួយចំនួនដូចជាអង្គការស្ត្រី ឬសមាគមស្ត្រីត្រូវបានគេប្រើប្រាស់ផងដែរក្នុងប្រទេសឡាវ និងវៀតណាមក្នុងការងារផ្សព្វផ្សាយ ។

យុទ្ធសាស្ត្រចំរុះក៏មានការចាំបាច់ផងដែរចំពោះការផ្តល់សេវាកម្ម និងការផ្សព្វផ្សាយនៅថ្នាក់មូលដ្ឋាន។ បច្ចុប្បន្នដំណើរការវិមជ្ឈការបាននឹងកំពុងគេមើលឃើញថា បានជ្រាបចូល និងអនុវត្តនៅក្នុងតំបន់អាងទន្លេមេគង្គ ។

ចំពោះបញ្ហាចំបងដែលមានការពាក់ពន្ធ័នឹងវារីវប្បកម្មរបស់ប្រជាជនក្រីក្រនោះគឺខ្វះប្រព័ន្ធសន្សំប្រាក់ និងកង្វះខាតប្រាក់ឥណទាន។ ប្រព័ន្ធឥណទាននៅតាមតំបន់ជនបទមិនទាន់បានជឿនលឿនហើយបញ្ហានេះមានការលំបាកនៅប្រទេសឡាវ និងប្រទេសកម្ពុជា។ ប៉ុន្តែការងារនេះបានអភិវឌ្ឍល្អក្នុងប្រទេសថៃ និងវៀតណាមព្រោះថាគេមានធនាគារសម្រាប់ការអភិវឌ្ឍកសិកម្ម និងអ្នកនៅជនបទ ឧទាហរណ៍ការផ្តល់ប្រាក់កម្ចីសម្រាប់ការចិញ្ចឹមត្រីទឹកសាបគេបានផ្តល់ឯកសារ (សៀវភៅក្រហម) ដល់កសិករដែលនេះបានចង្អុល បង្ហាញថាពួកគេជា (ម្ចាស់កម្មសិទ្ធ) លើដីដែលមានក្នុងសៀវភៅក្រហម ។ ឥណទានគួរត្រូវបានគេវិភាគថាជាផ្នែកមួយនៃដំណើរការដើម្បីគាំទ្រដល់គ្រួសារដែលមានកសិដ្ឋានហើយចូលរួមក្នុងវារីវប្បកម្ម ។ ប៉ុន្តែពួកគេជួបការលំបាកមួយចំនួនពិសេសគ្រួសារក្រីក្របានប្រឈមមុខនឹងឧបសគ្គនានាដែលការលំបាកទាំងនេះគួរត្រូវបានគេទទួលស្គាល់ និងធ្វើការដោះស្រាយដោយភ្នាក់ងារជួយឧបត្ថម្ភ ។

### ២.២.២ បញ្ហា និង គោលនយោបាយជាតិ

កាបណ្តុះបណ្តាលសមត្ថភាពថ្នាក់មូលដ្ឋាន និងការងាយស្រួលក្នុងការទទួលយកបាននូវយុទ្ធសាស្ត្រថ្មីដើម្បីផ្សព្វផ្សាយនៅក្នុងការអភិវឌ្ឍចំរុះនៅមូលដ្ឋាន ឬយុទ្ធសាស្ត្រគ្រប់គ្រងដែនទឹកធម្មជាតិនឹងតម្រូវឱ្យមានការប្តូរគោលនយោបាយវារីវប្បកម្ម ។ មានផែនការផ្សេងៗគ្នាពីគោលនយោបាយគ្រប់គ្រងត្រីធម្មជាតិ ពីព្រោះគេបានកំណត់កាន់តែងាយស្រួលអំពីការផ្សព្វផ្សាយព័ត៌មានជាងគោល

នយោបាយចាស់។ គោលនយោបាយជលផលទឹកសាបទំនងទទួលបានការចាប់អារម្មណ៍ច្រើនជាងទៅលើសហគ្រប់គ្រង។ ការអភិវឌ្ឍគោលនយោបាយថ្នាក់ជាតិសម្រាប់វារីវប្បកម្មនឹងត្រូវសង្កត់ធ្ងន់ទៅលើការបណ្តុះបណ្តាលសមត្ថភាព និង ការគាំទ្រស្ថាប័នមូលដ្ឋាន ទាំងដំណើការ និងការគ្រប់គ្រងទូទៅដែលនឹងជួយឧបត្ថម្ភដល់កសិករនៅតាមជនបទ។ ការកំណត់ទំហំពិតប្រាកដសម្រាប់អភិវឌ្ឍគោលនយោបាយបន្ថែមដែលគាំទ្រដល់វារីវប្បកម្មលក្ខណៈគ្រួសារនៅក្នុងក្របខ័ណ្ឌការអភិវឌ្ឍជនបទ ហើយក៏មានឱកាសជាច្រើនដែលត្រូវបានគេពិចារណាផងដែរដើម្បីចែករំលែកបទពិសោធន៍ក្នុងការអភិវឌ្ឍនយោបាយនៅក្នុងអាងទន្លេមេគង្គពីព្រោះប្រទេសទាំងអស់កំពុងតែធ្វើការងារនៅក្នុងបរិស្ថានប្រែប្រួលនេះ។

## ២.២.៣ បញ្ហាថ្នាក់តំបន់

បញ្ហាក្នុងតំបន់អាងទន្លេមេគង្គដែលបានជះឥទ្ធិពលដល់វារីវប្បកម្ម និងឱកាសសម្រាប់សហប្រតិបត្តិការក្នុងចំណោមបណ្តាប្រទេសជាប់អាងទន្លេមេគង្គក្នុងការជួយឧបត្ថម្ភគ្នាទៅវិញទៅមក និងការអភិវឌ្ឍនយោបាយ។ បញ្ហាទាំងអស់នេះរាប់បញ្ចូលនូវបញ្ហាថ្នាក់ជាតិដែលជាលក្ខណៈធម្មតាចំពោះថ្នាក់តំបន់ ហើយបញ្ហានេះជាធម្មតាកើតឡើងចំពោះបណ្តាប្រទេសដែលនៅក្នុងអាងទន្លេមេគង្គ។

បញ្ហាដែលពាក់ព័ន្ធនឹងវារីវប្បកម្មនេះគឺបញ្ជាក់ពីតម្រូវការក្នុងការចែករំលែកនូវបទពិសោធន៍ និងជំនាញក្នុងការធ្វើវារីវប្បកម្មលក្ខណៈគ្រួសារ និងការរីកចំរើនរបស់ខ្លួនក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍តាមជនបទ។ ឱកាសមានជាច្រើនដែលគួរឱ្យពិចារណាសម្រាប់បណ្តាប្រទេសជាប់អាងទន្លេមេគង្គដើម្បីចែករំលែកព័ត៌មានកែលំអទំនាក់ទំនង ដោយជំរុញកិច្ចសហប្រតិបត្តិការស្រាវជ្រាវបច្ចេកទេស និងការពិភាក្សាលើយុទ្ធសាស្ត្រថ្មីៗ។ ប្រហែលជាមានឱកាសផ្សេងទៀតសម្រាប់បណ្តាញ និងការចែករំលែកក្នុងចំណោមអ្នកផលិតជាលក្ខណៈគ្រួសារ ប៉ុន្តែបញ្ហាភាសារវាងភាគីនឹងក្លាយជាបញ្ហាយ៉ាងច្បាស់ដល់កិច្ចសហការនេះផងដែរ។

បញ្ហាតំបន់ពីរដែលមានការចាប់អារម្មណ៍ពិសេស គឺការត្រួតពិនិត្យជម្ងឺវារីសត្វ និងនយោបាយដែលកាត់បន្ថយបច្ច័យអាក្រក់ចែងឡចំពោះផលស្តុកត្រីធម្មជាតិដែលបណ្តាលមកពីការនាំចូលប្រភេទត្រីក្រៅស្រុក ឬចលនាគ្រប់គ្រងតំបន់រួមគ្នា និងការបញ្ចូលប្រភេទត្រីក្នុងស្រុកដែលមានសេនេទិចផ្សេងគ្នា ។

**កិច្ចសហប្រតិបត្តិការត្រួតពិនិត្យជម្ងឺវារីសត្វ**

ជម្ងឺវារីសត្វអាចរាលដាលយ៉ាងលឿនឆ្លងកាត់ដែនទឹកធម្មជាតិ និងព្រំប្រទល់ប្រទេសដែលនាំទៅដល់ការបាត់បង់ផលស្តុកត្រី និងការចិញ្ចឹមជីវិតរបស់អ្នកផលិត។ ជំនាញការក្នុងការត្រួតពិនិត្យជម្ងឺត្រី ក៏មានលក្ខណៈផ្សេងគ្នាផងដែររវាងបណ្តាប្រទេស ដូច្នេះការចែករំលែកនិងការផ្តល់ផលប្រយោជន៍ក្នុងចំណោមសមាសភាពផ្សេងៗនៃផែនការគ្រប់គ្រងសុខភាពវារីវប្បកម្មឱ្យមានប្រសិទ្ធភាព និងផែនការផ្សេងៗទៀតដែលអាចកាត់បន្ថយយ៉ាងសំខាន់នូវរាល់ផលប៉ះពាល់បណ្តាលមកពីជម្ងឺ ហើយធ្វើឱ្យខូចខាតដល់សេដ្ឋកិច្ចសង្គម។ ជាញឹកញាប់ ការលេចចេញជាជម្ងឺរាលដាលគឺកើតឡើងភាគច្រើនដោយសារភាពអសកម្មក្នុងការងារ ជាជាងកង្វះខាតខាងចំណេះដឹងបច្ចេកទេសវិទ្យាសាស្ត្រ។ ដូច្នេះផែនការគ្រប់គ្រងព្រំដែនរួមគ្នាដែលបានអនុវត្ត និង បានសហការត្រូវបានគេផ្តល់ជាអនុសាសន៍ដូចតទៅ ១) បង្កើតការតាមដានជម្ងឺឱ្យមានប្រសិទ្ធភាព និងប្រព័ន្ធរបាយការណ៍ ២) ពង្រឹងសេវាកម្មរោគសញ្ញា ៣) កែលំអធនធានមនុស្ស និងបណ្តុះបណ្តាលសមត្ថភាពថ្នាក់ជាតិ និងតំបន់ដើម្បីជំរុញសកម្មភាពគ្រប់គ្រងជម្ងឺ ៤) ពង្រឹងឆន្ទៈសម្រាប់ការប្រឈមមុខរាល់ជម្ងឺដែលកើតឡើងថ្មីៗ ៥) គាំទ្រការបង្កើតនយោបាយ និងប្រព័ន្ធច្បាប់ឱ្យបានសមស្រប ៦) ជំរុញការកសាងដោយការចូលរួមដោយសហគមន៍ និងការវិនិយោគទុនឯកជន និង ៧) ផ្តល់អំណាចដល់សហគមន៍មូលដ្ឋានដោយភ្ជាប់ជាមួយនូវចំណេះដឹង និងឧបករណ៍ សម្ភារៈដើម្បីឱ្យយល់កាន់តែច្បាស់ ហើយអាចកាត់បន្ថយនូវគ្រោះថ្នាក់ដោយជម្ងឺ។

**ការគ្រប់គ្រងធនធានសេនេទិច**

ការចាំបាច់ដើម្បីអភិវឌ្ឍន៍នយោបាយ និងយុទ្ធសាស្ត្ររួមសម្រាប់ការគ្រប់គ្រងប្រភេទត្រីនាំចូល។ ការអនុវត្តបែបនេះដោយសារមានការពាក់ព័ន្ធនឹងផលប៉ះពាល់ទៅលើអេកូឡូស៊ីធម្មជាតិ។ ប្រភេទត្រីក្នុងស្រុកដែលគេបានអនុវត្តគួរត្រូវបានគេប្រើប្រាស់សម្រាប់វារីវប្បកម្មនៅកន្លែងណា? ប៉ុន្តែប្រភេទត្រីទាំងអស់នោះអាចជាប្រធានបទចំពោះបញ្ហានៃការបង្កាត់ និងចិញ្ចឹមចំរុះប្រសិនបើមិនបានយកចិត្តទុកដាក់ទេ។ ដើម្បីថែរក្សានូវសេនេទិចចំរុះ គោលនយោបាយដែលពាក់ព័ន្ធការគ្រប់គ្រងត្រីមេពូជ និងចលនាគ្រប់គ្រងព្រំដែនរួមគ្នា គឺជាកត្តាមួយដ៏ចាំបាច់ដែលត្រូវធ្វើ។

## ២.៣ តម្រូវការ និង ការខ្វះខាតព័ត៌មានដែលត្រូវបំពេញសម្រាប់វារីវប្បកម្ម

នៅពេលបច្ចេកវិទ្យាសម្រាប់អភិវឌ្ឍន៍វារីវប្បកម្មជាលក្ខណៈគ្រួសារមានលទ្ធភាពគឺមិនចាំបាច់ធ្វើការស្រាវជ្រាវបច្ចេកទេសទៀតទេ។ ការយកចិត្តទុកដាក់បន្ថែមទៀតនោះគឺគួរត្រូវផ្ដល់ជំនួសវិញដោយការផ្សព្វផ្សាយ និង ការទំនាក់ទំនងនៃចំណេះដឹងដែលមានក្នុងមធ្យោបាយ ហើយសមស្របទៅនឹងគ្រួសារនៅតាមជនបទ។ ឧទាហរណ៍ ការអនុវត្តល្អនូវយុទ្ធសាស្ត្រទាំងនេះនឹងមានភាពចាំបាច់ដល់ការចែករំលែកបទពិសោធន៍ឱ្យកាន់តែទូលាយថែមទៀត។

ការសម្របសម្រួល និងការផ្លាស់ប្ដូរព័ត៌មានដែលមានឱ្យបានល្អប្រសើរ និងបទពិសោធន៍នានា កំពុងប្រែក្លាយភាពចាំបាច់ឱ្យកាន់តែកើនឡើង ដូចជាត្រូវការបញ្ចូលអ្នកទទួលផលប្រយោជន៍សមស្របទាំងអស់ដោយរាប់បញ្ចូលផងដែរនូវចំនួនគ្រួសារក្រីក្រទៅក្នុងការពិភាក្សាបន្ថែម។

ស្ថិតិជលផលផ្លូវការស្ដីពីវារីវប្បកម្មស្ថិតនៅក្រោមការប៉ាន់ប្រមាណ ទោះបីជាវារីវប្បកម្មជាលក្ខណៈគ្រួសារបានធ្វើជំរឿនក៏ដោយ ហើយផ្អែកលើការអង្កេតតាមគ្រួសារ លទ្ធផលបានចង្អុលបង្ហាញពីចំណុចសំខាន់ខ្លះៗដែលបានកើនឡើង។ ដើម្បីឆ្លុះបញ្ចាំងពីសារៈសំខាន់នៃវារីវប្បកម្មជាលក្ខណៈគ្រួសារនេះ ភ្នាក់ងារជលផលរបស់រដ្ឋាភិបាលគួរតែគិតគូរពិចារណា និងសហការមួយវិស័យផ្សេងទៀតដើម្បីទទួលបានទិន្នន័យពីតំបន់ជនបទ ដូចដែលបានធ្វើការយ៉ាងល្អនៅក្នុងប្រទេសឡាវ។

ដើម្បីឧបត្ថម្ភវារីវប្បកម្មជាលក្ខណៈគ្រួសារ របៀបវារៈស្រាវជ្រាវគួរតែប្រើយុទ្ធសាស្ត្រឱ្យមានការចូលរួម និងត្រូវធ្វើឡើងដោយកសិករ និងតម្រូវឱ្យមានការអភិវឌ្ឍ។ ការទំនាក់ទំនងឱ្យកាន់តែប្រសើរ គឺជាកត្តាដ៏ចាំបាច់ផងដែររវាងការស្រាវជ្រាវផ្សព្វផ្សាយ អ្នកផ្ដល់ការអប់រំ និងផ្ដោតការយកចិត្តទុកដាក់ពីសេចក្ដីត្រូវការរបស់កសិករ។ ទាំងអស់នេះរាប់បញ្ចូលផងដែរនូវ :

- ការជំរុញវារីវប្បកម្មត្រីក្នុងស្រុកតាមរយៈការស្រាវជ្រាវពីការចិញ្ចឹម និងសេនេទិច ព្រមទាំងការអភិវឌ្ឍគោលនយោបាយសមស្រប។
- ការបង្កើតចំណីសមស្រប និងការប្រើប្រាស់ចំណី និងជីប្រភេទណាដែលមានប្រសិទ្ធភាព។
- ការសិក្សាស្រាវជ្រាវជីវៈ-សេដ្ឋកិច្ច លើការប្រើប្រាស់ត្រីចាប់ពីធម្មជាតិ មកធ្វើជាចំណីត្រី។
- ការលើកទឹកចិត្តកសិករឱ្យចូលរួមការងារវារីវប្បកម្ម ដើម្បីជាប្រយោជន៍ជួយបង្កើននូវផលិតកម្មកសិកម្មរបស់កសិករ និងក៏ជាវិធីសាស្ត្រគ្រប់គ្រងសត្វល្អិតចង្រៃមួយសំរាប់កសិករអាចទទួលយកបាន ព្រមទាំងអាចជៀសផុតពីការប្រើប្រាស់ថ្នាំពុលសំលាប់សត្វល្អិតដែលមានផលប៉ះពាល់មិនល្អ។ ការងារនេះគួរតែបញ្ចូលបន្ថែមទៀតនូវវិធីសាស្ត្រងាយៗ ដូចជារូបភាពងាយយល់ ដើម្បីបង្ហាញឱ្យឃើញកាន់តែច្បាស់ពីអត្ថប្រយោជន៍សេដ្ឋកិច្ចទទួលបានពីវិធីសាស្ត្រគ្រប់គ្រងសត្វល្អិតចង្រៃ (IPM) និងការធ្វើវារីវប្បកម្មឬការចិញ្ចឹមត្រីក៏ដូចជាផ្ដល់នូវព័ត៌មានបច្ចេកទេសបន្ថែមផ្សេងៗទៀត។ ការងារសិក្សានេះអាចរៀបចំឡើងដោយប្រើប្រាស់នូវវិធីសាស្ត្រសាមញ្ញដែលបានអនុវត្តរួចដោយកសិករនៅប្រទេសបង់ក្លាដេសដោយបូកបញ្ចូលគ្នារវាងកសិដ្ឋានគ្រប់គ្រងចង្រៃជាមួយនឹងការងារចិញ្ចឹមត្រីដែលមានអត្ថប្រយោជន៍ច្រើន និងអាចយកទៅអនុវត្តបាននៅតាមដងទន្លេមេគង្គ ។
- ការជួយកាត់បន្ថយវិបត្តិគ្រោះថ្នាក់ដល់ប្រជាកសិករនៅជនបទតាមរយៈការប្រើប្រាស់ធនធានជលផលធម្មជាតិដែលមានមេរោគ។
- ការអភិវឌ្ឍប្រព័ន្ធវារីវប្បកម្មដោយគិតគូរសំខាន់ទៅលើការជួយកាត់បន្ថយភាពក្រីក្រដែលរួមបញ្ចូលទាំងការចិញ្ចឹមត្រីក្នុងបៃ ដោយប្រើប្រាស់បច្ចេកទេសសមស្រប និង
- ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងបរិស្ថានដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធការងារវារីវប្បកម្ម ដូចជាការចិញ្ចឹមត្រីក្នុងបៃជាដើម។

### ២.៣.១. ការស្រាវជ្រាវប្រព័ន្ធកសិដ្ឋានដោយយកដំណាំស្រូវជាមូលដ្ឋាន

ការបង្កើនផលិតផលស្រូវ គឺជានិច្ចកាលត្រូវបានធ្វើការផ្សព្វផ្សាយដោយបណ្ដាស្ថាប័ន ឬភ្នាក់ងារជាតិ និងអន្តរជាតិដោយមិនបានគិតគូរការប្រើប្រាស់ដីធ្លីទៅលើការងារផ្សេងៗទៀតឡើយ។ ការចិញ្ចឹមត្រីនៅក្នុងស្រែជាមួយស្រូវជាប្រការដ៏ប្រសើរមួយសម្រាប់ប្រជាកសិករដែលអាចផ្ដល់ផលខ្ពស់ជាងការធ្វើស្រែចំនួនពី ២ ទៅ ៣ ដង។ តំបន់លិចទឹកក៏ចាត់ទុកថា ជាទ្រព្យសម្បត្តិមួយដែលអាចជួយផ្ដល់នូវផលប្រយោជន៍ច្រើនដល់សហគមន៍ទូទៅ ព្រោះថាវាជាកន្លែងជំរកដ៏ល្អសម្រាប់ត្រីពងកូន និងបន្តពូជ ដែល

ល្អប្រសើរជាងក្នុងករណីយើងយកតំបន់ដីសើមនេះមកប្រើប្រាស់សំរាប់ធ្វើស្រែចំការតែប៉ុណ្ណោះ ។ ការស្រាវជ្រាវគឺត្រូវការជាចាំបាច់នូវការធ្វើសហប្រតិបត្តិការរវាងស្ថាប័នទាក់ទងសំខាន់ៗដូចជាកសិកម្មជលផល និងកម្មវិធីអភិវឌ្ឍន៍តំបន់ជនបទព្រមទាំងភ្នាក់ងារផ្សេងៗទៀត ដើម្បីសំរេចជោគជ័យនូវគោលដៅរបស់ខ្លួន ពោលគឺការធ្វើឱ្យប្រសើរឡើងនូវកំរិតជីវភាពរស់នៅរបស់ប្រជាកសិករនិងសហគមន៍ទូទៅផងដែរ ។

ជាតំរូវការចាំបាច់ណាស់នូវការសហប្រតិបត្តិការផ្សព្វផ្សាយឱ្យមានប្រសិទ្ធភាពជាមួយវិស័យកសិកម្មពីព្រោះថា ជាស្ថាប័នមួយ ជាអ្នកសាកល្បងពិសោធន៍នូវរាល់វិធីសាស្ត្រផ្សេងៗ ដើម្បីទទួលបាននូវបច្ចេកវិជ្ជាថ្មីសំរាប់ផ្សព្វផ្សាយជូនដល់កសិករអនុវត្តបន្តដោយមានការចូលរួមធ្វើការផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសដល់កសិករដ៏ទៃទៀតដែលក្នុងនោះរួមបញ្ចូលទាំងការងារគ្រប់គ្រងចំរុះ (IPM) ផងដែរ ដែលបានធ្វើឱ្យវិស័យជលផលអាចទទួលយកបាននូវផលប្រយោជន៍ជាច្រើន ។

## ២,៣,២, ការអភិវឌ្ឍប្រភេទត្រីក្នុងស្រុក

ប្រភេទត្រីក្នុងស្រុក គឺជាប្រភេទត្រីដែលមានការពេញនិយមពីសំណាក់ប្រជាពលរដ្ឋខ្មែរទូទៅ និងអ្នកប្រើប្រាស់ផ្សេងៗទៀតដែលរស់នៅតាមដងទន្លេមេគង្គ ហើយក៏ជាប្រភេទត្រីដែលត្រូវបានគិតគូរយកមកធ្វើការផ្សព្វផ្សាយក្នុងការងារវារីវប្បកម្ម ។ ការងារនេះត្រូវការចាំបាច់ឱ្យមានការឧបត្ថម្ភគាំទ្រ ដើម្បីធ្វើការអភិវឌ្ឍផែនការគ្រប់គ្រងត្រីមេពូជដែលជាអាទិភាពចំបងក្នុងការការពារ និងជៀសឱ្យផុតនូវការបង្កាត់ជាន់លើហ្សែនតែមួយ ឬក្នុងអំបូរតែមួយ និងថែរក្សាការពារឱ្យបាននូវសេនេទិចផ្សេងៗគ្នា ។ ការគិតគូរនេះក៏គួរត្រូវបានបង្កើតឱ្យចេញជាច្បាប់ផងដែរសំរាប់វិស័យឯកជន ( ទាំងប្រព័ន្ធអាងបង្កាត់ភ្ញាស់ និងប្រព័ន្ធស្រះបំប៉នកូនត្រី) និងក៏ដូចជាបណ្តុះស្ថានីយ៍ផលិតកូនត្រីរដ្ឋផងដែរ ។ រាល់ច្បាប់ទាំងនោះគួរត្រូវមានការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុផងដែរ ។

## ២,៤, តម្រូវការផែនការចំរុះ និង បទបញ្ញត្តិ

យុទ្ធវិធីដើម្បីធ្វើការអភិវឌ្ឍវារីវប្បកម្ម គឺជាផែនការមួយដ៏សំខាន់ដែលត្រូវបានដាក់ចេញឱ្យទាន់ពេលវេលា ។ មកដល់ពេលនេះឃើញថា រាជរដ្ឋាភិបាលបាននឹងកំពុងចូលរួមយ៉ាងសកម្មក្នុងការងារផ្សព្វផ្សាយការងារអភិវឌ្ឍន៍វារីវប្បកម្មព្រមទាំងក៏បានដាក់បញ្ចូលនៅក្នុងផែនការការងារអភិវឌ្ឍជនបទរួចជាស្រេចផងដែរ ។ ការផ្សព្វផ្សាយវារីវប្បកម្មគួរត្រូវបានចាត់ទុកថាជាការប្រើប្រាស់សម្រាប់ដោះស្រាយអសន្តិសុខស្បៀង និងភាពក្រីក្រដែលនេះជាជំហានចាប់ផ្តើមមួយជួយធ្វើអន្តរាគមន៍ដល់ការងារអភិវឌ្ឍន៍វារីវប្បកម្ម ។ ទាំងនេះមានន័យថាចូលរួមទាំងអស់គ្នាធ្វើការស្រាវជ្រាវដើម្បីរកឱ្យឃើញនូវបញ្ហាមួយចំនួនដែលនឹងជាប្រយោជន៍ដល់ការចាប់ផ្តើមអភិវឌ្ឍន៍វារីវប្បកម្មដូចជាការកសាងសមត្ថភាពនៅតាមស្ថាប័ននានា ( ជាពិសេស ការកសាងសមត្ថភាពនៅក្នុងតំបន់) សម្រាប់ការងារផ្សព្វផ្សាយ និងការងារគ្រប់គ្រង និងការធ្វើវារីវប្បកម្មចំរុះរួមបញ្ចូលជាមួយគ្នាគម្រោងជលផលផ្សេងៗ ក៏ដូចជានៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍតំបន់ជនបទ ។ យុទ្ធវិធីគ្រប់គ្រងផលចាប់ ឬផលនេសាទត្រី ត្រូវបានធ្វើការផ្សព្វផ្សាយដោយគម្រោង MRC កន្លងមករួចហើយ ដែលជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍អាងទន្លេមេគង្គ ។ លទ្ធផលទាំងនេះគួរយកមកធ្វើការអភិវឌ្ឍ និងការសាកល្បងយុទ្ធវិធីគ្រប់គ្រងបន្ថែមទៀត ដើម្បីជួយដល់ការអភិវឌ្ឍវារីវប្បកម្ម និងដាក់បញ្ចូលវិស័យនេះទៅក្នុងផែនការបង្កើនផលស្តុកជលផល និងការងារអភិវឌ្ឍតំបន់ជនបទ ។

រាល់ចំនុចទូទៅខាងក្រោម គួរត្រូវបានពិចារណានៅគ្រប់បុព្វបទនៃការអភិវឌ្ឍវិស័យវារីវប្បកម្ម :-

- គាំពារឱ្យមានការកសាងសមត្ថភាពនៅគ្រប់ស្ថាប័នដូចជាតាមថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីសម្រេចបាននូវយុទ្ធវិធីក្នុងការផ្សព្វផ្សាយ និងការស្រាវជ្រាវ ។
- លើកទឹកចិត្តដល់ដៃគូរណាដែលមានអាទិភាពក្នុងរដ្ឋាភិបាលដូចជាអង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជនដែលអាចដោះស្រាយបាននូវរាល់តម្រូវការរបស់ប្រជាជននៅតាមជនបទ ។
- បង្កើនឱ្យមានប្រព័ន្ធផ្សព្វផ្សាយ និងបទពិសោធន៍រួមនៅគ្រប់យុទ្ធវិធីផ្សព្វផ្សាយណាដែលមានប្រសិទ្ធភាព ។
- ចែករំលែកព័ត៌មានពីគ្នាទៅវិញទៅមក ទាំងខាងគោលនយោបាយ និងការងារអនុវត្ត ។
- ពង្រឹង និងយកចិត្តទុកដាក់ដោយធ្វើការអំពាវនាវដល់អ្នកដែលប្រើប្រាស់ធនធានវារិជាតិបានតិចតួចនៅក្នុងដំណើរការអភិវឌ្ឍគោលនយោបាយ ។

## ២.៥. ឧបសគ្គក្នុងវារីវប្បកម្ម និង ដំណោះស្រាយសមស្រប

រាល់ឧបសគ្គក្នុងវារីវប្បកម្ម និង ដំណោះស្រាយសមស្របមានបរិយាយដូចខាងក្រោម ៖

- សកម្មភាពផ្សព្វផ្សាយដោយស្ថាប័នរដ្ឋ គឺមានជួបបញ្ហាដោយសារតែពួកគេមិនមានបុគ្គលិកគ្រប់គ្រាន់ និង ខ្វះខាតធនធាន។ ទោះបីយ៉ាងនេះក្ដីធនធានមនុស្សអាចរកបាននៅតាមមូលដ្ឋាន ប៉ុន្តែទាមទារឱ្យមានការបណ្ដុះបណ្ដាលពួកគេជាមុនសិន ដើម្បីឱ្យពួកគេចូលរួមប្រកបដោយប្រសិទ្ធភាពនៅរាល់យុទ្ធសាស្ត្រផ្សព្វផ្សាយ និងអភិវឌ្ឍន៍។
- គោលនយោបាយនេះបានទាមទារឱ្យមានការគាំទ្រដល់យុទ្ធសាស្ត្ររួមលើវិស័យជលផល និងវិស័យវារីវប្បកម្មដែលពុំទាន់មាននៅឡើយ ដូចនេះការជំរុញឱ្យមានការងារបែបនេះ គឺទាមទារនូវពេលវេលាហើយដំណើរការក៏នឹងមានលក្ខណៈយឺតយ៉ាវទៅតាមបទពិសោធន៍ដែលមានស្រាប់ផងដែរ។ ការសិក្សាសាកល្បងដែលបានជ្រើសរើស និងឱកាសនៃការផ្លាស់ប្ដូរបទពិសោធន៍អាចចូលរួមចំណែកដល់ការអភិវឌ្ឍគោលនយោបាយ។
- ការថយចុះបរិស្ថាន គឺជាឧបសគ្គដ៏លំបាកមួយដែលមានអានុភាពលើវិស័យវារីវប្បកម្ម និងរាល់ប្រភពធនធានជលផលនៅក្នុងធម្មជាតិនៅក្នុងទន្លេមេគង្គ។ វារីវប្បកម្មបានទទួលរងគ្រោះដោយមហន្តរាយពីធម្មជាតិ ជម្ងឺរាតត្បាតការយាយីពីប្រភេទនាំចូលដែលបានរួចចូលទៅក្នុងធម្មជាតិ និងការបំពុលទឹក។ យុទ្ធសាស្ត្រគ្រប់គ្រងចាំបាច់ត្រូវបង្កើតឱ្យមានដើម្បីអាចដោះស្រាយបាននូវរាល់បញ្ហាដោយថាហេតុទាំងនេះ។
- យុទ្ធសាស្ត្រតាមតំបន់បានបង្អាក់ដល់ការធ្វើសមាហរណកម្មរួមគ្រប់តំបន់ ដូចជាមានភាពខ្សោយក្នុងការទំនាក់ទំនងជាមួយម្ចាស់ជំនួយ។ ការធ្វើការទំនាក់ទំនង និងសហការបែបសមាហរណកម្មជាប្រពៃណីនោះ គឺតែងតែជួបនូវការលំបាកប៉ុន្តែបញ្ហានេះអាចដោះស្រាយបាននៅពេលណាគ្រប់ភ្នាក់ងារធ្វើការរួមគ្នានៅតាមមូលដ្ឋាន។
- ទីផ្សារ និងការធ្វើដំណើរទៅកាន់ទីផ្សារ គឺជាវិធានបទមួយដែលបានស្រាវជ្រាវក្នុងតំបន់អាងទន្លេមេគង្គហើយការសិក្សានេះបានប្រៀបធៀបភាគច្រើនទៅលើគោលគំនិតនៃការអភិវឌ្ឍវិស័យវារីវប្បកម្ម។ ការយល់ដឹងដ៏ទូលំទូលាយពីទីផ្សារ និងប្រព័ន្ធរបស់ទីផ្សារ គឺជាមូលដ្ឋានគ្រឹះសំរាប់ជួយកែលំអដល់អ្នកផលិត ហើយអាចឱ្យពួកគេរកទីផ្សារបាន ជាពិសេសនោះអាចផ្ដល់ឱកាសឱ្យពួកគេពង្រីកមុខរបរផ្សេងទៀតបាន និងអាចរកចំណូលបានច្រើនពីការធ្វើវារីវប្បកម្មរបស់ពួកគេ។

# ៣

# អនុសាសន៍

## អនុសាសន៍សម្រាប់វារីវប្បកម្ម និង ការអភិវឌ្ឍនៅតំបន់អាងទន្លេមេគង្គ

ការអភិវឌ្ឍវារីវប្បកម្មនៅក្នុងតំបន់អាងទន្លេមេគង្គគឺជាកត្តាសំខាន់មួយដែលអាចឆ្លើយតបទៅនឹងតម្រូវការផលិតផលជលផលនាពេលអនាគត ហើយទង្វើនេះក៏ត្រូវបានគេអនុវត្តដើម្បីជួយទប់ស្កាត់អសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់នេះផងដែរ។ ដើម្បីបង្កើនជាអតិបរមានៃការរួមចំណែកដ៏មានសក្តានុពលភាពដល់ការអភិវឌ្ឍតំបន់អាងទន្លេមេគង្គនេះ វារីវប្បកម្មគួរត្រូវបានទទួលការគាំទ្រចាត់ជាសមាសភាពមួយក្នុងវិស័យជលផល និងជាផ្នែកមួយក្នុងចំណោមផ្នែកផ្សេងទៀតនៃផែនការអភិវឌ្ឍតំបន់អាងទន្លេមេគង្គ។ ដើម្បីជំរុញផែនការនេះឱ្យមានសន្ទុះឈានទៅមុខអនុសាសន៍ដ៏មានសក្តានុពលភាពបានលើកឡើងក្នុងគោលដៅជួយគាំទ្រដល់កម្មវិធីរបស់គណៈកម្មការទន្លេមេគង្គ និងបណ្តាប្រទេសនៅតាមទន្លេមេគង្គ។

## ៣.១ យុទ្ធសាស្ត្រនៃការកសាងផែនការ និង អនុវត្ត

### ៣.១.១ ការប្រើប្រាស់យុទ្ធសាស្ត្រតំបន់អាងរងទឹកភ្លៀង

តំបន់អាងទន្លេមេគង្គបានបែងចែកពី ១០-២០ តំបន់រងទឹកភ្លៀងធម្មជាតិ ឬតាមក្រុមនៃតំបន់លិចទឹកសម្រាប់ជាការងាយស្រួលដល់គោលគំនិតនៃការកសាងផែនការ ហើយទស្សនៈនេះត្រូវកំពុងស្នើឡើងដោយគណៈកម្មការទន្លេមេគង្គដោយសារវាជាផ្នែកមួយដែលមាននៅក្នុងផែនការអភិវឌ្ឍន៍តំបន់អាងទន្លេមេគង្គ។ យុទ្ធសាស្ត្រថ្មីនេះផ្តល់ឱកាសដល់ការទ្រទ្រង់ប្រព័ន្ធអភិវឌ្ឍន៍វារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផលធម្មជាតិដែលមាននៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍តំបន់មេគង្គដ៏ធំនេះ។

**ដូច្នេះដើម្បីដោះស្រាយរាល់បញ្ហាដែលទាក់ទងនឹងផែនការនេះ អនុសាសន៍មួយចំនួនត្រូវបានផ្តល់ដូចខាងក្រោម :**

- ការអភិវឌ្ឍវារីវប្បកម្មនឹងត្រូវបានទ្រទ្រង់ ព្រោះជាផ្នែកមួយនៃយុទ្ធសាស្ត្រដូចមានក្នុងតំបន់រងទឹកភ្លៀងធម្មជាតិ។
- ការយល់ដឹងពីជីវភាពរស់នៅរបស់ប្រជាជន និងការពាក់ព័ន្ធទៅនឹងធនធានវារីសត្វនឹងត្រូវប្រើប្រាស់ធ្វើជាចំនុចចាប់ផ្តើមសម្រាប់អន្តរាគមន៍នៃការគ្រប់គ្រងវិស័យជលផល និងវារីវប្បកម្ម។
- សក្តានុពលភាពវារីវប្បកម្មនឹងត្រូវបានធ្វើអត្តសញ្ញាណកម្មនៅគ្រប់តំបន់រងទឹកភ្លៀងធម្មជាតិតាមលក្ខណៈចូលរួម និងធ្វើសមាហរណកម្មដោយពឹងផ្អែកលើការវាយតម្លៃពីស្ថានភាពជលផល និងតម្រូវការក្នុងការគាំទ្រដល់ស្ថាប័នជំនាញ។

នៅក្នុងតំបន់រងទឹកភ្លៀងធម្មជាតិនៃអាងទន្លេមេគង្គផលិតផលជលផល និងផលិផលវារីវប្បកម្ម (រួមបញ្ចូលទូវផលិតផលជលផលដែលមានចិញ្ចឹមនៅតាមអាងស្តុកទឹក) គឺជាកត្តាដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងសំខាន់ មិនអាចខ្វះបាន។ ការអភិវឌ្ឍវារីវប្បកម្មអាចធ្វើទៅបានដោយត្រូវពិនិត្យលើទំនាក់ទំនងនៃភាពសម្បូររបស់ត្រីនៅក្នុងធម្មជាតិ។ ប្រសិនបើត្រីក្នុងធម្មជាតិមិនមានតាមតម្រូវការទេ នោះជាកត្តាមួយជួយឱ្យការអភិវឌ្ឍវារីវប្បកម្មទទួលបានជោគជ័យ ហើយអាចឱ្យវារីវប្បករនាំផលិតផលវារីវប្បកម្មរបស់ខ្លួនចូលប្រឡូកក្នុងទីផ្សារបាន ព្រោះពូជត្រីដែលចិញ្ចឹម គឺសមស្រប និងមានរចនាសម្ព័ន្ធជាក់ លាក់។ ជាទូទៅ តំបន់អាងទន្លេមេគង្គគឺជាតំបន់មួយពុំមានត្រីគ្រប់គ្រាន់តាមរដូវកាលទេ ដូច្នេះវារីវប្បកម្មបានបង្ហាញពីជ័យជំនះរបស់ខ្លួនក្នុងការផ្តួលរំលំភាពក្រីក្រ និងជំនួសវិញដោយការផ្តល់នូវជាតិប្រូតេអ៊ីនសម្រាប់ទ្រទ្រង់រាងកាយ។ ចំពោះកន្លែងដែលមានធនធានធម្មជាតិសំបូរបែបវិញ វារីវប្បកម្មប្រហែលជាពុំសូវមានតួនាទីសំខាន់ប៉ុន្មានទេ។ ដូច្នេះនៅតំបន់នេះកិច្ចខិតខំអភិវឌ្ឍជលផលគួរកំណត់ឱ្យមានការគ្រប់គ្រងឱ្យបានប្រសើរដល់ធនធានមច្ឆជាតិដែលមានស្រាប់ និងធានាសន្តិសុខដល់ការរកទទួលទានធនធានទាំងនេះបានពីសំណាក់ប្រជាជនក្រីក្រ។ ការបែងចែកតំបន់អាងមេគង្គជាដែននេសាទធម្មជាតិផ្តល់ជាចំនុចចាប់ផ្តើមដ៏សមហេតុផលក្នុងការធ្វើបទអន្តរាគមន៍ចំគោលដៅ ហើយអាចដោះស្រាយបាននូវភាពក្រីក្រ និងអសន្តិសុខស្បៀងនៅក្នុងតំបន់។ ស្តែងចេញពីទស្សនវិស័យនៃធនធានជលផលបានធ្វើឱ្យតំបន់ទាំងមូល ភាគច្រើនទទួលរងគ្រោះពីផែនការអន្តរាគមន៍លើការគ្រប់គ្រងទឹកដូចជាទំនប់ជាច្រើននឹងត្រូវបានគេធ្វើអត្តសញ្ញាណ និងចាត់វិធានការគ្រប់គ្រង។ ហេតុដូចនេះរាល់យុទ្ធសាស្ត្រត្រូវបានអនុលោមទៅតាមកិច្ចខំប្រឹងប្រែងរបស់គណៈកម្មការទន្លេមេគង្គ ដើម្បីបង្កើតផែនការអភិវឌ្ឍន៍តំបន់អាងទន្លេមេគង្គនេះ។ ដោយយុទ្ធសាស្ត្រនៃការបែងចែកតំបន់រងទឹកភ្លៀងធម្មជាតិជាការងារមួយថ្មីនោះដូចនេះវាត្រូវបាន គេស្នើសុំឱ្យអនុវត្តយុទ្ធសាស្ត្រនេះតាមដំណាក់កាល។

**ដូចនេះ សូមជូនអនុសាសន៍ដូចខាងក្រោម :**

- ដែនទឹកធម្មជាតិមួយចំនួននឹងត្រូវបានជ្រើសរើសដើម្បីសាកល្បងទៅតាមយុទ្ធសាស្ត្រដែលបានគ្រោងឡើងដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃធនធានដែលមានក្នុងទឹក និងវិសាលភាពនៃភាពក្រីក្រ។
- មេរៀនដែលទទួលបានពីគម្រោងសាកល្បងនេះ គួរយកទៅអនុវត្តនៅតំបន់រងទឹកភ្លៀងធម្មជាតិផ្សេងទៀត។

## ៣.២ ការជួយគាំទ្រវារីវប្បកម្មគ្រួសារ

កត្តាចាំបាច់ជាច្រើនដែលជួយទ្រទ្រង់ផែនការអភិវឌ្ឍន៍វារីវប្បកម្មនាពេលអនាគតនៅក្នុងតំបន់អាងទន្លេមេគង្គ។ ជាងដប់ឆ្នាំកន្លងមកនេះ ការអភិវឌ្ឍបច្ចេកវិទ្យាត្រូវបានគេលើកយកមកចង្អុលបង្ហាញ និងបច្ចេកវិទ្យាវារីវប្បកម្មគ្រួសារត្រូវបានគេធ្វើការអភិវឌ្ឍន៍ លើកលែងតែការងារខ្លះដែលទាក់ទងនឹងប្រភេទត្រីពូជក្នុងស្រុក។

**ដូចនេះ សូមជូនអនុសាសន៍ដូចខាងក្រោម :**

- បំណងដ៏សំខាន់ក្នុងការអភិវឌ្ឍន៍វិស័យវារីវប្បកម្មពេលអនាគតគួរត្រូវបានតម្រង់ទិសឆ្ពោះទៅមុខលើវារីវប្បកម្មជាលក្ខណៈគ្រួសារ។
- សេចក្តីបញ្ជាក់នេះគួរត្រូវបានផ្តល់សម្រាប់បង្កើតឱ្យមានសេវាកម្មគាំទ្រដ៏មានប្រសិទ្ធិភាពចំពោះវារីវប្បកម្មជាលក្ខណៈគ្រួសារ។
- គោលនយោបាយ និងការធ្វើផែនការឆ្លុះបញ្ចាំងអំពីតម្រូវការរបស់ជីវភាពគ្រួសារនៅតាមជនបទ និងការគាំទ្រដែលធ្វើឱ្យប្រសើរឡើងដល់ការចូលដល់សេវាកម្មផ្សព្វផ្សាយពីសំណាក់ប្រជាជនមូលដ្ឋាន។
- គ្រប់របៀបវារៈស្រាវជ្រាវរបស់ស្ថាប័នជាតិ និងរបៀបវារៈដែលបង្កើតឡើងដោយគណៈកម្មការទន្លេមេគង្គ ដើម្បីគាំទ្រដល់កិច្ចការនេះ គឺពឹងផ្អែកលើតម្រូវការចាំបាច់ និងការចិញ្ចឹមជីវិតរបស់គ្រួសារនៅតាមជនបទ។

បទពិសោធន៍ខ្លះៗដែលបានធ្វើរួចហើយ ឧទាហរណ៍.គម្រោងផ្សព្វផ្សាយវារីវប្បកម្ម (READ) របស់គណៈកម្មការទន្លេមេគង្គ ដែលមាននៅភាគខាងត្បូងប្រទេសឡាវ គម្រោងថ្នាក់តំបន់របស់ណាកា (NACA) និងគំនិតផ្តួចផ្តើមរបស់គម្រោង STREAM ប៉ុន្តែ នៅតែមានសេចក្តីត្រូវការបន្ថែមទៀតដើម្បីរួមចំណែក និងពង្រីកយុទ្ធសាស្ត្រនេះឱ្យបានដល់កន្លែងផ្សេងទៀត។ សក្តានុពលភាព ដ៏សំខាន់បំផុតនៃវារីវប្បកម្មលក្ខណៈគ្រួសាររួមចំណែកដល់ការអភិវឌ្ឍនហើយកត្តាទាំងនេះប្រហែលជាអាចជួយដល់តំបន់អសន្តិ សុខស្បៀង និង អ្នករស់នៅតាមតំបន់ដាច់ស្រយាលនៃតំបន់អាងទន្លេមេគង្គ ដូចជានៅតាមតំបន់ខ្ពង់រាប ឬតំបន់ដែលនៅឆ្ងាយពីដែនទេសាទនៃតំបន់ទន្លេមេគង្គ និងបឹងទន្លេសាបនៃប្រទេសកម្ពុជា។ សក្តានុពលភាពទាំងនេះ ប្រែប្រួលទៅតាមស្ថានភាពនៃអាងទន្លេមេគង្គដែលនេះគួរត្រូវបានធ្វើការវាយតម្លៃតាម មធ្យោបាយរួមសហការគ្នាមួយ។

**ដូចនេះ សូមជូនអនុសាសន៍ដូចខាងក្រោម :**

- ផ្នែកនៃផែនការអភិវឌ្ឍន៍តំបន់រងទឹកភ្លៀងធម្មជាតិការធ្វើវិភាគគ្រប់យុទ្ធសាស្ត្រនៃសក្តានុពលភាពវារីវប្បកម្មគួរត្រូវបានគេយកចិត្តទុកដាក់ ដើម្បីគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍វារីវប្បកម្មក្នុងតំបន់យុទ្ធសាស្ត្រទាំងនោះ។

### ៣.២.១ ការកសាងសមត្ថភាពផ្សព្វផ្សាយ

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រដែលមានការចូលរួមក្នុងការធ្វើផែនការ និង ការផ្សព្វផ្សាយឱ្យទទួលបានជោគជ័យ ម្ចាស់ជំនួយ និងភ្នាក់ងារផ្គត់ផ្គង់នានាត្រូវតែបង្វែរការផ្តោតយកចិត្តទុកដាក់របស់ខ្លួនតែទៅលើបច្ចេកទេស ទាំងនេះអាចឱ្យគេងាកទៅរកយុទ្ធសាស្ត្រថ្មីដែលអាចបញ្ជាក់ពីការកសាងសមត្ថភាពបទពិសោធន៍រៀនសូត្រ និងការប្រាស្រ័យទាក់ទងគ្នា។

**ដូចនេះ សូមជូនអនុសាសន៍ដូចខាងក្រោម :**

- កត្តាជាអាទិភាពគួរត្រូវបានផ្តល់ដើម្បីឱ្យការអភិវឌ្ឍសមត្ថភាពថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និងស្ថាប័នជាតិក្នុងគោលដៅលើកតម្កើង ការយល់ព្រមរបស់ពួកគេនៅក្នុងយុទ្ធសាស្ត្រដែលមានការចូលរួមនៅក្នុងការផ្សព្វផ្សាយ និងការធ្វើផែនការដែលអាចឆ្លុះបញ្ចាំងអំពីតម្រូវការពិតប្រាកដរបស់គ្រួសារនៅតាមជនបទ។
- ការកសាងសមត្ថភាពគឺជាផ្នែកមួយនៃយុទ្ធសាស្ត្រប្រព័ន្ធក្នុងការអភិវឌ្ឍការផ្សព្វផ្សាយវារីវប្បកម្មនៅតាមដែនរងទឹកភ្លៀងធម្មជាតិនៃតំបន់អាងទន្លេមេគង្គ។

- តម្រូវការចាំបាច់សម្រាប់កសាងសមត្ថភាព និងភាពទទួលខុសត្រូវរបស់ស្ថាប័ននានាគួរត្រូវបានគេធ្វើការវាយតម្លៃថាជាផ្នែកមួយនៃការសម្រេចឱ្យបាននូវយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់រងទឹកភ្លៀងធម្មជាតិ ។

## ៣.២.២ របៀបវារៈស្រាវជ្រាវវារីវប្បកម្មសំដៅកសាងសមត្ថភាពកសិករ

មានស្ថាប័នជាតិជាច្រើននៅក្នុងតំបន់អាងទន្លេមេគង្គរក្សានូវសកម្មភាពរបស់ខ្លួនដែលធ្លាប់បានអនុវត្តកន្លងមក ហើយមានការពាក់ព័ន្ធដល់ការស្រាវជ្រាវ អភិវឌ្ឍ និងការពិនិត្យលើបច្ចេកទេសផងដែរ ។

**អនុសាសន៍មួយចំនួនមានដូចខាងក្រោម :**

- ដោយបុគ្គល និងថវិកាមានកំរិត សមត្ថភាពស្រាវជ្រាវគួរត្រូវសំដៅរកការអភិវឌ្ឍនៅតំបន់ជនបទ និងកាត់បន្ថយភាពក្រីក្រតាមរយៈការចូលរួមដែលនឹងបានទទួលផលនៅពេលអនាគតក្នុងការកំណត់ពីតម្រូវការនៃការរៀបចំ និងការអនុវត្តគម្រោង ការបង្កើតវគ្គបណ្តុះបណ្តាល និងការផ្សព្វផ្សាយ ការពិនិត្យ និងការវាយតម្លៃ ។
- ការអភិវឌ្ឍរបៀបវារៈនៃការស្រាវជ្រាវគឺអាស្រ័យនឹងតម្រូវការរបស់គ្រួសារនៅតាមជនបទ និងបានគាំទ្រដោយការអភិវឌ្ឍសមត្ថភាពខាងស្រាវជ្រាវដើម្បីឱ្យការស្រាវជ្រាវប្រព្រឹត្តទៅដោយមានការចូលរួមការពិនិត្យពិច័យ និងវាយតម្លៃ ។
- ការចូលរួមយ៉ាងផុលផុសពីអ្នកស្រាវជ្រាវផ្នែកវារីវប្បកម្មជាកត្តាមួយជួយជំរុញឱ្យមានការផ្តួចផ្តើមគំនិតអភិវឌ្ឍនៅតាមជនបទ និងការកសាងយុទ្ធសាស្ត្រដែលផ្តោតលើដែនរងទឹកភ្លៀងធម្មជាតិ ។
- យុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់រងទឹកភ្លៀងធម្មជាតិ នឹងជួយជំរុញភាពចាំបាច់ក្នុងការសិក្សាស្រាវជ្រាវដ៏ទូលំទូលាយដែលនឹងប្រើប្រាស់ធ្វើជាឱកាសសម្រាប់អ្នកស្រាវជ្រាវផ្នែកវារីវប្បកម្ម ហើយឱ្យពួកគេចូលរួមក្នុងដំណើរការ និងមានអានុភាពយ៉ាងជិតស្និទ្ធលើការអភិវឌ្ឍតាមតំបន់ជនបទ ។

ឯកសារនេះបានកំណត់អត្តសញ្ញាណជាច្រើនពីតម្រូវការចាំបាច់សម្រាប់ការងារសិក្សាស្រាវជ្រាវ និងបញ្ហាដែលត្រូវដោះស្រាយ ដូចជាការចិញ្ចឹមប្រភេទពូជត្រីក្នុងស្រុក ប្រព័ន្ធចិញ្ចឹមតាមវាលស្រែ និងប្រព័ន្ធផ្សេងៗទៀត ។ ការអភិវឌ្ឍ និងការអនុវត្តសកម្មភាពស្រាវជ្រាវទាំងនេះអាចនឹងជំនះបានយ៉ាងមានប្រសិទ្ធភាពតាមរយៈការពង្រឹងបន្ថែមឱ្យមានកិច្ចសហប្រតិបត្តិការស្រាវជ្រាវទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ។

**អនុសាសន៍មួយចំនួនមានដូចខាងក្រោម :**

- រាល់ឱកាសដែលអាចធ្វើឱ្យមានប្រសិទ្ធភាពដល់កិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងប្រព័ន្ធទំនាក់ទំនងគ្នាក្នុងចំណោមប្រទេសដែលនៅតាមដងទន្លេមេគង្គ និងស្ថាប័នស្រាវជ្រាវគួរត្រូវបានជំរុញឱ្យមាននៅគ្រប់ទីកន្លែង ដូចជាគម្រោងផ្តួចផ្តើមគំនិតរបស់គម្រោង STREAM និងគម្រោង AIMS ដែលកំពុងបានជំរុញ និងធ្វើកិច្ចការនេះ ។

## ៣.២.៣ កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ក្នុងការអភិវឌ្ឍគោលនយោបាយ

បញ្ហាជាច្រើនដែលពាក់ព័ន្ធនឹងវារីវប្បកម្មហើយហួសពីព្រំដែនជាតិនៅតំបន់អាងទន្លេមេគង្គដូចជាការធ្វើជំនួញកូនត្រីពូជ និងចរាចរវារីសត្វពីតំបន់រងទឹកភ្លៀងធម្មជាតិ ដែលបញ្ហានេះបានធ្វើឱ្យមានការកើនឡើងនូវការព្រួយបារម្ភខាងសេនេទិច និងសុខភាព ។ ការណែនាំឱ្យចិញ្ចឹមពូជថ្មី ឬការទទួលយកដោយគ្មានការប្រុងប្រយ័ត្នជាមុនអាចនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដោយអចេតនា ។ កិច្ចសហប្រតិបត្តិការរវាងប្រទេសដែលនៅតាមដងទន្លេមេគង្គនឹងមានប្រយោជន៍សំខាន់ដល់ដល់ការរៀបចំគោលនយោបាយរួមដោយមានការយល់ស្របគ្នា និងគោលនយោបាយយុទ្ធសាស្ត្រសម្រាប់ដោះស្រាយនូវរាល់បញ្ហាទាំងនេះ ។

**អនុសាសន៍មួយចំនួនមានដូចខាងក្រោម :**

- កិច្ចសហប្រតិបត្តិការនៃបណ្តាប្រទេសនៅតាមទន្លេមេគង្គនឹងត្រូវបានជំរុញឱ្យអភិវឌ្ឍយុទ្ធសាស្ត្រ ឬគោលនយោបាយបរិវើផលប្រយោជន៍ទាំងសងខាង និងផ្លាស់ប្តូរបទពិសោធន៍ក្នុងការអភិវឌ្ឍវារីវប្បកម្ម ។ បញ្ហាគន្លឹះជាច្រើនដែលប្រសូត្រចេញពីការផ្ទៀងផ្ទាត់ឡើងវិញនេះ គឺជាប្រភពធ្វើឱ្យមានកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍគោលនយោបាយ ។

**ការទ្រទ្រង់វារីវប្បកម្មគ្រួសារ គឺជាបរិបទដ៏សមហេតុផលចំពោះជីវភាពគ្រួសាររបស់ប្រជាជនក្រីក្រ**

មានឱកាសជាច្រើនសម្រាប់ការធ្វើវារីវប្បកម្មគ្រួសារ ហើយផ្តោតការយកចិត្តទុកដាក់ចំពោះអ្នកក្រីក្រដែលមាននៅក្នុងតំបន់អាងមេគង្គ និងឱកាសក្នុងការជំរុញឱ្យមានប្រសិទ្ធភាពនូវការផ្លាស់ប្តូរបទពិសោធន៍ និងជំនាញនានានៃបណ្តាប្រទេសជាសមាជិកក្នុងការជួយគាំពារដល់ការអភិវឌ្ឍនេះ។

**ប្រភេទត្រីនាំមកពីបរទេស ប្រភេទក្នុងស្រុក និង ចរាចរឆ្លងដែន**

ដោយសារមានការព្រួយបារម្ភចំពោះផលប៉ះពាល់នៅក្នុងប្រព័ន្ធបរិស្ថាន ការប្រើប្រាស់ប្រភេទនាំចូលគួរត្រូវជៀសវាងប្រសិនបើមានជម្រើសផ្សេង។ ដូច្នេះការសិក្សាស្រាវជ្រាវជាតម្រូវការដ៏ចាំបាច់ដើម្បីប៉ាន់ប្រមាណពីបច្ច័យមិនល្អ និងដើម្បីអភិវឌ្ឍន៍យុទ្ធសាស្ត្រគ្រប់គ្រងដែលមានលក្ខណៈត្រឹមត្រូវ និងគោលនយោបាយសម្រាប់គ្រប់គ្រងប្រភេទត្រីនាំចូល។ ការប្រើប្រាស់មេពូជដែលជាប្រភេទត្រីក្នុងស្រុកប្រហែលជាប្រធានបទមួយជួយដោះស្រាយរាល់បញ្ហាជួបប្រទះ ព្រោះថាអាចជៀសបាននូវភាពខុសគ្នានៃសេនេទិចនៅក្នុងធម្មជាតិ។ វិធីបែបនេះប្រហែលអាចដោះស្រាយបាន ឧទាហរណ៍ ការប្រើប្រាស់ត្រីធម្មជាតិដែលចាប់បានពីកន្លែងដែលនៅជិតកន្លែងអភិវឌ្ឍន៍វារីវប្បកម្ម ឬក៏ការជំរុញឱ្យមានកន្លែងភ្ញាស់នៅតាមមូលដ្ឋាន។ ការធ្វើដូចនេះបានលុះត្រាតែរៀបចំឱ្យមាន និងយល់ព្រមលើគោលនយោបាយរួមគ្នា។

**អនុសាសន៍មួយចំនួនត្រូវបានផ្តល់ជូនដូចខាងក្រោម :**

- ការវិភាគពីបច្ច័យមិនល្អនឹងត្រូវធ្វើការអនុវត្តដើម្បីវាយតម្លៃពីផលប៉ះពាល់ដែលលេចចេញពីការណែនាំឱ្យប្រើប្រាស់ប្រភេទត្រីនាំចូល និងបង្កើតឱ្យមាននូវគោលនយោបាយដ៏ត្រឹមត្រូវមួយ។
- គោលនយោបាយដែលជំរុញឱ្យមានការប្រើប្រាស់ប្រភេទត្រីនៅក្នុងអាងទន្លេមេគង្គសម្រាប់វារីវប្បកម្មគួរត្រូវបានរៀបចំដោយប្រទេសជាសមាជិកទន្លេមេគង្គក្នុងគោលដៅកែលំអការគ្រប់គ្រងមេពូជ។ យុទ្ធសាស្ត្រនេះអាចនឹងត្រូវសហការយ៉ាងជិតស្និទ្ធដោយពឹងផ្អែកលើការអភិវឌ្ឍតំបន់រងទឹកភ្លៀងធម្មជាតិជាមូលដ្ឋានសម្រាប់គាំទ្រដល់វារីវប្បកម្ម ក៏ដូចជាវិស័យជលផល។
- គួរបង្កើតគោលនយោបាយនៃអាងទន្លេមេគង្គចំពោះចរាចរឆ្លងដែននៃប្រភេទវារីសត្វរួមទាំងការដាក់ចិញ្ចឹមប្រភេទថ្មីសំរាប់តំបន់អាងរងទឹកភ្លៀង និងបណ្តាប្រទេសទន្លេមេគង្គ។

**ការបង្កើតផែនការគ្រប់គ្រងសុខភាពវារីវប្បកម្មនៅក្នុងតំបន់អាងទន្លេមេគង្គ**

ដោយមានការកើនឡើងនូវការអភិវឌ្ឍវារីវប្បកម្មនៅក្នុងតំបន់អាងមេគង្គប្រហែលអាចបណ្តាលឱ្យមានការរីករាលដាលជម្ងឺដល់វារីសត្វ ហើយជម្ងឺឆ្លងទាំងនេះងាយសាយភាយទៅតាមតំបន់រងទឹកភ្លៀងធម្មជាតិថ្នាក់ជាតិនីមួយៗ។ ជាងនេះទៀតកត្តានេះបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរបស់ប្រជាជនដែលជាវារីវប្បករទ្រង់ទ្រាយតូច និងប្រភេទត្រីដែលមាននៅក្នុងធម្មជាតិ។

**ដោយហេតុនេះ សូមផ្តល់ជូនអនុសាសន៍មួយចំនួនដូចខាងក្រោម :**

- ផែនការគ្រប់គ្រងសុខភាពវារីសត្វនឹងត្រូវបង្កើតឡើងនៅក្នុងតំបន់អាងទន្លេមេគង្គដោយយោងតាមអនុសាសន៍របស់អង្គការស្បៀងអាហារពិភពលោក និងអង្គការណាកា (FAO/NACA) ចរាចរនៃប្រភេទវារីសត្វមានជីវិត និងយោងតាមគោលការណ៍ណែនាំបច្ចេកទេសតំបន់អាស៊ីស្តីពីការគ្រប់គ្រងសុខភាពនៃប្រភេទវារីសត្វធ្វើចរាចរ យុទ្ធសាស្ត្រអនុវត្ត និងកិច្ចព្រមព្រៀងនៅទីក្រុងប៉េកាំង (FAO/NACA, 2000)។
- ផែនការគ្រប់គ្រងសុខភាពតំបន់មេគង្គគួរត្រូវមានលក្ខណៈអាចអនុវត្តបាន និងស្វែងរកគន្លឹះសំរាប់ដោះស្រាយរាល់បច្ច័យដែលមិនល្អហើយមានទំនាក់ទំនងនឹងការរីករាលដាលនៃជម្ងឺរបស់វារីសត្វ និងការចម្លងជម្ងឺឆ្លងដ៏ធ្ងន់ធ្ងរផ្សេងទៀតនៅក្នុងតំបន់អាងមេគង្គ។

### ៣.២.៤ កែលំអការសិក្សា ការប្រាស្រ័យទាក់ទងគ្នា និង ការអភិវឌ្ឍគោលនយោបាយ

មានឱកាសជាច្រើនសម្រាប់ផ្លាស់ប្តូរបទពិសោធន៍ ចំណេះដឹង និងការជំរុញឱ្យមានកិច្ចសហប្រតិបត្តិការនៅគ្រប់ស្ថាប័នជំនាញ និងភ្នាក់ងារផ្តល់ជំនួយនៅក្នុងតំបន់អាងទន្លេមេគង្គក្រោម ហើយក៏មានការផ្លាស់ប្តូរបទពិសោធន៍ និងចំណេះដឹងជាមួយបណ្តាភ្នាក់ងារនៅក្រៅតំបន់អាងទន្លេមេគង្គផងដែរ ឧទាហរណ៍ គម្រោង IPM គម្រោងវារីវប្បកម្ម និងប្រមូលផលិតផលជលផលតាមវាលស្រែជំរុញឱ្យមានសហគ្រប់គ្រង និងការប្រើប្រាស់ប្រភេទត្រីដែលជាពូជក្នុងស្រុក។

**ដោយហេតុនេះ សូមផ្តល់ជូនអនុសាសន៍មួយចំនួនដូចខាងក្រោម :**

- ការប្រាស្រ័យទាក់ទងបន្ថែមទៀត ការផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍រៀនសូត្រគួរត្រូវបានផ្តល់ជាអាទិភាពចំបងដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍវារីវប្បកម្ម។
- ការប្រាស្រ័យទាក់ទងនេះក៏អាចជួយស្វែងរកបាននូវចំណេះដឹងដ៏ប្រសើរ ហើយអាចទ្រទ្រង់អ្នកដែលប្រើប្រាស់ធនធាន និងជួយដល់ការកសាងសមត្ថភាព និងការអភិវឌ្ឍគោលនយោបាយ។

រដ្ឋាភិបាល និងជំនួយទ្រទ្រង់ការអភិវឌ្ឍវារីវប្បកម្មប្រហែលក្លាយជាបញ្ហារាំងស្ទះនៅឆ្នាំខាងមុខនេះ។ ការបញ្ជាក់បង្ហាញនេះគឺចង់ឱ្យដឹងពីសារៈសំខាន់ប្រកបដោយប្រសិទ្ធភាពនៃកិច្ចសហការគ្នានៅក្នុងចំណោមស្ថាប័នជាតិ ដែលនេះអាចជួយគាំទ្រដល់សកម្មភាពស្រាវជ្រាវ និងផ្សព្វផ្សាយ។

**ដោយហេតុនេះ សូមផ្តល់ជូនអនុសាសន៍មួយចំនួនដូចខាងក្រោម :**

- ជំរុញឱ្យមានកិច្ចសហការបន្ថែមទៀតនៅក្នុងចំណោមភ្នាក់ងារផ្គត់ផ្គង់ (ម្ចាស់ជំនួយ ធនាគារអភិវឌ្ឍ) ព្រោះថាកិច្ចប្រឹងប្រែងនេះ នឹងជួយឱ្យមានការគាំទ្រដល់ស្ថាប័ននៃបណ្តាប្រទេសទន្លេមេគង្គ។
- សេចក្តីបញ្ជាក់បង្ហាញផ្សេងទៀតបានកំណត់ថា ការអភិវឌ្ឍគួរត្រូវផ្តល់ឱ្យប្រទេសទន្លេមេគង្គ និងការគាំទ្រដែលមានការសហការជាមួយស្ថាប័នទាំងនេះ ពីសំណាក់ម្ចាស់ជំនួយ និងអង្គការតំបន់ និងអន្តរជាតិ។
- គម្រោងអភិវឌ្ឍន៍តំបន់រងទឹកភ្លៀងធម្មជាតិគួរត្រូវយកមកប្រើប្រាស់ដើម្បីផ្តល់ជាប្រភពមេរៀនសម្រាប់ការរៀបចំស្ថាប័នប្រកបដោយកិច្ចសហការដ៏ប្រសើរ និងជាពិសេសធ្វើឱ្យកិច្ចសហការល្អរវាងម្ចាស់ជំនួយ និងរដ្ឋាភិបាលកាន់តែមានប្រសិទ្ធភាពខ្ពស់។

# ឯកសារយោង និង អានបន្ថែម ៤

The following provides references to key aquaculture works quoted in thetext and to other more detailed technical information on aquaculture in the Mekong riparian countries.

Agricultural Census. 2000. Lao Agricultural Census, 1998/99 - highlights. Agricultural Census Office, Ministry of Agriculture and Forestry and National Statistics Centre, Vientiane. 62 pp.

Ahmed, M., H. Navy, L. Vuthy & M. Tiongco. 1998. Socio-economic assessment of freshwater capture fisheries of Cambodia. Report on a household survey. Mekong River Commission, Phnom Penh.

Ahmed,M.& P. Hirsch. Editors. 2000. Common property in the Mekong-Issues of sustainability and subsistence. ICLARM Studies Review,26.

AIT. 1997. Policy Paper No. 1: issues in developing fish seed supply. AIT Aqua Outreach,Asian Institute of Technology, Bangkok. 4 pp.

Anon. 2002. Vietnam Environment Monitor 2002.the World Bank, National Environment Agency, World Bank in Vietnam and Danish Agency for International Development (DNIDA). World Bank, Hanoi, 43 pp.

Bush, S. R. 2001. Review of fish marketing in Cambodia: Assessment of Mekong Fisheries. Component of the MRC Fisheries Programme,Working Paper No.2.Mekong River commission, Phnom Penh.

Coates, D. 2001. Biodiversity and fisheries management opportunities in the Mekong River Basin. Blue Millenium Conference Paper. Assessment of Mekong Fisheries Component of the MRC Fisheries Programme. Unpublished report, MRC, Phnom Penh.

Coates, D., A. F. Poulsen & S. Viravong. 2000. Governance and trans-boundary fish stocks in the Mekong River Basin. 2nd MRC Technical Symposium on Fisheries, Mekong River Commission, Phnom Penh.

DOF. 2001. Freshwater fish farm production. Freshwater Aquaculture Statistics Analysis Sub- Division. Fisheries Economic Division 5/2544 No. 5/2001. Department of Fisheries, Government of Thailand, Bangkok.

Funge-Smith, S.J.1999a. Small-scale rural aquaculture in Lao PDR (Part I). FAo Aquaculture Newsletter, August 1999. 22.

Funge-Smith, S.J.1999b. Some lessons learned in aquaculture extension. Provincial Aquaculture Development Project (LAO/97/007). Lao PDR. FAORAP, Bangkok.Funge-Smith, S. J. 1999c. Small-scale rural aquaculture in Lao PDR (Part II). *FAO Aquaculture Newsletter*, December 1999, 23:17-21.

Funge-Smith, S. J. 2001. Activity planning and hatchery renovation, Viet Nam, Aquaculture of indigenous Mekong species.Component(AIMS),Mekong River Commission,Phnom Penh. 56pp.

Funge-Smith, S. j. & P. DuBeau. 1999. Aquatic animal health management issues in rural aquaculture development in Lao PDR. In: Proceedings of DfID/FAO/NACA Regional Scoping Workshop on Primary Aquatic Animal Health Care in Rural, Small-scale Aquaculture Development in Asia, 27-30th September 1999. Dhaka, Bangladesh, NACA, Bangkok, Thailand.

Garaway, C.1999. Small water body fisheries and the potential for community led enhancement: case study in Lao PDR. Imperial College of Science Technology and Medicine, University of London, London. Ph.D. thesis. 413 pp.

Garrow, J. S. & W. P. T. James. Editors 1993. Human nutrition and dietetics, 9th ed. Churchill Livingstone, Edinburgh, UK.

Gregory, R. & H. Guttman.2002. The rice field catch and rural food security. Pp. 1-13. In: P. Edwards, DC. Little & H.Demaine. Editors. 2002. Rural Aquaculture. CABI Publishing, Wallingford, UK.

Gupta, M. V., B. Saphakdy & L. Khamsivilay. 2000. Review of aquaculture support to Lao PDR during 1975-2000. LARReC Technical Report No. 4, Vientiane.

Guttman, H. & S. J. Funge-Smith 2000. the role of aquaculture in rural subsistence livelihoods in Lao PDR. Provincial Aquaculture Development Project (LAO/97/007). STS Field Document 9. FAORAP, Bangkok.

Hambrey, J. 2002. Financial analysis and risk assessment of selected aquaculture and fishery activities in the Mekong basin. MRC Technical Paper No. 5, Mekong River Commission, Phnom Penh. 66 pp.

Haylor, G. 2000. Eight successful systems for promoting sustainable livelihoods through developing aquatic resource management systems that benefit the poor in SE Asia. Aquatic Resources Management Programme Briefing Paper2. DfID Southeast Asia, Bangkok (www. streaminitiative.org/virtuallibrary)

Haylor, G. 2001. Report of the email conference on poverty and aquatic resource. Aquatic Resources Management Programme. DfIF Southeast Asia, Bangkok(www. streaminitiative.org/ virtuallibrary)

INFOFISH. 2000. The potential of Cambodian fishery products in the international market: a market study. INFOFISH, Kuala Lumpur.

Interim Committee for the Coordination of Investigations of the Lower Mekong Basin. 1992. Fisheries in the Lower Mekong Basin, Main Report and Annex 5-8 interim Committee for the Coordination of Investigations of the Lower Mekong Basin, Bangkok.

Khanh, P. V., N. Tuan, N. V. Hao, Z. Jeney, T.Q.Trong & N.M.Thanh, 2000. Review of bioloty and breeding of some indigenous fish species in the Mekong Delta of Viet Nam. Management of Reservoir Fisheries in the Mekong Basin II. Component Report, Number 3. Vientiance.

LECS 2. 1999. The households of Lao PDR-social and economic indicators from the Lao Expenditure and Consumption Survey 1997/98. National Statistics Centre, State Planning Committee, Vientiane. 67 pp.

Leelapatra, W., P. Srisakultiew & N. Sukumasavin. 2000. Biology and breeding of indigenous fish species in Thailand. Management of Reservoir Fisheries in the Mekong Basin II. Component Report, Number 2. Mekong River Commission, Vientiance.

Lithdamlong, D., E.Meusch & N.I. Taylor. 2002. Promoting aquaculture by building the capacity of local institutions: developing seed supply networks in the Lao PDR. p. 155-166. In: P. Edwards, D.C. Little & H. Demaine (Editors). 2002. Rural aquaculture. CABI Publishing, Wallingford, UK.

MAF. 1999a. The government's strategic vision for the agricultural sector. Ministry of Agriculture and Forestry, Vientiane. 76 pp.

MAF. 1999b. Agricultural Statistics of Lao PDR-1998. Permanent Secretary Office of the Ministry of Agriculture and Forestry, Vientiane, 146 pp.

Meenakarn, S. 1998. Mini-hatchery development. Provincial Aquaculture Development Project (LAO/97/007), STS Field Document 1, FAORAP, Bangkok.

Meenakarn, S. 1999. Farmer training in small-scale hatchery techniques. provincial Aquaculture Development Project (LAO/97/007). STS Field Document 6. FAORAP, Bangkok.

Murray, U. Sayasane, K. & S. J. Funge-Smith. 1998. Gender and aquaculture in Lao PDR: a synthesis of a socio-economic and gender analysis of the UNDP/FAO Aquaculture Development Project LAO/97/007. Provincial Aquaculture Development Project (LAO/97/007), STS Field Document, FAORAP Bangkok.

Nam, S. & N. Thouk. 1999. Cambodia. Aquaculture sector review (1984-1999): an outline of national aquaculture development paln (2000-2020). APCU/DOF, Phnom Penh.

Nho, Pham Van & H. Guttman. 1999. Aquatic resources use assessment in Long An province, Viet Nam (results from 1997 survey). AIT Aqua Outreach Working Paper No. SV-52 Bangkok.

Phillips, M. 1998. Freshwater cage culture development in the reservoirs of the Central Highlands of Viet Nam. Report to the Mekong River Commission. Phnom Penh. 124 pp.

Phuong, N. T. 1998. Pangasius cage culture in the Mekong Delta-current situation and study for feeding improvement. Can Tho University, Viet Nam, Ph. D thesis.

Phovinsay, A. & S. R. Bush. 2001 Baseline study of the fish trade from the Siphandone Fishery in Champassak Province. LaRREC Research Report No. 4. Vientiane.

Potipitak, K. 1996. Aquaculture Extension Services Review: Thailand. FAO Fisheries Circular No. 910. FIRI/C910,. FAPRAP, Bangkok.

Sen, A.K. 1999. Development as freedom.Oxford University Press, Oxford, UK.

Sjorslev, J. G. Editor. 2001 An Giang Fisheries Survey, Viet Nam. Research Institute for Aquaculture No. 2 and Assessment of Mekong Fisheries Component of the MRC Fisheries Programme. Mekong River Commission, Phnom Penh.

Sverdrup-Jensen, S. 2002. Fisheries in the Lower Mekong Basin: status and perspectives. MRC Technical Paper No. 6, Mekong River Commission, Phnom Penh. 103 pp.

Tan, B., H. Choundara & H. Guttman. 1999 Mid-term evaluation report of LAO/97/007, FAO STS Field Document 8. Provincial Aquaculture Development Project LAO/97/007. Vientiane. 92 pp. FAO, Vientiane.

Tran T. X. & T. H. Tran. 2000. Report of status of aquaculture in the Mekong Delta of Viet Nam. Research Institute for Aquaculture No. 2, Ministry of Fisheries, Hanoi. 42 pp.

Welcomme, R. & C. Vidthayaonon. 1999. Report on the impacts of introduction and stocking in the Mekong Basin and policies for their control. Mekong River Commission, Vientisane. 66 pp.

WHO. 1999. Food safety issues associated with products from aquaculture. Report of joint FAO/NACA/WHO study group. WHO Technical Report Series 883, World Health Organisation, Geneva.

Wysocki, J. & R. Friend. 1998. Aquatic Resources and Rural Livelihood. Report to the ToR Regional Aquaculture Approach Assessing Potential for Poverty Reduction. DfID Southeast Asia, Bangkok. 39 pp.

*MRC Technical Papers*

**Status of the Mekong Pangasianodon hypophthalmus resources, with special reference to the stock shared between Cambodia and Viet Nam: MRC Technical Paper 1.**

Van Zalinge, Nicolaas; Lieng Sopha, Ngor Peng Bun, Heng Kong, and John Valbo Jorgensen. 2002. Status of the Mekong Pangasianodon hypophthalmus resources, with special reference to the stock shared between Cambodia and Viet Nam, MRC Technical Paper No. 1, Mekong River Commission, Phnom Penh. 29 pp.

**Status of Pangasiid aquaculture in Viet Nam: MRC Technical Paper 2**

Trong, Trinh Quoc, Nguyen Van Hao and Don Griffiths. 2002. Status of Pangasiid aquaculture in Viet Nam. MRC Technical Paper No. 2, Mekong River Commission, Phnom Penh. 16 pp.

**Mekong giant fish species: on their management and biology: MRC Technical Paper 3**

Mattson, Niklas S.,Kkongpheng Buakhamvongsa, Naruepon Sukumasavin, Nguyen Tuan, and Ouk Vibol, 2002. Mekong giant fish species: on their management and biology. MRC Technical Paper No. 3, Mekong River Commission, Phnom Penh. 29 pp.

**Deep pools as dry season fish habitats in the Mekong Basin: MRC Technical Paper 4**

Poulsen,Anders,Ouch Poeu,Sintavong Viravong,Ubolratana Suntornratana & Nguyen Thanh Tung.2002.Deep pools as dry season fish habitats in the Mekong Basin. MRC Technical Paper No. 4, Mekong River Commission, Phnom Penh. 24 pp.

**Financial analysis and risk assessment of selected aquaculture and fishery activities in the Mekong Basin: MRC Technical Paper 5**

Hambrey, John.2002.Financial analysis and risk assessment of selected aquaculture and fishery activities in the Mekong Basin. MRC Technical Paper No. 5, Mekong River Commission, Phnom Penh 66 pp.

**Fisheries in the Lower Mekong Basin: status and perspectives: MRC Technical Paper 6**

Sverdrup-Jensen, S.2002.Fisheries in the Lower Mekong Basin: status and perspectives. MRC Technical Paper No. 6, Mekong River Commission, Phnom Penh. 95 pp.

**Freshwater aquaculture in the Lower Mekong Basin: MRC Technical Paper 7**

Phillips, M.J. 2002. Freshwater aquaculture in the Lower Mekong Basin. MRC Technical Paper No. 7, Mekong River Commision, Phnom Penh. 62 pp.

**Fish migrations of the Lower Mekong Basin: imllications for development, planning and enviromental management : MRC Technical Paper 8**

Poulsen, A.F., Ouch Poeu, Sintavong Viravong, Ubolratana Suntornratana & Nguyen Thanh Tung. 2002.Fish migrations of the Lower Mekong Basin: implications for development, planning and environmental management. MRC Technical Paper No. 8, Mekong River Commission, Phnom Penh. 62 pp.

ដើម្បីព័ត៌មានលំអិតបន្ថែម សូមទំនាក់ទំនង:

**គណៈកម្មការទន្លេមេគង្គ**

ប្រអប់សំបុត្រលេខ ១១១២ # ៣៦៤ មហាវិថីព្រះមុនីវង្ស . រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (៨៥៥) (២៣) ៧២០ ៩៧៩, ទូរសារ: (៨៥៥) (២៣) ៧២០ ៩៧២
អ៊ីមែល: mrcs@mrcmekong.org
គេហទំព័រ: www.mrcmekong.org